ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jun-2012, 09:48
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី៧៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

កញ្ញា ណាតាចា វីស៊ែល រីសឺ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វ៉េង ហ៊ត់

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក រេយ៍ន័រ កែត
*(Mr.RAYNOR Keith)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោក សំ សុគង់

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Mrs. Chritine MARTINAU)*

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

លោកស្រី ស៊ីន សុវ៉ន

លោក គឹម ម៉េងឃី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ | អង់គ្លេស |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក បាណាបេ ណោគ្វី | បារាំង |
| លោក អាង ឧត្តម | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក ខៀវ នៅ (TCW-321) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក ខៀវ នៅ** (TCW-321)

សួរដោយលោក អាប់ឌុលឡាក់ ថារីក ផ្ដើមពី៖............................................................ទំព័រ ២
សួរដោយលោក ពេជ អង្គ ផ្ដើមពី៖ ...........................................................................ទំព័រ៤៨
សួរដោយលោក បាណាបេ ណេគ្វី ផ្ដើមពី៖ ..................................................................ទំព័រ៥៩
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី៖...............................................................ទំព័រ៦៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួម នៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមជម្រាបលោកប្រធាន គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែលោកមេធាវីការពារក្តីអន្តរជាតិរបស់ក្រុមមេធាវីការពារក្តី អៀង សារី គឺលោក ម៉ៃខល កាណាវាស ដែលអវត្តមានដោយមិនមានមូលហេតុ។ ចំណែកជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ។ ជនជាប់ចោទ អៀង សារី តាមរយៈមេធាវីរបស់គាត់បានស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះ សម្រាប់រយៈពេលពេញមួយថ្ងៃនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់គាត់ បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សូមអរគុណ។

[០៩:០២:២០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃ២១ ខែមិថុនា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ ដោយគាត់សុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ ដោយមានបញ្ហាសុខភាពមិនអាចអង្គុយតាមដានស្តាប់នូវកិច្ចដំណើរការសវនាការដោយផ្ទាល់បាន។ អនុសាសន៍របស់វេជ្ជបណ្ឌិតទទួលបន្ទុកពិនិត្យថែទាំងសុខភាព ព្យាបាលជនជាប់ចោទនៅមន្ទីរឃុំឃាំងបានផ្តល់យោបល់ថា នៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ ជនជាប់ចោទគួរតែត្រូវបានទទួលការអនុញ្ញាតឲ្យនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ដោយមូលហេតុលោក អៀង សារី មានអាការៈហេវហត់ ពិសេសនៅ

ពេលឡើងចុះជណ្តើរ និងពុំមានលទ្ធភាពអង្គុយចុះយូរបាន។

[០៩:០៣:២០]

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះជនជាប់ចោទ អៀង សារី បានសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការនេះដោយផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ និងក៏អាចសម្រួលដល់ទំនាក់ទំនងការងាររវាងគាត់ និងក្រុមមេធាវីការពាររបស់គាត់បានដែរ។

អង្គជំនុំជម្រះសម្រេចយល់ព្រម តាមពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។

[០៩:០៤:១៦]

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម មេធាវីការពារក្តី ហើយសូមជម្រាបសួរលោកសាក្សី ខៀវ នៅ ហើយសូមអរគុណដែលលោកបានអញ្ជើញមកទៀតថ្ងៃនេះ។ ហើយយើងខ្ញុំសូមកោតសរសើរដែលលោកបានធ្វើដំណើរឆ្ងាយមកតុលាការនេះ ហើយនិងសូមអរគុណដែរ ដែលលោកបានជួយឲ្យតុលាការស្វែងរកការពិត។

**ការតាំងសំណួរបន្តដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** អ្វីដែលខ្ញុំចង់ធ្វើបន្ទាប់ទៅនេះគឺ សួរលោកសំណួរសង្ខេបមួយ ឬពីរ សំណួរខ្លីៗ ដែលសំណួរនោះទាក់ទងទៅនឹងសម័យកាលមុនឆ្នាំ១៩៧៥ ដើម្បីបំភ្លឺនូវបញ្ហាមួយចំនួន ដែលលោកបានឆ្លើយរួចហើយ។ ហើយនិងបន្ទាប់មកទៀត នឹងសួរសំណួរមួយទាក់ទងទៅអ្វីដែលលោកបានឃើញចាប់ពីឆ្នាំ

១៩៧៥ ដល់៧៩។ ពីដំបូងនោះគឺថា លោកបានមានស្រុកកំណើតនៅត្រពាំងធំ តើត្រឹមត្រូវដែរឬទេលោកសាក្សី?

**លោក ខៀវ នៅ៖**

**ឆ៖** ពិតប្រាកដហើយ នៅត្រពាំងធំមែន។

[០៩:០៥:៥២]

**ស៖** សូមអរគុណ។ ដើម្បីឱ្យខ្ញុំយល់ច្បាស់ទៀត តើមានភាពខុសគ្នារវាង ពាក្យថា "ត្រពាំងធំ" ហើយនិង "ត្បូងឃ្មុំ" ហើយនិង "ត្រពាំងធំជើង" តើខុសគ្នាទេ? បាទ ត្រពាំងធំត្បូង និងត្រពាំងធំជើង តើខុសគ្នាដូចម្ដេច?

**ឆ៖** ខ្ញុំ-- ឃ្លាខាងដើមនេះ ចាប់ផ្ដើមនិយាយអត់បាន សមគួរដល់លោកប្រធាន។ ដូច្នេះសូមបកក្រោយបន្តិច។ សូមគោរពលោកប្រធាន ហើយក៏សូមអភ័យទោស ចំពោះចំណុចខ្វះខាត ដែលខ្ញុំភ្លាំងភ្លាត់ដែលខ្ញុំនិយាយទៅច្រឡំ។ ព្រោះសុខភាពប្រែប្រួលខ្លះ ដំណេកមិនសូវគ្រប់គ្រាន់ មានការគិតពីនេះពីនោះច្រើនទៅវាស្មារតីមិនសូវគ្រប់គ្រាន់ និយាយទៅអាចត្រឡប់មុខត្រឡប់ក្រោយ។ ហេតុដូច្នេះ សូមចំពោះចំណុចទាំងអស់នេះ គឺសូមអភ័យទោស។ ហើយតទៅ សូមសួរបញ្ជាក់សំណួរលោកម្ដងទៀត ដើម្បីឱ្យចាំកាន់តែច្បាស់។

**ស៖** បាទ ខ្ញុំនឹងសួរ។ សូមលោកប្រាប់ខ្ញុំ បើសិនជាលោកមិនច្បាស់សំណួររបស់ខ្ញុំ។ ខ្ញុំយល់ថា មានឃុំពីរ ដែលមានឈ្មោះស្រដៀងគ្នា។ មួយ ហៅថា "ត្រពាំងធំត្បូង" ហើយនិងមួយទៀត គេហៅថា "ត្រពាំងធំជើង" បាទ ជាឃុំពីរហ្នឹង។ តើឃុំទាំងពីរនេះ ក្នុងឃុំមួយណា ដែលជាស្រុកកំណើតរបស់លោកនោះ?

**ឆ៖** សូមជម្រាបលោក។ ឃុំត្រពាំងធំនេះ កាលដែលកើតនោះតែមួយទេ ហៅថា ត្រពាំងធំតែមួយទេ តែដល់មកក្រោយមកបានបែកជាពីរ។ បែកជាពីរ មានថ្នល់ទៅពីអង្គតាសោម ទៅត្រពាំងអណ្ដើកហ្នឹងវាចែក ដល់ចែកជាពីរអ៊ីចឹង វាទៅជាត្រពាំងធំខាងត្បូង ត្រពាំងធំខាងជើង មិនមែនត្រពាំងធំត្បូង ត្រពាំងធំជើងទេ គឺទិសខាងត្បូង ទិសខាងជើង។ សព្វថ្ងៃនេះ ភូមិកំណើតរបស់ខ្ញុំនៅក្នុងឃុំត្រពាំងធំខាងត្បូង ជិតនៅខាងលិចវត្តត្រពាំងធំ។ សូមជ្រាប។

[០៩:០៨:៤២]

**ស៖** សូមអរគុណលោកសាក្សី ហើយសំណួរមួយទៀតទាក់ទងទៅនឹងសម័យកាលនោះ។ តើ

តាម៉ុក មានស្រុកកំណើតនៅក្នុងឃុំដដែលនេះ ឬក៏ស្រុកកំណើតគាត់នៅកន្លែងណាផ្សេងបាទ?

**ឆ៖** ស្រុកកំណើតគាត់នៅក្នុងឃុំត្រពាំងធំ។ សព្វថ្ងៃវា ត្រពាំងធំខាងត្បូងដែរ។ មិនមែនត្រពាំងធំខាងជើងទេ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ហើយខ្ញុំនឹងចូលទៅខាងមុខទៀតបាទគឺ សួរលោកអំពីខែមេសា ឆ្នាំ១៩៧៥ ហើយនិងសួរបន្តពីសំណួរម្សិលមិញ ដែលសហព្រះរាជអាជ្ញាជាតិសួរ។ លោកបានជម្រាបតុលាការថា ព្រះសង្ឃដែលស្ថិតនៅក្នុងខេត្តតាកែវ ឬមកពីភ្នំពេញនោះ ត្រូវបានគេៗយកទៅដាក់កន្លែងមួយ ឬក៏និមន្តមកវត្តមួយ គឺនៅឆ្នាំ-- នៅខែមេសា ឆ្នាំ១៩៧៥។ តើលោកនៅចាំឈ្មោះវត្តនុ៎ងទេបាទ?

[០៩:១០:០៤]

**ឆ៖** វត្តនោះហៅវត្តអង្គរកា ពេលនោះខ្ញុំនៅបួសភេទជាបព្វជិតដែរ ជាភិក្ខុស្នាក់នៅកន្លែងនោះឯមកជួបគ្នានៅវត្តអង្គរកាហ្នឹង។

**ស៖** ជាពិសេសខ្ញុំចាប់អារម្មណ៍ថា តើនៅពេលណាដែលលោកអញ្ជើញទៅវត្តនោះ? តើលោកទៅដល់វត្តនោះនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ឬក៏ទៅមុនថ្ងៃហ្នឹង ឬក៏ក្រោយថ្ងៃហ្នឹងបាទ?

**ឆ៖** ខ្ញុំទៅមុន។ ពីមុនមកខ្ញុំនៅវត្តត្រពាំងធំ ហើយបានទៅនៅអង្គរកា។ ដល់ពេលទៅនៅអង្គរកាហ្នឹងបានបន្តិច ដល់ពេលចប់សង្គ្រាម ក៏មានលោកមកជួបជុំគ្នានៅវត្តអង្គរកាហ្នឹង។ ខ្ញុំទៅមុន។

[០៩:១១:២២]

**ស៖** សូមអរគុណ។ ថាហេតុអ្វីបានជាលោកបានចាកចេញពីវត្តត្រពាំងធំនៅក្នុងឃុំនេះ ទៅវត្តអង្គរកា ហេតុអីបានជានិមន្តទៅទីនោះនៅកាលនោះ?

**ឆ៖** កាលនោះអ្នកធ្វើការគេប្រាប់ថា អង្គការតម្រូវឲ្យទៅនៅវត្តអង្គរកា ហើយមិនចាំឈ្មោះទេអ្នកដែលប្រាប់ហ្នឹងគ្រាន់តែក្នុងនាមអង្គការមិនដឹងជា-- មិនចាំទេ វាកន្លងទៅជិត៤០ឆ្នាំហើយ។

**ស៖** តាមអ្វីដែលខ្ញុំយល់ចម្លើយរបស់លោកហ្នឹង គឺថាបើខ្ញុំយល់ខុសកែខ្ញុំផង គឺមុនឆ្នាំ១៩៧៥ ខែមេសា ព្រះសង្ឃមកពីវត្តមួយចំនួនគឺត្រូវបានគេប្រាប់ឲ្យទៅវត្តអង្គរកា។ តើអ៊ីចឹងមែនឬទេ?

**ឆ៖** ត្រង់គេប្រាប់ខ្ញុំមិនបានដឹងទេ ស្រាប់តែជួបគ្នានៅវត្តអង្គរកា។ អ្នកណាប្រាប់ៗកន្លែងណាខ្ញុំមិនបានដឹងទេ ប៉ុន្តែស្រាប់តែជួបគ្នា។

[០៩:១២:៥៩]

**ស៖** សំណួរមួយទៀតដែលទាក់ទងទៅនឹងពេលដែលលោកទៅដល់វត្តអង្គរកានោះ តើលោក

មិនចាំថាអ្នកណាជាអ្នកប្រាប់ឲ្យទៅទេ ប៉ុន្តែតើកាលនោះលោកត្រូវតែទៅវត្តអង្គរកា បើសម្រេចថាមិនទៅគឺថាមិនទៅនឹងបានដែរឬទេ?

**ឆ៖** មិនបាន ៗគិតដល់កន្លែងអស់ហ្នឹងទេ ព្រោះក្នុងពេលនោះគឺប្រយ័ត្នគ្រប់ជំហាន បើថាឲ្យទៅហ្នឹងគឺរៀបចំទៅតែម្តង។ ហើយសូមជម្រាបថែមបន្តិចបន្តួចទៀតចុះ កុំឲ្យពិបាកសួរច្រើន។ តាំងពីខ្ញុំនៅក្មេងកើតសង្គ្រាមមកប៉ុន្មានលើកប៉ុន្មានសាហ្នឹងចាស់ៗគាត់ច្រើនតែប្រាប់ថា ឲ្យដាំដើមគ កុំធ្វើចេះធ្វើដឹងពេក ហើយយើងគោរពតាមចាស់តាមទុំហ្នឹង យើងមិនសូវមាត់សូវកទេ។ បើគេឲ្យទៅឯណាហ្នឹងទៅអីហ្នឹងសិនទៅ ដើម្បីរស់។ សូមនិយាយដោយសង្ខេបប៉ុណ្ណឹង។ ហើយមិនតែពេលហ្នឹងទេតាំងពីមុនមកដែលមានកលិយុគក្នុងស្រុកក្នុងទេសហ្នឹង។ ហ្នឹងសូមហៅថា ឆ្លើយក្រៅសំណួរបន្តិចចុះ ប៉ុន្តែវាទាក់ទងនឹងសំណួរ។

[០៩:១៥:៣៩]

**ស៖** អ្នកដែលប្រាប់លោកឲ្យទៅវត្តអង្គរកានោះ តាមដែលលោកចាំ តើក្រុមអ្នកដែលប្រាប់លោកឲ្យទៅវត្តអង្គរកានោះ តើពួកហ្នឹងស្ថិតនៅក្នុងរបបសាធារណរដ្ឋខ្មែរ ឬក៏នៅក្នុងក្រុមខាងចលនាខាងបដិវត្តន៍ខ្មែរក្រហម?

**ឆ៖** ខាងចលនាខ្មែរក្រហម ហៅពួករណសិរ្ស អង្គការរណសិរ្ស។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចូលទៅដល់ផ្នែកមួយទៀតដែលនិយាយពីថ្ងៃ គឺថ្ងៃទី១៧ ខែមេសា ហើយនិងតទៅមុខទៀត ហើយថាតើរយៈពេលប៉ុន្មាន ហើយមានព្រះសង្ឃប៉ុន្មានអង្គដែលមកពីខេត្តតាកែវ ទៅចូលរួមនៅវត្តអង្គរកាជាមួយលោកនោះ ពីភ្នំពេញជាដើមហ្នឹង?

**ឆ៖** ខ្ញុំមិនបានដឹងទេ ពីព្រោះខ្ញុំមិនមែនជាអ្នកទទួលខុសត្រូវ គ្រាន់តែឃើញមកជួបជុំគ្នា លោកអង្គណាដែលធ្លាប់ស្គាល់គ្នា ក៏សួរសុខទុក្ខគ្នា បានចប់សង្គ្រាមនាំគ្នារីករាយសប្បាយ។ ហើយត្រង់កំណត់ថាប៉ុន្មានៗហ្នឹង មិនបានជាគិតគូរ។ ហើយខ្ញុំក៏មិនមែនជាអ្នកប្រវត្តិសាស្ត្រ ក៏មិនមែនជាអ្នកយកការណ៍អីដែរ។ ដូច្នេះមិនបានដឹងទេ ចំនួនអីសព្វគ្រប់ ច្បាស់លាស់អត់ទេ។

[០៩:១៦:៣៤]

**ស៖** សូមអរគុណ។ សូមលោកមានអារម្មណ៍ទុកចិត្តខ្លួនឯង គឺប្រាប់អ្វីដែលលោកច្បាស់អ្វីដែលលោកមិនច្បាស់បាទ។ តើលោកស្គាល់ទេ អ្នកណាជាអ្នកបញ្ជូនព្រះសង្ឃទាំងអស់នេះ ឲ្យមកវត្តអង្គរកា។ តើព្រះសង្ឃទាំងអស់នោះ អង្កាល់នោះលោកមានឆន្ទៈថាមកដោយខ្លួនឯង ដោយអង្គឯង

ឬក៏អ្នកណាគេបញ្ជូនមក?

**ឆ៖** បញ្ហានេះ ក៏អត់បានដឹងដល់ឫស ដល់គល់អីទេ គឺស្រាប់តែទៅជួបគ្នា ហើយនាំគ្នានិយាយថា អង្គការឲ្យមកជួបជុំគ្នាកន្លែងហ្នឹង។ អត់មានចេញឈ្មោះបុគ្គលទេ ចេញឈ្មោះអង្គការ។

**ស៖** សូមអរគុណ។ ហើយបន្ទាប់ពីជុំគ្នានៅវត្តអង្គរការួចហើយ តើមានហេតុការណ៍ ឬក៏បញ្ហាអ្វីកើតឡើងបន្តទៅទៀត?

**ឆ៖** ត្រូវរៀបចំដំណើរចាកសិក្ខាបទ ពាក្យធម្មតាហៅថា សឹក។ ខ្ញុំក៏លាចាកសិក្ខាបទ គឺសឹកចាកផ្នួសក្នុងពេលហ្នឹងជាមួយនឹងលោកមួយចំនួន ច្រើនដែរ ប៉ុន្តែមិនបានចាំចំនួនថាប៉ុន្មានៗទេ គ្រាន់តែថាច្រើនគួរសមដែរ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកមានប្រសាសន៍ថា លោកបានរៀបចំលាចាកសិក្ខាបទ ថាតើមានអ្វីជាកត្តាជំរុញថា ត្រូវតែលាចាកសិក្ខាបទ ឬក៏ត្រូវតែសឹកនោះ?

[០៩:១៨:៤៨]

**ឆ៖** កត្តា គឺ រួចដូចខ្ញុំបញ្ជាក់ខាងដើមថា ពាក្យចាស់ថាកុំឲ្យធ្វើចេះ កុំឲ្យធ្វើដឹង កុំឲ្យរឹងទទឹង គឺចាំនាំគ្នាដាំដើមគ ទើបបានសេចក្តីសុខ។ ដូច្នេះ អត់បាច់គិតរកអីវែងឆ្ងាយទេ បើឮថាឲ្យសឹក គឺនាំគ្នាសឹកតែម្តងទៅ។ មិនបានគិតដល់ឫស រកគល់អីវែងទេ។

**ស៖** សូមអរគុណ។ ប្រហែលជាសំណួររបស់ខ្ញុំមិនច្បាស់ ប៉ុន្តែលោកបានឆ្លើយហើយ។ តើលោកនៅចាំទេ អ្នកណាជាអ្នកណែនាំ ឬក៏ប្រាប់ថាឲ្យលាចាកសិក្ខាបទនោះ?

**ឆ៖** រកឈ្មោះបុគ្គលមិនឃើញទេ មិនចាំទេ ប៉ុន្តែឮថា គ្រាន់តែឮថា អង្គការៗ ប៉ុន្តែពេលនោះច្រើន អាហ្នឹងយើងថា ប្រហែលទេ និយាយប្រហែលចុះ។ ពួកក្មេងធ្វើឈ្លបឃុំ ឈ្លបអីហ្នឹង ដើរប្រាប់ហ្នឹង អត់មានចេញជាគណៈឃុំ គណៈខេត្ត គណៈស្រុកមកផ្ទាល់ទេ។ ពួកឈ្លបឃុំ ឈ្លបនេះហ្នឹង គឺមកប្រាប់ អាហ្នឹងគឺមិនច្បាស់ទេ ប៉ុន្តែប្រហែលជាអ៊ីចឹង ថាអង្គការឲ្យ--

**ស៖** ដើម្បីកុំឲ្យមានការសង្ស័យ នៅពេលដែលលោកនិយាយថា ឈ្លបឃុំហ្នឹង តើលោកចង់សំដៅពួកខ្មែរក្រហម ឬក៏ក្រុមខាងណា?

**ឆ៖** ក្នុងពេលនោះគឺពួកអង្គការរណសិរ្សហ្នឹងហើយ។ ពួកខាងអង្គការរណសិរ្សហ្នឹងហើយ ព្រោះចប់សង្គ្រាម ពួកភ្នំពេញចេញមកក្រៅហើយ ចេញពីក្រុងមកក្រៅហើយ។ ដូច្នេះ មានតែពួកហ្នឹងម្យ៉ាងទេ។

**ស៖** នៅពេលនេះ តាមអ្វីដែលខ្ញុំយល់ចម្លើយរបស់លោកបានត្រឹមត្រូវនោះ គឺថាលោកបានជាព្រះសង្ឃប្រហែលជា១៥ឆ្នាំ-- ១៥វស្សា។ ក្រោយពី១៥ឆ្នាំ តើលោកយល់ដូចម្ដេច ឬក៏មានអារម្មណ៍ដូចម្ដេចដែលថា គេឲ្យសឹកពីបួសបែបនេះនោះ?

[០៩:២១:៥១]

**ឆ៖** ខ្ញុំមិនត្រឹមតែ១៥ទេ ២៥ តាំងក្នុងអាណានិគមបារាំងមក ឆ្នាំ៥១មក មកដល់៧៥។ ហើយត្រង់នេះមិនបាច់ដេញដោលច្រើនទេ។ ធម៌វិន័យក្នុងពុទ្ធសាសនាហ្នឹងវាចាក់ឫសជ្រៅហើយ។ មិនបាច់ដេញដោលច្រើនទេ។ វាមិនជ្រះស្រឡះក្នុងចិត្តទេ។ បើសិនជាមានលោកនៅ ក៏នៅជាមួយនឹងគេទៅ ប៉ុន្តែដល់អត់មានលោក ក៏អត់ហ៊ាននៅទៅ។ ព្រោះពេលនោះ សុខភាពក៏អន់ដែរ។ ឯអាយុ៤២ហើយ។ ហ្នឹងសូមជម្រាបដោយខ្លីតែប៉ុណ្ណេះ។

**ស៖** លោកបានជម្រាបតុលាការខាងដើមថា មានព្រះសង្ឃជាច្រើនដែលរាប់ទាំងលោកផង គឺថាត្រូវបានលាចាកសិក្ខាបទនៅវត្តអង្គរកា។ ចុះបើមានព្រះសង្ឃមិនព្រមលាចាកសិក្ខាបទ នឹងជួបបញ្ហាអ្វីដែរ?

**ឆ៖** ដល់ឃ្លាថា "បើ" នេះ ខ្ញុំមិនបានដឹងទេ។ ព្រោះអត់បានគិតឲ្យល្អិត ដល់ថ្នាក់ "បើ" ទៀតទេ។ បានគេឲ្យសឹក ក៏សឹកទៅ ឲ្យតែរួចខ្លួន ខ្លួនឯង ព្រោះអត់មាននៅអាល័យទៅគិតគូរអីវែងឆ្ងាយដល់គេដល់ឯងច្រើនទៀតទេ។

**ស៖** តើលោកបានសង្កេតឃើញថាព្រះសង្ឃផ្សេងៗទៀត តើព្រះសង្ឃណាខ្លះដែលមិនព្រមសឹកដែរឬទេ ដែលថាចង់បន្តនៅជាព្រះសង្ឃតទៅទៀតនោះ?

[០៩:២៤:១៣]

**ឆ៖** ក្នុងពេលជាមួយគ្នានោះមិនឃើញអង្គណាមួយ ភិក្ខុ ឬសាមណេរអង្គណាមួយថាមិនព្រមទេ ក្នុងពេលជាមួយគ្នា។ អាហ្នឹងគឺសូមបញ្ជាក់ដោយខ្លី។

**ស៖** ដើម្បីឲ្យខ្ញុំយល់ច្បាស់ តើមានន័យថា ព្រះសង្ឃទាំងអស់នៅវត្តអង្គរកាហ្នឹង គឺត្រូវតែលាចាកសិក្ខាបទ។ តើអ៊ីចឹងមែនឬទេ?

**ឆ៖** ត្រូវតែ មិនត្រូវតែ ក៏ខ្ញុំមិនដឹងច្បាស់ដែរ ប៉ុន្តែថាឮឲ្យ ថាឲ្យលាចាកក៏នាំគ្នាប្រញិបប្រញាប់។ អត់មាននៅតវ៉ាអីច្រើនទេ អត់មានដេញដោលអីច្រើនទេ។ បើគេថាឲ្យធ្វើអី គឺប្រញាប់ធ្វើហ្នឹងទៅ។ ហ្នឹង គឺសូមជម្រាប។

**ស៖** ខ្ញុំមានសំណួរពីរបីទៀត ទាក់ទងនឹងប្រធានបទនេះ ប៉ុន្តែខ្លីៗទេបាទ។ បន្ទាប់ពីលោកលាចាកសិក្ខាបទរួចមក តាមអ្វីដែលលោកបានដឹងនោះ តើមានព្រះសង្ឃណា អង្គណាគង់នៅទេ នៅក្នុងតំបន់ ឬក៏ក្នុងវត្តនោះ? ឬក៏ព្រះសង្ឃទាំងអស់ដែលលោកស្គាល់ លោកបានដឹងនោះ សុទ្ធតែលាចាកសិក្ខាបទទាំងអស់?

[០៩:២៦:០៣]

**ផ៖** សូមបញ្ជាក់លោក វត្តនោះគឺវត្តណា?

**ស៖** នៅក្នុងចម្លើយរបស់លោក លោកបាននិយាយថា វត្តអង្គរកា ហើយលោកក៏បាននិយាយវត្តមួយទៀត នៅក្នុងសំរោង គឺវត្តថ្មីកជ្រៃ បាទ?

**ផ៖** បាទ សូមបញ្ជាក់ កាលមុន ខ្ញុំបាននិយាយទៅដល់វត្តថ្មីកជ្រៃ ប៉ុន្តែក្នុងការសួរអម្បាញ់មិញនេះ គឺ អត់ទាន់បាននិយាយទេ គឺគ្រាន់តែបញ្ជាក់។ ឥឡូវ គឺដល់មកក្រោយមក ខ្ញុំមកបាត់ហើយ បានឮដំណឹងថា លោកដែលនៅសល់ ឲ្យទៅគង់នៅវត្តថ្មីកជ្រៃ។ ហ្នឹងខ្ញុំចេញមកបាត់ហើយ។

**ស៖** តើលោកធ្លាប់បានឮដែរឬទេ អ្វីៗដែលថាកើតមានឡើងចំពោះព្រះសង្ឃដែលនៅវត្តថ្មីកជ្រៃនោះបាទ?

**ផ៖** ឮៗ ដែរ ប៉ុន្តែឮតៗមកឆ្ងាយហើយ។ ព្រោះលោកដែលទៅថ្មីកជ្រៃហ្នឹង មានលោកមួយអង្គបួសចាស់ ហើយលោកធ្លាប់នៅព្រៃធ្វើសមាធិ។ នាមលោក អង្គ ហៅ វិចាអង្គ នៅខាងគិរីវង្ស។ ហើយដែលខ្ញុំជួបដឹងថែមទៀតហ្នឹង គឺមកក្រោយពេលក្រោយ ប្រហែលជាប្អូនប្រាំឆ្នាំមុននេះ ជួបអ្នកស្រុកគិរីវង្ស។ អ្នកស្រុកគិរីវង្សថា គេឲ្យសឹក លោកមិនព្រមសឹក ក៏លោកទៅចងក អាហ្នឹងដឹងក្រោយ ដឹងតាមរយៈអ្នកស្រុកគិរីវង្ស ដឹងនៅភ្នំពេញហ្នឹង ជួបគ្នានៅជិតពេទ្យសូវៀត ដឹងក្រោយទេ អាហ្នឹងដឹងក្រោយ។

[០៩:២៨:៤៥]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចូលទៅដល់ប្រធានបទមួយទៀត ដែលម្សិលមិញ លោកបានជម្រាបសហព្រះរាជអាជ្ញាជាតិថា ក្រោយពីថ្ងៃទី១៧ ខែមេសា ប្រជាជននៅអាចប្រតិបត្តិពុទ្ធសាសនាបាន ប៉ុន្តែមានកម្រិត តើលោកអាចជម្រាបបន្ថែមបានទេ ថាតើការប្រតិបត្តិសាសនា ក្រោយពីថ្ងៃទី១៧ ខែមេសា ហ្នឹង កម្រិតអាចប្រតិបត្តិបានកម្រិតណា? មិនបានកម្រិតណា?

**ផ៖** បានហ្នឹង គឺសំដៅយកន័យ គឺសង្ឃ លោកគង់នៅវត្តថ្មីកជ្រៃហ្នឹង ហើយអ្នកស្រុកទៅធ្វើ

បុណ្យ ទៅប្រគេនចង្ហាន់ហ្នឹង។ កម្រិតប៉ុណ្ណឹង។ ឥឡូវ ស្រេចលោកជួយវាស់កម្រិតមើលចុះ ហើយខ្ញុំមិនបានតាមពិនិត្យវែងឆ្ងាយទៀតទេ។ ប៉ុន្តែនៅមានអ្នកស្រុកទៅប្រគេនចង្ហាន់លោកដែរ ទម្រាំលោកលាចាកសិក្ខាបទអស់។ ដែលចម្លើយម្សិលមិញនេះ គឺសំដៅត្រង់ហ្នឹង។

**ស៖** សូមអរគុណ។ ខ្ញុំដឹងហើយថា យូរណាស់មកហើយ ប៉ុន្តែលោកដឹងដែរឬទេ ថាតើរយៈកាលប៉ុនណា ដែលថាប្រជាជននៅអាចទៅវត្តថ្មីកជ្រំហ្នឹង អាចប្រគេនចង្ហាន់ព្រះសង្ឃបាននោះ បាទ?

[០៩:៣០:១៥]

**ឆ៖** ដាក់កំណត់ឲ្យច្បាស់លាស់មិនបានទេ ប៉ុន្តែមើលទៅមិនយូរទេ ពេលតិចទេ ប្រហែលជាមួយឆ្នាំហ្នឹង អស់យូរពីរឆ្នាំប៉ុណ្ណឹង។ ប៉ុន្តែប្រហែលជាមិនដល់ពីរឆ្នាំទេ។ អាហ្នឹងប៉ាន់ស្មាន។

**ស៖** តាមដែលខ្ញុំយល់ចម្លើយមុនៗរបស់លោកនោះ គឺមួយឆ្នាំក្រោយពីពេលនោះមក គឺលោកសង្ឃទាំងអស់ គឺត្រូវបានផ្សឹក ហើយប្រជាជនមិនអាចទៅវត្តអារាមបានទេ។ តើចម្លើយនេះត្រឹមត្រូវអ៊ីចឹងមែនទេ?

[០៩:៣១:០៣]

**ឆ៖** សូមបញ្ជាក់សំណួរម្តងទៀត។

**ស៖** លោកបានជម្រាបជូនអង្គជំនុំជម្រះថា ការប្រតិបត្តិព្រះពុទ្ធសាសនា គឺប្រហែលជាមួយឆ្នាំក្រោយខែមេសា ឆ្នាំ១៩៧៥។ លោកសង្ឃនៅវត្តថ្មីកជ្រំទាំងអស់គឺថាត្រូវបានផ្សឹក។ ខ្ញុំបញ្ជាក់ម្តងទៀត គឺប្រហែលជាមួយឆ្នាំក្រោយខែមេសា ឆ្នាំ១៩៧៥ លោកសង្ឃទាំងអស់ត្រូវចាប់ផ្សឹក ហើយប្រជាជនមិនអាចទៅវត្តអារាមបានទេ តើអ៊ីចឹងមែនទេ?

**ឆ៖** អ្អែ៎ ត្រង់នេះបើបញ្ជាក់ឲ្យងាយទៅ គឺថាបើអស់លោកហើយ ដឹងទៅវត្តធ្វើអីទៀត អាហ្នឹងបើនិយាយចំកន្លែងហ្នឹង។ បើទៅ ទៅដោយសារមានលោក ហើយបើទៅអត់លោកហ្នឹង មិនមែនទៅធ្វើបុណ្យទេ គ្រាន់ទៅមើលវត្ត។ អាហ្នឹងវាន័យថាលោកអស់ហើយ ហើយទៅហ្នឹង។ អាហ្នឹងន័យហ្នឹងវាអ៊ីចឹង សូម-- ហើយបើថាម៉េចៗសូមបញ្ជាក់ថែមទៀត។

[០៩:៣២:៣៧]

**ស៖** អរគុណលោកសាក្សី ខ្ញុំមានសំណួរពីរបីទៀត ទាក់ទងទៅនឹងព្រះពុទ្ធសាសនា គឺប្រជាជនមិនអាចទៅជួបលោកសង្ឃបានទេ។ ប៉ុន្តែសំណួររបស់ខ្ញុំថា តើប្រជាជនអាចនឹងប្រតិបត្តិព្រះពុទ្ធសាសនានៅតាមផ្ទះសម្បែងរបស់គាត់បានទេ?

**ឆ៖** ត្រង់នេះ គឺខ្ញុំសូមបញ្ជាក់ខ្លួនខ្ញុំផ្ទាល់។ នៅកាន់តាមព្រះពុទ្ធសាសនាដែរឬយ៉ាងម៉េច? ខ្ញុំកាន់រហូត កាន់សីលរហូត តាំងពីថ្ងៃចូលបួស មកទល់សព្វថ្ងៃនេះ មិនដែលអត់សីលទេ។ យើងមានទៅអួតប្រាប់គេឯណា ទើបមកឥឡូវហ្នឹងបានអួតប្រាប់ បើពីមុនមកអត់ទេ ស្ងាត់ ប៉ុន្តែគេដឹងៗ ដឹងថាយើងនៅកាន់។ ហើយដឹងស្ងាត់ រកភស្តុតាងមិនឃើញ បើយើងនឹកគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ នឹកតែក្នុងចិត្ត ហើយខ្សឹបៗ មានអ្នកណាយក មកយកការណ៍ផ្ទាល់អីអត់ទេ គឺកាន់ស្ងាត់ៗ កាន់ចំហអាហ្នឹងវាមិនឃើញមានគេធ្វើចំហទេ។ ហើយបើកាន់ស្ងាត់ គឺខ្លួនខ្ញុំហ្នឹងហើយកាន់ស្ងាត់។ ហើយមានច្រើនទៅទៀត របៀបកាន់ស្ងាត់ ខ្សឹបគ្នាស្ងាត់ៗហ្នឹងក៏មានច្រើនដែរ គ្រាន់តែដឹងគ្នា។ សូម--

[០៩:៣៤:៣៥]

**ស៖** សំណួរចុងក្រោយទៅលើបញ្ហាព្រះពុទ្ធសាសនានេះ។ ហេតុអ្វីបានជាលោកត្រូវគោរពប្រតិបត្តិព្រះពុទ្ធសាសនាហ្នឹង ដោយស្ងៀមស្ងាត់បែបហ្នឹង ដោយស្ងាត់ៗបែបនេះ?

**ឆ៖** អត់មានហេតុអីច្រើនទេ ហេតុជឿៗព្រះពុទ្ធសាសនា។ ជឿជំនឿ ជឿច្បាស់ថា បើជាសាសនាដ៏ត្រឹមត្រូវ សាសនាឯកក្នុងលោក ហើយពិភពលោកកាន់ពេញទូទៅសកលលោក ហើយគម្ពីរមានរាប់រយក្បាល។ សម្តេច ជួន ណាត រៀបចំក្រុមជំនុំប្រែព្រះត្រៃបិដកពីភាសាបាលី និងមគធភាសាមក មកជាភាសាខ្មែរ ប្រស្រ្តពីន័យប្រអប់បថម មានគោលច្បាប់ច្បាស់លាស់ មានលក្ខណៈច្បាស់លាស់នេះហើយដែល-- មិនមែនគ្រាន់តែឃើញតែឃើញគម្ពីរហើយជឿទេ យើងរៀនសូត្រច្រើនទៀតហើយនិយាយឲ្យខ្លីមកហេតុជឿ។

[០៩:៣៦:០០]

**ស៖** ខ្ញុំសូមបញ្ជាក់ទៅលើសំណួរនេះឡើងវិញ ហើយអរគុណណាស់ ចំពោះចម្លើយរបស់លោក។ សំណួរខ្ញុំគឺ ថាតើមានហេតុផលអ្វី ដែលនាំឲ្យលោកមិនអាចគោរពប្រតិបត្តិ ដោយចំហបានទេ? ជាការពិតហើយ លោកអាចគោរពប្រតិបត្តិដោយស្ងាត់ៗបាន ប៉ុន្តែថាតើមានហេតុផលអ្វីដែលនាំឲ្យលោកមិនអាចគោរពប្រតិបត្តិ ដោយបើកចំហបានទេ?

**ឆ៖** ចុះបើអស់លោក អស់លោកទៅហើយ លោកសឹកទៅហើយ។ ឯយើងនៅៗពើងទ្រូងដល់ណាទៀត នៅចំហដល់ណាទៀត បើអស់ហើយ គេគ្រប់គ្នាគេឈប់អស់ហើយ។ ដូច្នេះ យើងអត់ប៊ានទេ។

**ស៖** សូមអរគុណ។ នៅក្នុងស្រុករបស់លោក គឺស្រុកត្រាំកក់ តើមានសហគមន៍ចាម រស់នៅ

ទីនោះដែរឬទេ?

**ឆ៖** មាន មិនមាន មិនច្បាស់ទេ ប៉ុន្តែតាមដែលដឹង ដូចមានចាមដំដែកខ្លះដែរ ចាមដំដែក។ អាចមានខ្លះមិនអត់ទេ ចាមដំដែក ប៉ុន្តែភូមិចាមអីគគ្រឹកគគ្រេង អត់ទេ។ អត់មានភូមិចាមអីអត់ទេ ហើយនិងគេយក-- កូនខ្មែរ គេយកទៅទៅលក់ឲ្យចាម។ ហ្នឹងនៅខាងកើតវត្តត្រពាំងធំ គឺនឹកឃើញត្រឹមប៉ុណ្ណឹង សូមជម្រាបខ្ពី។

[០៩:៣៨:២៤]

**ស៖** លោកបានជម្រាបជូនតុលាការថា លោកសង្ឃត្រូវបានចាប់ផ្សឹក ហើយព្រះពុទ្ធសាសនាមិនត្រូវបានអនុញ្ញាតឲ្យប្រតិបត្តិ ឬក៏មិនអាចប្រតិបត្តិ ដោយបើកចំហបានទេ។ តើចំពោះសាសនាអ៊ីស្លាមវិញថាតើជនជាតិចាមនេះ អាចប្រតិបត្តិសាសនារបស់ខ្លួនបានទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេ ដល់ចាម ដល់អីទៀត ខ្ញុំមិនដឹងទេ។ ដឹងជាផ្លូវការមែនទែន គឺមិនដឹង ហើយមួយទៀត លោកប្រើពាក្យថា ចាប់ផ្សឹក អត់មានចាប់ទេ គ្រាន់តែប្រាប់ឲ្យលាចាកសិក្ខា ប្រើពាក្យថា ចាប់ហ្នឹងហួសហើយ។ អត់ឃើញចាប់។ មិនឃើញចាប់ ហើយមិនឮថាចាប់។

**ស៖** ប្រជាជនចាម ដែលលោកបានស្គាល់ ឬក៏បានឃើញនៅក្នុងអំឡុងពេលនោះ តើពួកគាត់អាចនៅគោរពប្រតិបត្តិសាសនារបស់ខ្លួនបានទេ? សូមលោកជម្រាប បើសិនណាជាលោកបានដឹង បើមិនបានដឹង លោកឆ្លើយតាមនោះចុះ។

[០៩:៤០:០៧]

**ឆ៖** មិនបានដឹងទេ។ សូមជម្រាបដោយខ្ពី។

**ស៖** មុននឹងបញ្ចប់សំណួរទៅលើបញ្ហាសាសនានេះ គឺចម្លើយរបស់លោកមុនៗ លោកបានឆ្លើយថាមិនមានការបង្ខំ ឬក៏ថាចាប់បង្ខំឲ្យលោកសង្ឃ ចាប់ផ្សឹកលោកសង្ឃនោះទេ។ ចំពោះលោកផ្ទាល់ហ្នឹងតើក្រោយពីលោកលាចាកសិក្ខាបទហើយ ថាតើលោកអាចចង់បួសឡើង-- បើលោកចង់បួសឡើងវិញតើលោកអាចបួសឡើងវិញបានទេ?

[០៩:៤១:១១]

**ឆ៖** ពេលបីឆ្នាំហ្នឹង អាហ្នឹងវានៅក្នុង "បើ" ទៀតហើយណ៎ា។ បាទ វាអត់ វាមិនត្រូវចង់បួសនឹកចងបួសផង។ ព្រោះលាចាកមកបានពីរឆ្នាំ ដល់អាយុ៤៤ ក៏មានគ្រួសារហើយ ចង់បួសចោលប្រពន្ធកូនអីទៀត។ ដូច្នេះ "បើ" ក្នុងហ្នឹងមិនបាច់ "បើ" ក៏បានដែរ។ ឯត្រង់សភាពការណ៍ប្រទេស អាហ្នឹង

ណ៌ា អាហ្នឹងមិនបានគិតវែងឆ្ងាយទេ ប៉ុន្តែផ្ទាល់ខ្លួនវាអ៊ីចឹង។ បើការមិនទាន់លាចាកអាហ្នឹងវាចង់នៅតទៅទៀត ប៉ុន្តែដល់លាចាកមកហើយ វាខ្ជិលត្រឡប់ត្រឡិនព្រោះបួសយូរដែរហើយ។

**ស៖** អរគុណលោក។ ប្រសិនណាជាយើងអាចត្រឡប់ទៅដល់ការធ្វើដំណើររបស់គាត់គឺនៅក្នុងខែមេសា ១៩៧៥ នៅពេលលោកលាចាកសិក្ខាបទ ហើយចាកចេញពីវត្តនោះទៅ តើលោកធ្វើដំណើរទៅទីណា?

[០៩:៤២:៤៨]

**ឆ៖** មុនដំបូងទៅផ្ទះម្ដាយ ភាសាដែលហៅថា "ផ្ទះញោម" បើម្ដាយនៅ។

**ស៖** ហើយក្រោយពេលនោះមកលោកបន្តរស់នៅជាមួយក្រុមគ្រួសារ ឬក៏លោកទៅធ្វើការអ្វីមួយ? តើលោកទៅធ្វើអ្វី?

**ឆ៖** បន្ទាប់ពីនោះមក ដោយខ្ញុំសុខភាពខ្សោយ មានការឈឺច្រើនពួកឃុំ ពួកនេះ-- ឃុំ និងស្រុកគេឲ្យទៅនៅជាមួយពេទ្យ ហើយយើងដឹងថ្នាំបរមបុរាណអីខ្លះ ដឹងថ្នាំពេទ្យអីខ្លះជួយប្រាប់គេ។ មូលដ្ឋានពេទ្យនៅកន្លែងវត្តត្រពាំងគល់ ក្នុងឃុំត្រពាំងធំខាងជើង។

**ស៖** ត្រឡប់ទៅការរៀបរាប់របស់លោក ដែលលោកបានរៀបរាប់ជូនសហព្រះរាជអាជ្ញាជាតិកាលពីម្សិលមិញ អំពីប្រជាជនដែលបានជម្លៀសពីភ្នំពេញ និងពីក្រុងតាកែវ។ លោកបានជម្រាបថាប្រជាជនរាប់ពាន់នាក់ត្រូវបានជម្លៀស ហើយលោកឃើញប្រជាជននៅគ្រប់ទីកន្លែង។ តើលោកបានឃើញប្រជាជនដែលគេជម្លៀសហ្នឹង លោកបានឃើញពីវត្តដែលលោកនៅនោះ ឬក៏លោកបានឃើញក្រោយពេលដែលលោកចាកចេញពីវត្តនោះហើយ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

[០៩:៤៥:១៣]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ប្រហែលជាខ្ញុំចងចាំមិនបានច្បាស់ទេ ប៉ុន្តែពីម្សិលមិញ សាក្សីរូបនេះបានឆ្លើយថា គាត់មិនបានឃើញការជម្លៀសនោះទេ។ គាត់បានឮគេនិយាយអំពីការជម្លៀសនេះដូច្នេះសំណួរនេះប្រហែលជាមិនត្រឹមត្រូវទេ។ នេះគឺអ្វីដែលខ្ញុំបានស្ដាប់ឮកាលពីម្សិលមិញ។ សូម

អរគុណលោកប្រធាន។

**លោក អាប់ឌុលឡាក់ ថារីក៖**

គឺខ្ញុំសាក្សីបានឆ្លើយបែបនេះមែន គឺគាត់និយាយដូចតទៅ ដោយរៀបរាប់អំពីការជម្លៀសប្រជាជន។ នេះគឺជាឃ្លា ដែលខ្ញុំបានដកស្រង់ពាក្យសម្តីរបស់សាក្សីដោយផ្ទាល់តែម្តង។ អ៊ីចឹងបានខ្ញុំសួរគាត់ថាតើគាត់បានឃើញដោយផ្ទាល់ ឬក៏យ៉ាងណានោះ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ខៀវ នៅ ខ្ញុំសូមថយក្រោយបន្តិច។ នៅពេលដែលលោកនៅជាលោកសង្ឃគង់នៅវត្តនោះ រហូតមកដល់ថ្ងៃ-- ដល់ខែមេសា ៧៥ ឬក៏ក្រោយពេលដែលលោកចាកចេញពីវត្តនោះហើយ តើលោកបានឃើញប្រជាជនដែលត្រូវបានជម្លៀសចេញពីភ្នំពេញ ឬតាកែវដែរឬទេ?

**លោក ខៀវ នៅ៖**

**ឆ៖** ឃើញចេញតាំងពីខ្ញុំមិនទាន់សឹក មិនទាន់លាចាក។ វាចេញមកមុនខ្ញុំលាចាក។ ហើយអ្នកដដែលហ្នឹង គឺដល់លាចាកហើយ ក៏នៅតែឃើញទៀត។ ប៉ុន្តែបានឃើញពីមុន មុនលាចាកសិក្ខាបទបាទ។

**ស៖** លោកបានជម្រាបជូនតុលាការថា គឺខាងផ្នែកឃុំ និងស្រុកគឺបានស្នើសុំឱ្យលោកស្នាក់នៅពេទ្យមូលដ្ឋាន។ តើលោកដឹងថា អ្នកណាជាអ្នកទទួលខុសត្រូវ ទទួលគ្រប់គ្រងទៅលើប្រជាជនដែលគេជម្លៀសចេញពីក្រុងតាកែវ និងភ្នំពេញដែរឬទេ?

**ឆ៖** មិនបានដឹងទេ។ ព្រោះច្រើនពាក្យថា អង្គការៗ ដូច្នេះមិនចេញឈ្មោះបុគ្គលណាមួយៗទេ។ គណៈស្រុក ខេត្ត វាមានហ្នឹងហើយ ប៉ុន្តែច្រើនសួរទៅ ប្រើពាក្យអង្គការ។

[០៩:៤៨:៣០]

**ស៖** ពីម្សិលមិញលោកបានជម្រាបជូនតុលាការថា ប្រជាជនដែលគេជម្លៀសជាច្រើនគឺបានធ្វើដំណើរទៅកាន់ស្រុកកំណើតរបស់ពួកគាត់។ តាមដែលលោកដឹង ថាតើមានការណែនាំណាឱ្យប្រជាជនត្រូវតែធ្វើដំណើរទៅកាន់ទីណា ទីណានោះដែរឬទេ? ឬក៏ថាប្រជាជនអាចសម្រេចចិត្តធ្វើដំណើរទៅទីណាក៏បានតាមបំណងរបស់គាត់?

**ឆ៖** ឯកំពុងធ្វើដំណើរហ្នឹង មិនឃើញ មិនឮថាម៉េចៗទេ។ ប៉ុន្តែថ្ងៃក្រោយមក រៀបចំយ៉ាងម៉េចៗ ឱ្យទៅនៅណា នៅណាហ្នឹង អាហ្នឹងខ្ញុំមិនបានដឹងល្អិតទៅទៀតទេ។ ប៉ុន្តែពេលធ្វើដំណើរហ្នឹង

គឺទៅតាមសេរី តាមទំនើងចិត្ត តាមស្ម័គ្រចិត្ត។

**សៈ** ពីម្សិលមិញលោកជម្រាបថា ថ្នាក់ភូមិ និងឃុំ គឺបានទទួលប្រជាជន-- ទទួលអ្នកភៀសខ្លួននោះ គឺរួមទាំងល្ខោបផងដែរ។ តើល្ខោបនោះ ដែលមកទទួលប្រជាជននោះ គឺជាល្ខោបដដែល ដែលឲ្យលោកសង្ឃហ្នឹង គឺថាឲ្យលោកសង្ឃត្រូវតែលាចាកសិក្ខាបទ ជាក្រុមដដែល ឬក៏ផ្សេងគ្នា?

**ឆៈ** ត្រង់នេះ ខ្ញុំមិនបានឃើញផ្ទាល់ទេ គ្រាន់តែឮតៗគ្នា។ ព្រោះគ្នាច្រើន អត់មានចំណាំមុខចាំមុខអីចេះអីចុះទេ គ្រាន់តែឮថា អង្គការឲ្យលាចាក គឺនាំគ្នារៀបចំប្រញាប់តែម្តង។ អត់បានទៅអាល័យតែរកមុខរកមាត់អ្នកនេះអ្នកនោះទេ។ តែចេញឈ្មោះអង្គការ ត្រូវតែប្រញាប់។

**សៈ** ពីម្សិលមិញលោកបានជម្រាបថា លោកបានឃើញសាច់ញាតិរបស់លោកខ្លះ ដែលត្រូវបានគេជម្លៀសខ្លួនដែរ។ លោកបានជម្រាបថា លោកបាននិយាយទៅកាន់ពួកគាត់អំពីការធ្វើដំណើរនោះ តើពួកគាត់នោះ សាច់ញាតិរបស់លោកនោះ មានបានប្រាប់មកលោកវិញទេ ថាហេតុអីបានជាពួកគាត់ត្រូវចាកចេញពីទីក្រុង?

**ឆៈ** សួរទៅថា ពួកទាហានដែលវ៉ៃចូលក្រុងហ្នឹង វ៉ៃដល់ណា ប្រាប់ឲ្យថយ-- វ៉ៃចូលដល់ណាប្រាប់ឲ្យថយ។ អាហ្នឹងអ្នកភ្នំពេញនិយាយអ៊ីចឹងតែម្តង "ត្រូវតែថយចេញទៅក្រៅ អត់ឲ្យនៅទេ"។

[០៩:៥២:០៥]

**សៈ** តើសាច់ញាតិរបស់លោកនោះធ្វើដំណើរទៅកាន់ទីណាដែរ?

**ឆៈ** ទៅស្រុកកំណើតរបស់ខ្លួនហ្នឹង ទៅត្រពាំងធំហ្នឹង។ ខ្លះមកពីភ្នំពេញ ខ្លះមកពីតាកែវ។

**សៈ** ក្រោយពេលប្រជាជនធ្វើដំណើរទៅកាន់ស្រុករបស់ពួកគាត់ តើពួកគាត់នៅបន្តរស់នៅជួបជុំគ្រួសារដែរឬក៏យ៉ាងណា?

**ឆៈ** តមកក្រោយមក ខ្ញុំអត់នៅក្នុងស្រុកក្នុងឃុំទេ ប៉ុន្តែខ្ញុំទៅលេងភូមិម្តងៗឃើញបងប្អូនដែលទៅពីក្រុង ទៅថ្មីហ្នឹង គេរៀបចំភូមិឲ្យនៅរួមគ្នាជាមួយគ្នា។

**សៈ** ពីម្សិលមិញលោកបានជម្រាបជូនសហព្រះរាជអាជ្ញាទៀតថា ពេលខ្លះនៅពេលមួយនោះ គឺថាសហករណ៍ត្រូវបានគេបង្កើតឡើង តើសហករណ៍ទាំងនេះគេបង្កើតឡើងនៅក្នុងបណ្តាភូមិដែលលោកទើបជម្រាបអម្បាញ់មិញ ឬក៏យ៉ាងណា?

**ឆៈ** នៅក្នុងភូមិខ្ញុំហ្នឹងក៏ធ្វើសហករណ៍ ប៉ុន្តែខ្ញុំមិនបាននៅរួមសហករណ៍នឹងគេទេ ព្រោះខ្ញុំចេញពីភូមិទៅហើយ ប៉ុន្តែពេលទៅភូមិម្តងៗ បានៗដឹងថាគេរួមគ្នាធ្វើសហករណ៍។

**សៈ** តើមានអ្នកណាម្នាក់ដែលមកពីភូមិរបស់លោក រស់នៅក្នុងសហករណ៍នេះ ឬក៏យ៉ាងណា? តើប្រជាជនទាំងអស់រស់នៅក្នុងសហករណ៍នេះ ឬក៏មានអ្នកភូមិខ្លះពីភូមិរបស់លោករស់នៅសហករណ៍នេះដែរ?

**ឆៈ** សូមលោកបញ្ជាក់ម្តងទៀត។

**សៈ** ជាការពិតហើយ ខ្ញុំអាចជម្រាបបាន គឺថាលោកថាមានការបង្កើតសហករណ៍។ តើម្នាក់ៗមក-- ប្រជាជនទាំងអស់ភូមិរបស់លោក ត្រូវរស់នៅក្នុងសហករណ៍នេះ ឬក៏ប្រជាជនខ្លះរស់នៅកន្លែងផ្សេង ដោយមិនរស់នៅសហករណ៍ទាំងអស់ទេ?

**ឆៈ** ពួកមន្ទីរ ពួកអង្គភាព ពួកក្រសួងមន្ទីរ អាហ្នឹងនៅដោយឡែក។ ឯប្រជាជននៅតាមភូមិ គឺនៅតាមសហករណ៍។

[០៩:៥៦:២៦]

**សៈ** តើប្រជាជនធ្វើអ្វីនៅក្នុងសហករណ៍ទាំងនេះ? តើពួកគាត់មានការងារធ្វើទេ ហើយបើមានហ្នឹង តើលោកដឹងថា គាត់ធ្វើការងារអ្វីដែរ?

**ឆៈ** ធ្វើហ្នឹង វាអត់មានធ្វើអីប្លែកទេ ធ្វើស្រែ ធ្វើចម្ការ ធម្មតាហ្នឹង គ្រាន់តែធ្វើរួមគ្នា។ ដដែលហ្នឹង ការងារដដែលរកស៊ីជីវិតអី ធ្វើស្រូវ ធ្វើអង្ករ ដំណាំដាំដុះ កាប់គាស់ ដដែលៗហ្នឹងទេ។ គ្រាន់ថារួមវាលក្ខណៈជារួមគ្នា។

**សៈ** តាមដែលលោកដឹង តើប្រជាជនអាចសម្រេចចិត្តដោយខ្លួនឯង ថាមិនរស់នៅក្នុងសហករណ៍បានទេ?

**ឆៈ** បើដឹង ក៏ដឹងក្នុងស្ថានដែរ ប៉ុន្តែៗវាអត់មានឃើញពីណារស់នៅក្រៅសហករណ៍។ បើថាពួកមន្ទីរ ពួកក្រសួង អាហ្នឹងនៅក្រៅ។ ឯម្នាក់ឯងម៉េចបានៅ។ បើនេះ មានកង មានក្រុម មានមេមានមេភូមិ មានមេក្រុម។

[០៩:៥៨:១២]

**សៈ** ចំពោះប្រធានទាំងអស់ហ្នឹង ដែលទទួលខុសត្រូវលើឃុំ តើលោកស្គាល់ ថាតើអ្នកណាជាអ្នកតែងតាំងប្រធានឃុំទាំងអស់ហ្នឹងបាទ?

**ឆៈ** ក្នុងពេលនោះ អត់មានចេញឈ្មោះថានេះនោះទេ គឺកំណត់ថាអង្គការតែងតាំង អង្គការចាត់តាំង បាទ។ ទៅលើទៅទៀត ក៏ឮសូរតែអង្គការចាត់តាំង អង្គការតែងតាំងអីចឹងមក។

**ស៖** នៅក្នុងតំបន់មូលដ្ឋានរបស់លោក តាមដែលលោកចាំនោះ តើមានការប្រកាសអ្វីដែរឬទេ ដែលនិយាយអំពីការកែប្រែជីវភាពរស់នៅរបស់ប្រជាជន ដូចថាពីរស់ធម្មតា ទៅជាសហករណ៍ជាដើមហ្នឹង?

**ឆ៖** ការនិយាយ ការអប់រំនោះវាមានហើយ អារបៀបរួមគ្នា របៀបសមូហភាព យកចំណេញយ៉ាងម៉េចៗ គឺមាននិយាយ អប់រំ រៀនសូត្រ ប្រជុំ។ អាហ្នឹងមាន។ ប្រជុំកសាងគ្នា ទិតៀន ស្វ័យទិតៀន អាហ្នឹងមានហើយ។ ធ្វើការចម្រើន មិនចម្រើនយ៉ាងណាៗ មានរៀនមានសូត្រ។

**ស៖** ចាតើការប្រជុំនោះគេប្រជុំញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ខ្ញុំមិនចាំថាកំណត់ខែ កំណត់ថ្ងៃទេ ប៉ុន្តែឃើញប្រជុំហ្នឹងញឹក។ បើលោកសង្ឃប្រជុំដែរវាមានកំណត់កន្លះខែម្តង សង្គមសង្ឃ ឯសង្គមខាងហ្នឹងគឺមិនបានកំណត់ថាប៉ុណ្ណេះថ្ងៃប៉ុណ្ណោះថ្ងៃ អត់ទេ។ មិនដូចក្នុងសង្គមលោកសង្ឃ គេមានកំណត់។ ថ្ងៃពេញបូណ៌ថ្ងៃដាច់ ប្រជុំធ្វើឧបោសថ អាហ្នឹងទៀងទាត់អ៊ីចឹងតែម្តង។ ឯខាងនោះអត់មានដាក់ថ្ងៃថាយ៉ាងនេះយ៉ាងនោះ ប៉ុណ្ណេះថ្ងៃម្តងប៉ុណោះថ្ងៃម្តងអត់ទេ។ ប៉ុន្តែ-- ប្រជុំដកពិសោធន៍ការងារ ការងារធ្វើកន្លងមកហើយ តើមានចំណុចខ្វះខាតខ្លាំងខ្សោយត្រង់ណា អាហ្នឹងប្រជុំអ៊ីចឹង។

[១០:០១:៤៣]

**ស៖** តើអ្នកណាជាអ្នកអធិបតីនៅក្នុងអង្គប្រជុំទាំងអស់នោះ បាទន័យថាជាអ្នកនិយាយបាទ?

**ឆ៖** ក្នុងការនិយាយនេះ គឺបើក្នុងភូមិ គឺមេភូមិហ្នឹងហើយ ក្នុងក្រុមមេក្រុម បើឃុំមេឃុំ។ ឯក្នុងប្រជុំហ្នឹងគឺ អាហ្នឹងហើយយើងសំដៅយកហ្នឹងតែម្តង។ ហើយយកមែនទែន ស្រេចអង្គការកំណត់ឲ្យ អ្នកណាត្រូវប្រជុំ អ្នកហ្នឹងទៅៗ។

**ស៖** តើលោកចាំដែរឬទេ ឬក៏លោកដឹងដែរឬទេថាតើចំពោះមនុស្ស ដែលធ្វើការក្នុងរបបមុនដូចជាថាអាជ្ញាធរមូលដ្ឋាននៅត្រាំកក់ ក្រោយពីខែមេសា-- ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ មក ថាតើអ្នករាជការចាស់នោះយ៉ាងម៉េចដែរបាទ?

**ឆ៖** រាជការចាស់ហ្នឹងខ្លះនៅរស់ទាល់ឥឡូវនេះ។ មួយស្រុករគ្នានឹងខ្ញុំ ធ្វើអាចារ្យវត្តត្រពាំងធំរាល់ថ្ងៃ ធ្វើទាហានហ្លួងពីដើម។ ហ្នឹងអ្នកដែលស្គាល់ច្បាស់ ធ្លាប់បួស ធ្លាប់រៀនជាមួយគ្នា។ ហើយមាននៅឃើញខ្លះ ក៏អត់ឃើញ-- ខ្លះក៏បាត់អត់ឃើញមកដល់ស្រុកវិញ។ សួរបងប្អូនទៅថា មិនដឹងទៅឯណាចេញពីភ្នំពេញ បែកគ្នា បាទ។

[១០:០៣:៤៥]

**សៈ** ថាតើគេបានបំបែកពួកគេទេ ឬក៏គេសុខចិត្តបែងចែកទៅនៅកន្លែងផ្សេងដោយខ្លួនគេបាទ?

**ឆៈ** ពេលហ្នឹងសួរបងប្អូនថា បាត់អ្នកនេះបាត់អ្នកនោះ ថាទេទៅតាមពួកម៉ាកទៅនេះទៅនោះហើយ ហើយឃើញបាត់រហូតអត់ឃើញទៅស្រុក អាហ្នឹងអ្នកនៅជិតស្រុកហ្នឹង។ មួយនែ៎ឈ្មោះ ស៊ូ ណែម *អាគ្រីហ្សេ*ពទ្យ ទៅរៀននៅប៉ារីសបីឆ្នាំ។ ទៅឃើញតែប្អូនៗ បងៗ ដល់ ណែម ហ្នឹងអត់ឃើញ សួរទៅថាទៅតាមពួកម៉ាកទៅខេត្តកំពង់ស្ពឺ ហើយលុះតែឥឡូវអត់ឃើញ។ មិនដឹងម៉េចវាអាហ្នឹង មិនដឹងទេ ប៉ុន្តែគ្រាន់ថាមិនឃើញ។

**សៈ** សំណួរចុងក្រោយនៅលើប្រធានបទនេះ។ នៅក្នុងចន្លោះពេលនោះ និងរហូតមកដល់ពេលនេះ តើលោកបានឮព័ត៌មានអ្វីបន្ថែម អំពីបញ្ហាអ្វីដែលកើតឡើង ចំពោះពួករដ្ឋការសម័យមុន ដែលបាត់ខ្លួនក្នុងសម័យខ្មែរក្រហម តើលោកបានដឹង បានឮអ្វីដែរទេ?

[១០:០៥:២២]

**ឆៈ** ក្នុងការដឹងឮ ដូចជាមនុស្សរាប់លានអ៊ីចឹង ក្នុងស្រុកខ្មែរទាំងមូល គេឮយ៉ាងម៉េច ខ្ញុំក៏ឮតាមគេអ៊ីចឹង ព្រោះគេនិយាយពេញដី តាមឮដែលគេនិយាយពេញដី មិនមែនតាមដោយយកការណ៍ពីនេះពីនោះទេ។ និយាយតៗគ្នាមកពេញស្រុកខ្មែរ ក៏ឮដូចតែគេអ៊ីចឹង អត់មានរឿងអី ឮជាងគេទេ បាទ។ បើខ្លួនកាន់តែចាស់ហើយ មានទៅដើរសន្សំរឿងអីច្រើន ហើយសុខភាពខ្សោយផង ហើយមួយទៀតចាស់ហើយទើបនឹងមានកូនខ្ចី បានអីទៅរវល់ដើរសន្សំរឿងក្រៅ។ ខំតែជីវភាពក្នុងគ្រួសារ ហើយយើងអ្នកកាន់សីលផង ដើរសន្សំរឿងច្រើន សន្សំបាបកាន់តែច្រើន។

**ប្រធានអង្គជំនុំៈ**

អរគុណណាស់សាក្សី ហើយសូមសាក្សីផ្តង់អារម្មណ៍ ហើយឆ្លើយតបទៅនឹងសំណួរ ដែលសួរដោយភាគី ហើយសូមសួរ-- ឆ្លើយតបនឹងសំណួរកម្រិត ដែលសួរបានហើយ ដើម្បីបង្កើនពេលវេលាក្រែងលោដំណើរការសវនាការ ស្តាប់សក្ខីកម្មរបស់លោកបានចប់ថ្ងៃនេះ អាចនឹងវិលត្រឡប់ទៅជួបប្រពន្ធកូនវិញ។ ប្រសិនបើលោកចេះតែពេលវេលា និយាយនូវអ្វីដែលមិនចាំបាច់ នោះវានឹងអាចធ្វើឲ្យពេលវេលាវែង អាចអូសដល់ទៅស្អែកទៀត អាចជាការប៉ះពាល់នូវជីវភាពរស់នៅប្រចាំថ្ងៃរបស់លោកជាមួយនឹងគ្រួសាររបស់លោកដែរ។ អ៊ីចឹង ខិតខំផ្តង់អារម្មណ៍ ដើម្បីឆ្លើយតបទៅនឹងសំណួរដែលសួរ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា បន្តការតាំងសំណួរ!

[១០:០៧:៣០]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ខៀវ នៅ ឥឡូវនេះ យើងត្រឡប់ទៅសំណួរមួយ គឺការប្រជុំដែលគេប្រជុំធ្វើការអប់រំ រៀនសូត្រ ដែលលោកនិយាយថា មានការទិតៀន ស្វ័យទិតៀននោះ។ តាមអ្វីដែលលោកចាំថាតើមានឯកសារ ឬក៏មានទស្សនាវដ្ដីអីគេប្រើ ដើម្បីអប់រំប្រជាជន ឬក៏ផ្សព្វផ្សាយអំពីសីលធម៌រស់នៅ ជីវិតរបស់បដិវត្តន៍នោះដែរឬទេ?

**លោក ខៀវ នៅ៖**

**ឆ៖** ឯកសារមាន។ សូមជម្រាបដោយខ្លី។

**ស៖** តើលោកចាំទេ ឯកសារហ្នឹងមានប្រភេទអ្វីខ្លះ?

**ឆ៖** នឹកមិនទាន់ឃើញទេ ព្រោះឯកសារច្រើន ហើយខានគិតយូរ។

**ស៖** បើខ្ញុំប្រាប់ឈ្មោះ ឯកសារហ្នឹង គឺគេហៅថា "ទស្សនាវដ្ដីទង់បដិវត្ត" តើគេប្រើឯកសារហ្នឹងដែរឬទេ នៅក្នុងវគ្គរៀនសូត្រនោះ?

[១០:០៩:១០]

**ឆ៖** ទង់បដិវត្តឮសូរតែក្នុងបទចម្រៀង ឯឯកសារសម្រាប់ប្រជាជន ដូច-- និយាយចូលហើយ ប៉ុន្តែចេញជាឯកសារ ដូចមិន-- ដឹងម៉េចទេ ខ្ញុំភ្លេចភ្លាំងហើយ។

**ស៖** សំណួរមួយចុងក្រោយ ទាក់ទងទៅនឹងបញ្ហានេះ គឺទាក់ទងនឹងការប្រជុំ និងការរៀនសូត្រនេះ។ តាមអ្វីដែលលោកដឹង បាទនៅក្នុងសម័យកាលនោះ តើគេឲ្យប្រជាជនសរសេរប្រវត្តិរូបផ្ទាល់ខ្លួនទេ?

**ឆ៖** ប្រជាជនទូទៅខ្ញុំដឹងមិនដល់ទេ ប៉ុន្តែបើអ្នកធ្វើការមានធ្វើប្រវត្តិរូប ឲ្យធ្វើប្រវត្តិរូប។

**ស៖** តើគេឲ្យលោកធ្វើប្រវត្តិរូបដែរឬទេ?

**ឆ៖** ខ្ញុំមិនឃើញឲ្យធ្វើប្រវត្តិរូបអីវែងឆ្ងាយទេ។ មិនឃើញឲ្យធ្វើទេ ព្រោះគេស្គាល់ច្រើនគ្នាហើយ បើក្មេងៗទើបនឹងចូលអាហ្នឹងគេធ្វើ ហើយយើងចាស់អ្នកស្រុកស្គាល់មកយូរហើយ។

**ស៖** តាមអ្វីដែលលោកសង្កេត តើលោកដឹងពីមូលហេតុនៃការស្នើការសុំឲ្យប្រជាជនធ្វើប្រវត្តិរូបនោះដែរឬទេ?

[១០:១១:២២]

ឆ៖ មូលហេតុជាផ្លូវការ ខ្ញុំអត់បានដឹងទេ។

ស៖ ថាតើក្រោយពីប្រវត្តិរូបហ្នឹងគេរៀបចំរួច តើគេបញ្ជូនទៅខាងណាដែរ?

ឆ៖ មិនដឹងថា ខាងណាៗទេ ដូចខ្ញុំបញ្ជាក់ខាងដើមថា ឲ្យទៅអង្គការ ជូនទៅអង្គការ។

ស៖ សូមអរគុណ។ ឥឡូវនេះខ្ញុំសូមត្រឡប់ទៅរកជីវិតរបស់លោក ហើយនិងការផ្លាស់ប្ដូរទីកន្លែង ហើយលោកនិយាយថា អ្នកឃុំ អ្នកស្រុក-- នៅថ្នាក់ស្រុកហ្នឹងគឺឲ្យលោកនៅធ្វើការជាមួយមន្ទីរពេទ្យមួយ តើលោកនៅនឹកឃើញទេថា តើអ្នកដែលនៅក្នុងថ្នាក់ឃុំ ថ្នាក់ស្រុកដែលប្រាប់ឲ្យលោកទៅធ្វើការនៅមន្ទីរពេទ្យនោះ។ តើមានឈ្មោះអ្វីខ្លះ?

[១០:១២:៥៥]

ឆ៖ សុទ្ធចាស់ៗអស់ហើយ ស្លាប់អស់ហើយ។ ឃុំក៏ស្លាប់ ហើយស្រុកក៏ស្លាប់ក្នុងសង្គ្រាម។ ស្លាប់ហើយ គឺថ្នាក់ប្រធានៗស្លាប់។

ស៖ ឥឡូវត្រឡប់មកថ្នាក់ស្រុកវិញម្ដង តើលោកនៅចាំដែរឬទេ អ្នកណាដែលស្ថិតនៅក្នុងគណៈស្រុកនោះ នៅក្នុងឆ្នាំ១៩៧៥ នៅពេលដែលលោកនៅទីនោះ?

ឆ៖ ឈ្មោះ គិត, ឈ្មោះ ចាយ ប៉ុន្តែស្លាប់អស់ហើយ។ ហើយតាចាយ បើនៅឥឡូវហ្នឹងជិត ១០០ហើយអាយុនោះ។ ហើយ គិត បើនៅឥឡូវហ្នឹងប៉ែតសិបលើ ប៉ុន្តែស្លាប់អស់ហើយ។ ហើយក្មេងក៏ស្លាប់ដែរ ស្លាប់ក្នុងសមរភូមិ ឈ្មោះ ញ៉ែវ ក្នុងហ្នឹងដែរ។

ស៖ នៅពេលដែលលោកនិយាយថា គិត តើឈ្មោះ ព្រាប គិត ហ្នឹងមែនឬទេ? បាទ សូមលោកអញ្ជើញឆ្លើយ ខ្ញុំចង់ឲ្យលោកបំភ្លឺដែលលោកថា គិត ហ្នឹងគឺឈ្មោះ ពេញរបស់គាត់នោះឈ្មោះ ព្រាប គិត ដែរឬទេ?

[១០:១៤:៥១]

ឆ៖ ព្រាប គិត។

ស៖ សូមអរគុណ។ តើសមាជិកនៃក្រុមគ្រួសារ តាម៉ុក នៅក្នុង មានអ្នកណាម្នាក់នៅក្នុងគណៈកម្មការស្រុក នៅក្នុងស្រុករបស់លោកទេបាទ?

ឆ៖ មានប្អូន តាម៉ុក ធ្វើឃុំ ប៉ុន្តែស្លាប់ហើយ។ ស្លាប់អស់ហើយ អត់មាននៅទេ ដែលធ្វើការហ្នឹង។

[១០:១៦:០៤]

**សៈ** សូមអរគុណ។ តើលោកនៅចាំឬទេ? តើតំបន់ណាត្រាំកក់ ស្រុកត្រាំកក់នៅក្នុងតំបន់អ្វីដែរ?

**ឆៈ** នៅក្នុងតំបន់១៣។

[១០:១៦:៥០]

**សៈ** តើមានគណៈកម្មាធិការនៅក្នុងតំបន់ហ្នឹងដែរឬទេ?

**ឆៈ** គណៈកម្មការយ៉ាងម៉េច? សូមសួរបញ្ជាក់ម្តងទៀត។

**សៈ** បាទ ខ្ញុំសួរឡើងវិញ។ លោកបាននិយាយពីខាងដើមថា មានគណៈកម្មាធិការដែលទទួលបន្ទុកនៅថ្នាក់ស្រុក ហើយគណៈកម្មាធិការនៅថ្នាក់ឃុំ ហើយខ្ញុំសួរលោកថា តើតំបន់មានគណៈ-កម្មាធិការរបស់គេដែរឬទេ?

**ឆៈ** គណៈកម្មការតំបន់មាន។

**សៈ** លោកបានឆ្លើយកាលពីម្សិលមិញថា តាម៉ុក ធ្លាប់ធ្វើជាលេខានៃភូមិនិរតី។ តាមអ្វីដែលលោកដឹងនោះ តើមនុស្សដែលមិនពីគណៈតំបន់ត្រូវរាយការណ៍ទៅឲ្យ តាម៉ុក ឬក៏ធ្វើការនៅក្រោម តាម៉ុក ដែរឬទេ?

**ឆៈ** ដឹងថាលេខាតំបន់ មិនដឹងជាផ្លូវការច្បាស់លាស់ទេ។ គ្រាន់តែឮតៗមកទេ មិនមែនដឹងពីគល់បញ្ជើមកទេ។ ខាងលើមិនដឹងជាយ៉ាងម៉េចទេ មិនបានដឹងដល់ទេ។ ប៉ុន្តែខាងក្រោម ចេះតែនាំគ្នានិយាយទៅ ដឹងហ្នឹង ដឹងពីចុងមកទេ មិនដឹងពីគល់មកទេបាទ។

**សៈ** បាទ ឥឡូវនេះ យើងនឹងត្រឡប់ទៅនិយាយអំពីជីវិតរបស់លោកដែលយើងបានពិភាក្សាខាងដើម នៅពេលដែលលោកទៅ ហើយបានធ្វើការ ឬក៏នៅមន្ទីរពេទ្យមួយ។ តើលោកនៅមន្ទីរពេទ្យហ្នឹងអស់រយៈពេលប៉ុនណាដែរ? ហើយគេឲ្យលោកធ្វើអ្វីនៅកន្លែងមន្ទីរពេទ្យនោះ?

[១០:១៩:២៧]

**ឆៈ** ទៅហ្នឹងរយៈកាលរាប់ថ្ងៃអីទេ មិនយូរប៉ុន្មានទេ យ៉ាងច្រើនរាប់អាទិត្យប៉ុណ្ណឹង។ មិនដល់រាប់ខែ រាប់ឆ្នាំទេ រយៈកាលខ្លី មិនទាន់បានធ្វើអីច្បាស់លាស់ផង ព្រោះខ្ញុំឈឺ។

**សៈ** បន្ទាប់ពីលោកចេញពីមន្ទីរពេទ្យនោះទៅ តើលោកទៅកន្លែងណាទៀត?

**ឆៈ** ទៅនៅជិត តាម៉ុក។

**សៈ** តើ តាម៉ុក ឲ្យលោកទៅនៅជិតគាត់ហ្នឹងដែរឬទេ?

 E1/90.1

**ឆ៖** ហៅឲ្យទៅនៅជិត។

**ស៖** តើគាត់ហៅឲ្យលោកទៅនៅជិតគាត់ហ្នឹងហៅដោយរបៀបណា? គេមកប្រាប់ផ្ទាល់ ឬក៏លោកទៅជួបគាត់ គាត់ប្រាប់ដោយផ្ទាល់? បាទសូមពន្យល់ខ្ញុំផង។

**ឆ៖** ប្រាប់ទៅប្រធានគណៈកម្មាធិការខេត្តឈ្មោះ សោម ហើយ សោម ប្រាប់ដល់ខ្ញុំ។ ប៉ុន្តែប្រធានហ្នឹងស្លាប់ដែរហើយ តាំង៧៩ ឯណោះ។

**ស៖** តើ សោម ហ្នឹងជាលេខាតំបន់១៣ ហ្នឹងឬ?

**ឆ៖** បែបជាប្រធានហ្នឹងហើយ។ ប៉ុន្តែស្លាប់។

[១០:២១:៥៧]

**ស៖** តើលោកភ្ញាក់ផ្អើលទេ ដែល តាម៉ុក ហៅឲ្យលោកទៅនៅជិតគាត់នោះ? តើលោកមានការភ្ញាក់ផ្អើល ឬក៏អារម្មណ៍ដូចម្តេច?

**ឆ៖** ហៅទៅហ្នឹងគាត់ ដល់មកដល់គាត់ប្រាប់ថា ឲ្យពួកហ្នឹងមកជួយកាន់លុយ ជួយ-- ខ្ញុំថាម៉ាអាយុសខ្ញុំ បើឲ្យធ្វើអីៗមិនសូវខ្លាចទេ ខ្លាចបំផុតអារឿងលុយហ្នឹង ខ្លាចបាត់ ខ្លាចបង់ ខ្លាចអីហ្នឹង។ “អ្ហែ! មានតែធ្វើអីម្នាក់ឯង មានគ្នាច្រើនដែរ” គាត់គ្រាន់តែប្រាប់ប៉ុណ្ណឹង។ ប៉ុន្តែអត់បានកាន់បានធ្វើទេអាហ្នឹង សូមបញ្ជាក់ទៀត។ ព្រោះអត់ចាយលុយ ក៏ចប់ហ្នឹងទៅ។

**ស៖** តើលោកបានទៅជួប តាម៉ុក នោះជួបនៅកន្លែងណា?

**ឆ៖** ជួបនៅជិតកំពង់កន្ទួត កន្លែងគាត់នៅកន្លែងវត្តចាស់មួយ ហៅវត្តស្លារង ក្បែរស្ទឹងកន្ទួតហ្នឹង។

**ស៖** តើកន្លែងនោះគាត់មានមន្ទីរ ឬក៏ជាផ្ទះរបស់គាត់?

**ឆ៖** កន្លែងហ្នឹងពីដើមវាកន្លែងបន្ទាយ។ ទៅនៅហ្នឹងដីបន្ទាយហ្នឹង វាទំនេរច្រើន គាត់ឲ្យគេឈូសសាមីន សាអី ហើយដាំដើមចេក ដាំចេក។ ឲ្យពួកទាហានពួកអីទៅជួយដាំចេកពេញត្រង់ហ្នឹង។ កន្លែងវាទំនេរ ហើយក្បែរមាត់ទឹក។ មិនមែនគាត់នៅពីដើមនោះទេ កន្លែងហ្នឹងកន្លែងៗទាហានលន់ នល់ពីដើមមក។

[១០:២៤:១២]

**ស៖** ដើម្បីឲ្យខ្ញុំយល់ច្បាស់អំពីពេលវេលា នៅកាលនោះ តើរឿងហ្នឹងកើតឡើងនៅក្នុងឆ្នាំ១៩៧៥ ឬ? តើលោកនៅចាំទេ នៅក្នុងខែណា?

**ឆ៖** ប្រហែលជាហួស៧៥ មកដល់៧៦ ហើយ ហើយក៏ចុង៧៥។

**ស៖** ឥឡូវនេះលោក ៗមិនបានកាន់លុយនោះទេ ដូចដែលលោកបានបញ្ជាក់។ តើគេឲ្យធ្វើការងារអ្វីនៅកន្លែងកំពង់កន្ទួតនេះ?

**ឆ៖** អត់បានធ្វើការងារអីទេ គ្រាន់តែវាមានរបស់របរតូចស្រាលៗ ក៏ជួយរាប់ ជួយមើលគេក្រៅទៅ។ ឯពួកទាហានមកកាប់ដីដាំចេកហ្នឹង រង្គោះចប រង្គោះអី គ្រាន់តែធ្វើស្នៀតចបឲ្យគេហ្នឹង។ មិនទាន់បានធ្វើអីធំដុំទេ។

**ស៖** តើ តាម៉ុក នៅកន្លែងហ្នឹងទេ ដែលនៅពេលដែលលោកធ្វើការរៀបចំរបស់តូចតាចហ្នឹងនៅកំពង់កន្ទួត តាម៉ុក នៅជាមួយហ្នឹងដែរឬទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** បាទ សូមអភ័យទោស សូមលោកឆ្លើយម្តងទៀង ពីព្រោះមីក្រូហ្វូនអត់បានបើក អត់ឮ។

**ឆ៖** សូមអត់ទោស ខ្ញុំអត់បានមើលភ្លើង។ តាម៉ុក នៅជិតគ្នាហ្នឹងដែរ នៅមន្ទីរជាប់ជាមួយគាត់ហ្នឹង។

[១០:២៦:៤៣]

**ស៖** តើលោកបានឃើញមេដឹកនាំ ឬក៏កម្មាភិបាលថ្នាក់ខ្ពស់ណាផ្សេងទៀត ក្រៅពី តាម៉ុក ទេនៅកំពង់កន្ទួតនេះ?

**ឆ៖** ឃើញ មានឃើញខាងតំបន់ ខាងស្រុកអី ទៅជួប ខាងកងពលអីមានទៅហូរហែ។

**ស៖** តើលោកដឹងទេ ហេតុអីបានជាពួកគាត់ហ្នឹងមកកំពង់កន្ទួត?

**ឆ៖** ការងារ តាម៉ុក គឺខាងត្បូងភ្នំពេញ ហើយគាត់ការងារខាងក្រៅ ខាងភូមិភាគ មិនមែនខាងក្រុងទេ។ ដូច្នេះ គ្រាន់តែមកនៅជិតក្រុង ព្រោះចប់សង្គ្រាមហើយ មកនៅជិតក្រុងស្រួលទាក់ទង។ រឿងគ្រាន់តែប៉ុណ្ណឹងទេ។

**ស៖** តើមានអ្នកណាមកពីភ្នំពេញទៅកន្លែងកំពង់កន្ទួតហ្នឹងដែរឬទេ គឺជាកម្មាភិបាលថ្នាក់ខ្ពស់ ខ្ញុំចង់សួរលោកពីរឿងហ្នឹង?

**ឆ៖** មានទៅ ទៅហ្នឹងច្រើនដែរមិនដឹងអ្នកណា ជាអ្នកណាទេ ព្រោះខ្ញុំទើបលាចាកសិក្ខាបទ មិនទាន់ស្គាល់មេអស់ណា។ ស្គាល់តែក្នុងលោកសង្ឃហ្នឹងច្រើន។ ហើយមកដល់មេខ្មែរក្រហមហ្នឹង មិនទាន់ស្គាល់មុខអស់ទេ។ បើឃើញទៅហូរហែច្រើន។

**ស៖** តើប៉ុល ពត នៅក្នុងចំណោមអ្នកដែលទៅនោះដែរឬទេ?

[១០:២៨:៥៨]

**ឆ៖** ដូចមិនឃើញទេ បើឃើញ ឃើញទៅឯតាកែវ។ ព្រោះផ្លាស់ពីហ្នឹង ទៅតាកែវ។ វាឃើញទៅតាកែវ-- ផ្លាស់ពីហ្នឹងទៅតាកែវ ឃើញ។ ឃើញតែមួយភ្លែតទេ មិនបានទៅ បាននៅហូរហែយូរទេ ជួបមួយភ្លែត បែកទៅទៀតទៅ។

**ស៖** តើកន្លែងដែលលោកបានឃើញ ប៉ុល ពត ទៅជួប តាម៉ុក នៅតាកែវនោះ ជួបនៅកន្លែងណាបាទ?

**ឆ៖** កន្លែងផ្ទះ តាម៉ុក ហ្នឹងតែម្តង។ តាម៉ុក នៅតាកែវហ្នឹង មានផ្ទះគាត់។ កាលហ្នឹង មិនដឹងជាមកពីណាទេ មកចូល ឆៀងចូលមកបន្តិច ហើយក៏បែកទៅទៀតទៅ។

**ស៖** តើលោកតែងតែនៅផ្ទះ តាម៉ុក ទេ នៅខេត្តតាកែវ ឬក៏លោកទៅកន្លែងហ្នឹងញឹកញាប់ដែរឬទេ?

**ឆ៖** ខ្ញុំនៅជិតហ្នឹង។ ខ្ញុំនៅជិតផ្ទះ តាម៉ុក ហ្នឹង។

**ស៖** សូមអរគុណ។ តើលោកនៅជាមួយ តាម៉ុក រយៈពេលប៉ុន្មានដែរនៅកន្លែងហ្នឹង?

**ឆ៖** នៅមិនយូរប៉ុន្មានទេ។ ដាក់កំណត់ច្បាស់លាស់ជាជើងលេខ មិនបានច្បាស់ទេ គ្រាន់ប្រហែលៗ ព្រោះមិនបានកត់ត្រា ហើយក៏ត្រូវចេញពីហ្នឹងមកទៀត។

[១០:៣០:៥៨]

**ស៖** តើលោកទៅណាបន្ទាប់ពីលោកចាកចេញពីតំបន់ ដែលលោកធ្វើការជាមួយ តាម៉ុក ទៅនោះ?

**ឆ៖** គាត់ឱ្យទៅនៅខាងពាណិជ្ជ ហៅថា ពាណិជ្ជដឹកជញ្ជូន មិនមែនលក់ដូរទេ គ្រាន់តែដឹកជញ្ជូនអីវ៉ាន់ចេញទៅក្រៅ ប៉ុន្តែដាក់អក្សរថា ពាណិជ្ជ ភូមិភាគនិរតី។

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណ។ លោកប្រធាន ឥឡូវនេះខ្ញុំនឹងចាប់ផ្តើមប្រធានបទថ្មី ប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំចង់ចាប់ផ្តើមប្រធានបទនេះបន្ទាប់ពីសម្រាកបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា វាជាការចាំបាច់ចំពោះប្រតិចារឹក ក្នុងការបញ្ជាក់ឲ្យបានច្បាស់ថា សួរអំពីអ្នកណា? នៅពេលសាក្សីនិយាយអំពីទស្សនកិច្ច នៅក្នុងផ្ទះរបស់ តាម៉ុក ពីព្រោះថាជាភាសាបារាំងស្ដាប់មិនដឹងទេថា អ្នកណាទៅលេង តាម៉ុក នៅផ្ទះគាត់នៅតាកែវនោះ។ ដូច្នេះ សូមឲ្យបញ្ជាក់ឲ្យបានច្បាស់ ថាតើអ្នកដែលទៅតាកែវ ទៅផ្ទះ តាម៉ុក ហ្នឹងជាអ្នកណា?

[១០:៣២:៤០]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកចៅក្រម ឡាវែន៍។ ហើយសូមអនុញ្ញាតលោកប្រធានសួរទៅសាក្សី។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ខៀវ នៅ តើលោកស្ដាប់ចៅក្រម ឡាវែន៍ នោះគាត់ថា គាត់មិនដឹងថា អ្នកទៅផ្ទះតាម៉ុក នៅតាកែវហ្នឹង អ្នកណាទេ? សូមលោកបញ្ជាក់ឈ្មោះ អ្នកដែលទៅនោះផងបាទ។

**លោក ខៀវ នៅ៖**

**ឆ៖** គឺលោក ប៉ុល ពត ដែលទៅៗជួបមួយភ្លែតនៅតាកែវហ្នឹង គឺលោក ប៉ុល ពត។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី។ បាទ ឥឡូវនេះ ដល់ពេលសមល្មសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្ដល់កន្លែងសម្រាក សមរម្យដល់សាក្សី នៅបន្ទប់រង់ចាំសម្រាប់សាក្សី និងឲ្យអញ្ជើញគាត់មកកន្លែងផ្ដល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:៣៤ នាទី ដល់ម៉ោង ១០:៥១ នាទី)*

[១០:៥១:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងមុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាសូម-- អង្គជំនុំជម្រះសូមសួរទៅតំណាងសហព្រះរាជអាជ្ញាថា តើខាងក្រុមតំណាងសហព្រះរាជអាជ្ញា ត្រូវការពេលវេលាប៉ុន្មានទៀត ក្នុងការតាំងសំណួរសាក្សីរូបនេះ?

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំមានបំណងបញ្ចប់ការតាំងសំណួររបស់ខ្ញុំនៅពេលពិសាបាយថ្ងៃត្រង់តែម្តង គឺអាស្រ័យទៅលើសមត្ថភាពរបស់សាក្សីរូបនេះ ថាគាត់ឆ្លើយបានលឿនប៉ុនណា ប៉ុន្តែយើងខ្ញុំនឹងបញ្ចប់នៅត្រឹមពេលពិសាបាយថ្ងៃត្រង់។

[១០:៥២:២៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅ តំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរដេញដោល។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ជម្រាបសួរសាជាថ្មីម្តងទៀត លោក ខៀវ នៅ។ មុនពេលឈប់សម្រាកនេះ គឺលោកបានជម្រាបថា គេបានស្នើឲ្យលោកធ្វើការនៅមន្ទីរភូមិភាគនិរតី ប្រចាំនៅទីក្រុងភ្នំពេញ។ ទីមួយ សូមលោកជម្រាបថា តើអ្នកណាដែលណែនាំ ឬក៏ស្នើសុំឲ្យលោកមកធ្វើការនៅមន្ទីរនេះ?

[១០:៥៣:២៩]

**លោក ខៀវ នៅ៖**

**ឆ៖** សូមជម្រាបលោក។ តាម៉ុក គាត់ឲ្យមកតែម្តង។

**ស៖** តើលោកនៅចាំទេ យើងកំពុងនិយាយគ្នាអំពីឆ្នាំ១៩៧៦ ថាតើវានៅដើមឆ្នាំ ឬមួយក៏នៅពាក់កណ្តាល ឬក៏នៅចុងឆ្នាំ១៩៧៦?

**ឆ៖** ចាំមិនបាន។ ចាំមិនបានទេ ដើមឆ្នាំ ឬចុងឆ្នាំ ហើយបើខំនឹក ដល់តែយូរណាស់ ផ្សំរឿងវែងនោះបាននឹកឃើញខ្លះ បើភ្លាមៗនឹកមិនឃើញអស់ទេ។

**ស៖** មិនអីទេ។ មិនថ្វីទេលោក ប៉ុន្តែលោកនឹកឡើងវិញមើល៍ តើមានក្នុងឆ្នាំ១៩៧៦ មែនទេ?

**ឆ៖** ប្រហែលជាចុង៧៦ ហ្នឹងហើយ។

[១០:៥៥:00]

**ស៖** សូមអរគុណលោក។ តើលោកអាចជម្រាបជូនតុលាការបានទេ ថាតើមន្ទីរនោះ កិច្ចការរបស់មន្ទីរនោះគឺធ្វើការងារអ្វីដែរ?

**ឆ៖** ការងារកន្លែងនោះ គឺដឹកជញ្ជូនសម្ភារៈពីៗក្រុងភ្នំពេញយកទៅក្រៅ ចែកប្រជាជនខាងក្រៅ។ ហើយភាគច្រើន គឺដឹកពីឃ្លាំងរដ្ឋ ហៅឃ្លាំងរដ្ឋ។

**ស៖** ថាតើសម្ភារៈទាំងអស់នោះ គឺដឹកចេញពីឃ្លាំងរដ្ឋយកទៅហ្នឹង តើជាសម្ភារៈប្រភេទអ្វីដែរ?

**ឆ៖** តាំងពីចាន ឆ្នាំង គ្រឿងប្រើប្រាស់ រហូតដែក ស៊ីម៉ងត៍ ដែលប្រជាជនត្រូវការ។ រហូតទៅដល់ទៀន ដែលមាននៅក្នុងឃ្លាំងហ្នឹងក៏ដឹកចេញទាំងអស់។ ស្អី សម្ភារៈ ដែលប្រជាជនអាចប្រើការបាន គឺយកចេញជូនទៅទាំងអស់។

[១០:៥៦:៥៤]

**ស៖** ដើម្បីជាប្រតិចារឹក ថាតើឃ្លាំងរដ្ឋហ្នឹងស្ថិតនៅត្រង់កន្លែងណាដែរ លោកអាចជម្រាបជូនតុលាការបានទេ?

**ឆ៖** នៅក្នុងក្រុងភ្នំពេញហ្នឹង ប៉ុនមិនចាំកន្លែងទេ ខ្ញុំដូចភ្លេចព្រោះច្រើនតែឲ្យក្មេងៗទៅ ពួកឡានពួកដឹកផ្ទាល់យកទៅ យកសំបុត្រ ទៅដល់គឺប្រគល់ឲ្យខាងឃ្លាំងរដ្ឋៗប្រគល់របស់ហ្នឹងមក ដឹកចេញទៅ។

**ស៖** មុននឹងបន្តចូលទៅដល់កិច្ចការនេះ កិច្ចការដឹកជញ្ជូននេះ ខ្ញុំសូមសួរទៅលោក តើលោកធ្វើការនៅមន្ទីរនេះអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** ធ្វើកិច្ចការក្នុងទីនេះរហូតមកទាល់នឹង៧៩ ដែលកើតសង្គ្រាមហ្នឹង បានចេញ។

**ស៖** នៅមន្ទីរភូមិភាគនិរតីនេះ តើលោកមានតួនាទីអ្វីដែរ?

**ឆ៖** តួនាទី គ្រាន់តែចាត់ចែងគ្រប់គ្រងពួកដឹកជញ្ជូន ទាំងអ្នកបើកឡាន ទាំងអីហ្នឹង គ្នាប្អូន-

ដប់នាក់តែប៉ុណ្ណឹងទេ។ គ្រប់គ្រងតែប៉ុណ្ណឹងនាក់ អត់មានអំណាចហួសពីហ្នឹងទៀតទេ។

[១០:៥៩:២៥]

**ស៖** ហើយលោកបានជម្រាបមកជូនខាងយើងខ្ញុំថា ប្រជាជនគេត្រូវមានលិខិតកាន់ទៅកាន់ឃ្លាំងរដ្ឋហ្នឹង ដើម្បីទៅទទួលរបស់របរទាំងអស់ហ្នឹងដឹកទៅកាន់ភូមិភាគ។ ថាតើលិខិតទាំងអស់នេះ អ្នកណាជាអ្នកចេញលិខិតហ្នឹង?

**ឆ៖** លិខិតហ្នឹងចេញពីអង្គការលើមក។ ពីសេដ្ឋកិច្ចខាងលើមក។

**ស៖** ហើយនៅក្នុងផ្នែកសេដ្ឋកិច្ចហ្នឹង គឺអ្នកណាជាអ្នកគ្រប់គ្រងខាងផ្នែកសេដ្ឋកិច្ចហ្នឹង?

**ឆ៖** សូមសួរបញ្ជាក់ថា អ្នកគ្រប់គ្រងសេដ្ឋកិច្ចខាងលើ គឺយ៉ាងម៉េច? សេដ្ឋកិច្ចរដ្ឋ ឬយ៉ាងម៉េច? សេដ្ឋកិច្ចរដ្ឋ កាលនោះដឹងថា លោក វន វ៉េត។

**ស៖** ថាតើលោកលោក វន វ៉េត ជាអ្នកស៊ីញ៉េនៅលើលិខិតនេះដោយផ្ទាល់ ដើម្បីអនុញ្ញាតឲ្យដឹកជញ្ជូនរបស់ទាំងអស់នេះ ឬក៏យ៉ាងណា?

**ឆ៖** កាលនោះ ដូចមិនផ្ទាល់ទេ។ ដូចមាន ក-២២ មកទៀត ហើយអត់បានពិនិត្យនេះច្បាស់លាស់នេះផង អាងតែមានសំបុត្រមកពីលើមកហើយហ្នឹង។ ប៉ុន្តែដាក់ ក-២២ ដូចអ៊ីចឹងហើយ។

[១១:០២:០៥]

**ស៖** តើមានថ្នាក់ដឹកនាំជាន់ខ្ពស់ណា ឬក៏ថ្នាក់លើណា ដែលលោកបានស្គាល់នៅពេលនោះ ដែលធ្វើការជាមួយ វន វ៉េត ឬធ្វើការជាមួយនឹងខាងផ្នែកពាណិជ្ជកម្មរដ្ឋនេះ?

**ឆ៖** ខាងឃ្លាំងរដ្ឋ ប្រធានឃ្លាំងរដ្ឋឈ្មោះ រឿង ប៉ុនឮថាស្លាប់ហើយ។ ឈ្មោះ រឿង, ឈ្មោះ ជួន ហ្នឹងបែក។ ជួន, តេង ហ្នឹងមិនដឹងបែកគ្នាទៅឯណាទេ អត់ដឹងទេ។ ហើយខាងឧស្សាហ៍កម្ម ជ័យ អន ចាំបាន ជ័យ អន ហ្នឹងផ្នែកខាងឧស្សាហ៍កម្ម។ មិនចាំអស់ទេ។

**ស៖** មុននឹងខ្ញុំចូលបន្តទៅសួរនូវឈ្មោះទាំងនេះ លោកបានជម្រាបថា របស់របរទាំងអស់ហ្នឹង គឺត្រូវបានដឹកជញ្ជូនពីឃ្លាំងរដ្ឋទៅកាន់ភូមិភាគ។ តើមានរបស់របរអ្វីដែលត្រូវដឹកជញ្ជូនពីភូមិភាគ មកចូលភ្នំពេញវិញដែរឬទេ?

**ឆ៖** មានដឹកខ្លះដែរ ប៉ុន្តែ--។

**ស៖** សូមលោកជម្រាបខ្ញុំផង ថាតើរបស់របរទាំងអស់ហ្នឹង ជារបស់របរប្រភេទអីដែរ?

**ឆ៖** មានដឹកសំឡីគ ដឹកស្រូវ របស់អីដែលប្រជាជនធ្វើបាន ហើយត្រូវការយកមក។

**សៈ** ថាតើអង្គភាពដឹកជញ្ជូនរបស់លោកទទួលខុសត្រូវដឹកជញ្ជូនផលិតផលពីនិរតីមកកាន់ភ្នំពេញដែរឬទេ?

**ឆៈ** ខ្ញុំបញ្ជាក់អម្បាញ់មិញថា មានដឹកសំឡឹត ដឹកស្រូវ ដឹក អាហ្នឹងដឹកចូលមកខាងរដ្ឋ។ ដឹកដូងមកកន្លែងធ្វើសាប៊ូ។

**សៈ** ខ្ញុំសូមបញ្ជាក់ទៅលើសំណួររបស់ខ្ញុំ ថាតើសម្ភារៈទាំងអស់ហ្នឹង គឺថាត្រូវដឹក ត្រូវបានដឹកជញ្ជូនដោយអង្គភាពរបស់លោកមកចូលទីក្រុងភ្នំពេញមែន ឬក៏យ៉ាងណា?

**ឆៈ** ដឹកមកចូលភ្នំពេញមែន។

**សៈ** ថាតើលោកនៅចាំបានទេ ផ្នែករបស់លោកនេះបានដឹកជញ្ជូនរបស់របរទាំងអស់ហ្នឹងពីភូមិភាគនិរតីមកចូលភ្នំពេញញឹកញាប់ប៉ុនណាដែរ?

**ឆៈ** ហើយចំនួនញឹកញាប់ជាតួលេខពិបាកនិយាយដែរ ប៉ុន្តែដឹកហ្នឹងច្រើនដែរ។ ដាក់ជាចំនួនលេខ ពិបាកដាក់។

**សៈ** តាមដែលលោកចងចាំបានល្អបំផុតនោះ មិនបាច់លម្អិតបំផុតទេ ប៉ុន្តែថាតើការដឹកជញ្ជូនហ្នឹង ដឹកជញ្ជូនប្រចាំសប្តាហ៍ ឬក៏ប្រចាំខែ ឬក៏ប្រហែលជាប៉ុន្មានជើងក្នុងមួយខែ តាមដែលលោកស្មានមើល?

[១១:០៧:១៩]

**ឆៈ** មិនៗកំណត់ពេលវេលាទេ កំណត់ថារបស់ហ្នឹងវាមាន។ ដូចជាសំឡឹតដែលមានដល់កម្រិតអាចដឹកបាន ក៏ដឹកមក ហើយដឹកមកមិនមែនយកមកដល់ដាក់កន្លែងភូមិភាគហ្នឹងទេ យកដាក់កន្លែងឧស្សាហកម្ម។ ដូច្នេះ ខ្ញុំមិនបានឃើញទេ។ តែពួកឡានដឹកយកឲ្យខាងឧស្សាហកម្ម។ ត្រង់នេះហើយដែលនាំឲ្យមីងមាំងនោះ។ បើយកមកទុកកន្លែងហ្នឹងយើងស្រួល។ របស់ផ្សេងៗក៏របៀបហ្នឹងដែរ។ មិនមែនយកមកដាក់កន្លែងភូមិភាគហ្នឹងទេ។

**សៈ** និយាយអំពីស្បៀងអាហារវិញម្តង ដូចជាអង្ករ ដូង។ តើលោកនៅចាំទេអំពីការដឹកជញ្ជូនជាធម្មតាទៅលើរបស់របរទាំងអស់នេះ តើគេប្រើប្រាស់ឡានដឹកជញ្ជូនហ្នឹង ឡានធំៗដឹកជញ្ជូនហ្នឹងប្រហែលជាចំនួនប៉ុន្មានដែរ បើគិតពីចំនួនឡាននោះវិញនោះ?

**ឆៈ** ក្នុងការដឹកជញ្ជូនហ្នឹងឡានភូមិភាគ ដោយសារវាសល់ពេលសល់វេលា ដឹករបស់ពីភ្នំពេញទៅ មកវិញ ក៏ដឹកមក។ ប៉ុន្តែឡានខាងរដ្ឋ ហៅថាដឹកជញ្ជូនជើងគោក។ អាហ្នឹងគ្រាន់ដឹងតែប៉ុណ្ណឹងទេ។

គ្រាន់ដឹងតែប៉ុណ្ណឹងទេ ខាងដឹកជញ្ជូនជើងគោកត្រូវការដឹកច្រើនយ៉ាងណាៗគឺ ឡានខាងឃ្លាំង-- អ៎! ខាងរដ្ឋ។ ខាងដឹកជញ្ជូននោះ-- ក្រសួងដឹកជញ្ជូននោះផ្សេង។ ហ្នឹងខាងរដ្ឋ។

[១១:០៩:២៥]

**ស៖** ទាក់ទងទៅនឹងការរៀបចំចាត់ចែង លោកស្គាល់ទេថាតើអ្នកណាដែលមកពីភូមិភាគនិរតីដើម្បីទទួលខុសត្រូវក្នុងការដឹកជញ្ជូនរបស់របរទាំងអស់ហ្នឹង ក៏ដូចជាការចាត់ចែងមធ្យោបាយដឹកជញ្ជូនរបស់របរទាំងអស់ហ្នឹងមកចូលទីក្រុងភ្នំពេញ?

**ឆ៖** ចាត់ចែងហ្នឹង មិនមាននេះទេ កំណត់តាមតំបន់ តាមខេត្ត។ ខេត្តណាគេមានអី គេឱ្យយើង-- ពេលដែលយើងដឹកជញ្ជូនយកទៅឱ្យគេ គេដាក់ឡានហ្នឹងមកវិញ។ មិនកំណត់ថា យកអ្នកត្រឹមអ្នកភូមិភាគ អ្នកនេះ អ្នកនោះទេ។ ឯដឹកច្រើនមែនទែន អាហ្នឹងគឺក្រសួងខាងរដ្ឋ ខាងដឹកជញ្ជូនជើងគោកហ្នឹង ចេញចំមុខតែម្តង។ ឯខាងភូមិភាគ ខាងខ្ញុំនេះ គឺជាឡានមកវិញទទេ ក៏ដាក់មក មិនមែនតែដឹកត្រង់ៗទេ។ ដូច្នេះ ពិបាកកំណត់ជាផ្លូវការមែនទែនណាស់។

**ស៖** លោកបានជម្រាបពីមុន ពីឈ្មោះ ចេង អន ដែលទទួលខុសត្រូវខាងផ្នែកក្រសួងឧស្សាហកម្ម។ តើនៅក្នុងអំឡុងពេលហ្នឹង លោកដែល-- លោកបានជួបគាត់ទេ?

[១១:១១:២៤]

**ឆ៖** បានជួប ពេលទៅរកឥដ្ឋ រកគ្រឿង យកទៅក្រៅ ទៅទាក់ទងខាងហ្នឹង។ របស់អី ខាង-- ដែលទាក់ទងខាងឧស្សាហកម្ម ទៅទាក់ទងលោក ជ័យ អន ហ្នឹង។ ជួនទៅ លោក វន វ៉េត ក៏មានដែរ។ នៅកន្លែងមន្ទីរហ្នឹង។

**ស៖** តើលោកដែលធ្លាប់បានជួបមនុស្សម្នាក់ឈ្មោះ វ៉ាន់ រិទ្ធ ដែរទេ?

**ឆ៖** មិនចាំនាមត្រកូលទេ ប៉ុន្តែឈ្មោះ រិទ្ធ មានជួប។ ប៉ុន្តែមិនដឹងនាមត្រកូលថាម៉េច។

**ស៖** លោកដឹងតួនាទីរបស់គាត់ហ្នឹង របស់ រិទ្ធ ហ្នឹង មានតួនាទីអីដែរ?

**ឆ៖** ខាងពាណិជ្ជកម្មដែរ ប៉ុន្តែដូចទាក់ទងទៅក្រៅ។ អាហ្នឹង ដឹងមិនច្បាស់ទេ។ ដឹងតៗមកទ។

**ស៖** តើផ្នែកពាណិជ្ជកម្មក្រៅប្រទេសហ្នឹង គឺវាខុសគ្នាពីផ្នែកដែល ចេង អន ទទួលខុសត្រូវ ឬក៏យ៉ាងណាដែរ?

[១១:១៣:១៣]

**ឆ៖** ដល់វែងឆ្ងាយទៅទៀត ខ្ញុំមិនដឹងទេ។

**ស៖** លោកបានស្នាក់នៅទីក្រុងភ្នំពេញ លោកបានជម្រាបអម្បាញ់មិញថា រហូតដល់ខែមករា ១៩៧៩។ តើ ចេង អន នេះ បានស្ថិតនៅភ្នំពេញកាន់មុខតំណែងរបស់គាត់រហូតដល់ខែមករា ៧៩ ដែរឬទេ?

**ឆ៖** ដូចចាំមិនច្បាស់ ត្រង់ហ្នឹង។ ចាំមិនច្បាស់។

**ស៖** តើលោកមានដឹងថា មានអ្វីកើតឡើងចំពោះរូបគាត់នៅខែមករា ៧៩ ឬក៏ក្រោយខែមករា ១៩៧៩?

**ឆ៖** វែងឆ្ងាយទៀត ខ្ញុំមិនដឹងទេ។

[១១:១៤:៥០]

**ស៖** មុននឹងចាកចេញពីឈ្មោះនេះ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឯកសារ 5.12 និយាយអំពីឈ្មោះនេះ។ នេះនៅក្នុងចម្លើយសារភាពរបស់ ចេង អន។ ខ្ញុំនឹងចូលទៅសាកសួរ ថាតើមាន អ្វីកើតឡើងចំពោះបុគ្គលទាំងនេះ។ តើលោកមានបានដឹងទេ មានអ្វីកើតឡើង ចំពោះ វន វ៉េត មានអ្វីកើតឡើងចំពោះ វន វ៉េត នៅក្នុងអំឡុងពេលនោះ?

**ឆ៖** គ្រាន់តែឮតៗមកថា មានបញ្ហា ក៏បាត់ចេញពីក្រសួងហ្នឹងទៅ និងក៏តៗមកដែរ។ មិនបានដឹងជាផ្លូវការមែនទែនទេ។

[១១:១៦:០៤]

**ស៖** លោកឮមកពីអ្នកណាគេដែរ?

**ឆ៖** រកដើមទីលែងឃើញហើយ មកដល់នេះ គេនិយាយច្រើនគ្នា កំណត់ម្នាក់មិនបានទេ។

**ស៖** តើសហការីរបស់លោក សមមិត្តរបស់លោក ដែលធ្វើការនៅភ្នំពេញហ្នឹងដែលប្រាប់ថា វន វ៉េត បាត់ខ្លួនហ្នឹង តើអ៊ីចឹងមែនទេ?

**ឆ៖** ឮនិយាយក្រៅអ៊ីចឹងហើយ។ ប៉ុន្តែមិនចាំឈ្មោះទេ មិនចាំទេ។ ដល់ពេលអ៊ីចឹង និយាយច្រើនគ្នាៗ។ ដូច្នេះយើងកំណត់ម្នាក់មិនបានទេ។ ហើយយើងក៏មិនមែនជាអ្នកយកការណ៍ដែរ។ តែកាលណាឮដំណឹងម៉េចៗ ប្រយ័ត្នតែខ្លួនឯង។

[១១:១៧:១៦]

**ស៖** តើលោកអាចជម្រាបជូនតុលាការឲ្យបានច្រើនបន្តិចបានទេ ថាតើ-- លោកបានជម្រាបថា គឺ គាត់បានបាត់ខ្លួន។ ក្រៅពីនេះតើលោកអាចជម្រាបជូនតុលាការ ឲ្យបានច្រើនជាងនេះបន្តិចបានទេ?

**ឆ៖** បើនិយាយឲ្យពិតប្រាកដមិនបានច្រើនទេ។ ជាផ្លូវការមែនទែន មិនបានច្រើនទេ។ បើនិយាយក្រៅផ្លូវការ ចេះតែនិយាយស្មានខ្លះអីខ្លះទៅ ចេះតែបានច្រើន។ ប៉ុនជាផ្លូវការតុលាការមិនបានច្រើនទេ។

[១១:១៨:០០]

**ស៖** សូមលោកជម្រាបជូនតុលាការ សង្ខេបក៏បានដែរ។ តើលោកបានឮអ្វីខ្លះ?

**ឆ៖** គ្រាន់តែឮថាមានរឿង មានបញ្ហា។

**ស៖** តើលោកនៅចាំទេ គាត់បាត់ខ្លួនហ្នឹងនៅក្នុងអំឡុងពេលណាដែរ?

**ឆ៖** ហ្នឹងរឹតតែមិនចាំទៅទៀតហើយ។ ប្រុងប្រយ័ត្នតែខ្លួនឯង ប៉ុន្តែដល់ឮ តាំងភ័យក្នុងខ្លួនហើយ អត់ មិនអេចអូច មិនមាត់មិនក គឺប្រយ័ត្នតែក្នុងខ្លួនឯង តែមានឮបញ្ហាខាងក្រៅប្រយ័ត្នតែខ្លួនឯងនេះ។ តើអញទុកដាក់ខ្លួនយ៉ាងម៉េច ត្រូវរៀបចំខ្លួនយ៉ាងម៉េចឲ្យរួចខ្លួន។

**ស៖** ក្រៅពី វន វ៉េត តើលោកស្គាល់អ្នកណាផ្សេងទៀត ដែលបានបាត់ខ្លួនក្នុងពេលនោះទេ?

**ឆ៖** បាត់ៗ ពីមុនមក បាត់លោក ហ៊ូ នឹម, ហ៊ូ យន់។ អាហ្នឹងបាត់តាំងពីមុនមក។

**ស៖** ថាតើពួកគាត់ទាំងអស់ហ្នឹង បាត់ខ្លួនដោយសារអ្វីដែរ លោកអាចបង្ហាញហេតុផលបានទេ?

**ឆ៖** រឹតតែមិនដឹងទៅទៀតហើយហ្នឹង។ បើអត់ដែលបានទាក់ទង បើលោក វន វ៉េត បានទាក់ទងខ្លះ ហើយបាត់មិនដឹងថាបាត់ទេ បាត់យូរដែរបានឮៗដំណឹង។

**ស៖** ចុះចំពោះកម្មាភិបាលធម្មតា ដូចជាកម្មាភិបាល ដូចជារូបលោក ដែលធ្វើការនៅភ្នំពេញ តើលោកដែលបានកត់សម្គាល់ថា មានកម្មាភិបាលណាម្នាក់បាត់ខ្លួនដែរឬទេ?

[១១:២០:៥៥]

**ឆ៖** បាត់នោះមាន ប៉ុនសុទ្ធតែអ្នកឃ្លាតឆ្ងាយពីគ្នា ធ្វើការឆ្ងាយពីគ្នា ពួកន្លែងនេះកន្លែងនោះ ចេះតែឮទៅ ថាបាត់អ៊ីចេះអ៊ីចុះអី ឮមាន មានឮ។

**ស៖** តើលោកមានបានដឹងមូលហេតុ ថាហេតុអ្វីបានជាមានមនុស្សបាត់ខ្លួនដែរទេ?

**ឆ៖** បាត់ហ្នឹង គេច្រើនប្រើសួរទៅថា "ក្បត់" ប៉ុនមិនដឹងរឿងអីខ្លះទេ គ្រាន់តែឮថាអ៊ីចឹង ថាក្បត់។

**ស៖** ហេតុអ្វីបានជាគេចោទប្រជាជន ឬក៏ចោទអ្នកទាំងនោះថា ជាជនក្បត់?

**ឆ៖** ត្រង់ហ្នឹងក៏មិនដឹងច្បាស់ទៅទៀត ដូចថា ខ្ញុំដូចបញ្ជាក់ខាងដើម ខ្ញុំថា ខ្ញុំវាដឹងអីតែពីចុងទេ មិនបានដឹងពីគល់ ដឹងចុងៗហើយ ចុងសន្លឹក ចុងមែក មិនបានពីឫសពីគល់ទេ ព្រោះយើងវាមិនមែនជាកម្មាភិបាលពេញអង្គឯណា។ ដឹកជញ្ជូនហ្នឹងវែងមែន ប៉ុន្តែវាតូចតាចទេ ឋានៈតូច មិនធំដុំស៊ីជម្រៅទេ។

**សៈ** នៅពេលលោកនៅភ្នំពេញ តើលោកបានចូលរួមក្នុងកិច្ចប្រជុំណាមួយ ដែលណែនាំអំពីការធ្វើការងារ អំពីវិន័យ អំពីថាតើអង្គភាពរបស់លោកត្រូវធ្វើការអ្វីខ្លះ? តើលោកបានធ្លាប់បានចូលរួមក្នុងកិច្ចប្រជុំបែបនេះទេ?

**ឆ៖** ប្រជុំៗនៅភូមិភាគ មិនមែនប្រជុំនៅភ្នំពេញទេ ទៅប្រជុំភូមិភាគ ហើយតំណាងខាងភូមិភាគហ្នឹងពន្យល់ណែនាំ។

[១១:២៤:១៧]

**សៈ** តើលោកបានចូលរួមប្រជុំបែបនេះហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ភ្លេចពេល ភ្លេចវេលាហើយ ប៉ុន្តែមិនយូរប៉ុន្មានទេ ហើយក៏មិនញឹកពេកដែរ ការចូលប្រជុំហ្នឹង។

**សៈ** នៅក្នុងអង្គប្រជុំបែបនេះ តើគេមាននិយាយអំពីពួកអាក្បត់អី ដូច្នេះដែរឬទេ?

**ឆ៖** និយាយគេចែងតែមេរៀន អាមាត៌ាប្រជាជន មាត៌ាបដិវត្តន៍ យ៉ាងម៉េចៗគេមិននិយមចេញឈ្មោះបុគ្គលទេ បើដាក់ក្នុងឯកសារ និយាយចំពោះមាត៌ា ចំពោះច្បាប់ បដិវត្តន៍។

**សៈ** សូមឲ្យលោកឆ្លើយដោយសង្ខេប ដោយសារយើងមានពេលខ្លី តើមាត៌ាអ្វីដែលសំខាន់បំផុតដែលលោកបានដឹង បានឮនោះ ដែលនិយាយពេលនោះ?

**ឆ៖** មាត៌ាបដិវត្តន៍ ច្រើនលើកអំពីកសិករ ព្រោះខ្មែរមានកសិករ៨៥% ។ ដូច្នេះធ្វើកិច្ចការងារអ្វីគឺគោរពទៅតាម-- ភាគច្រើនគឺ ៨៥%។ ហ្នឹងគោលសង្ខេបប៉ុណ្ណឹង។

[១១:២៦:៥៤]

**សៈ** តើមានន័យថា អ្នកដែលមិនមែនជាកសិករត្រូវតែធ្វើអ្វី ឬក៏មានតែពួកកសិករទេ ដែលជាភាគច្រើន? តើអ៊ីចឹងឬ?

**ឆ៖** ត្រូវការធ្វើៗ ត្រូវការហាត់រៀន កសិករហ្នឹងក៏ត្រូវរៀន មាត៌ាកសិករដែរ ធ្វើឲ្យត្រូវតាមច្បាប់កសិករ ហើយអ្នកមិនមែលកសិករក៏ត្រូវការហាត់រៀនតាមកសិករ។ ហើយដូចខ្ញុំអីមានដែលនេះឯណាារស់តែឫស ហ្នឹងត្រូវរៀនធ្វើតាមកសិករ ធ្លាប់ធ្វើកសិករកាលនៅក្មេងដែរ។

**សៈ** តើលោកអាចរំឭក តើ សំណាង មានតួនាទីជាអ្វីដែលជាអ្នកដឹកនាំនោះ?

**ផៈ** សូមបញ្ជាក់ សំណាង ណា? សំណាង ណា?

[១១:២៨:៣៦]

**សៈ** ឈ្មោះ សំណាង ដែលលោកនិយាយថា ដែលផ្តល់ការណែនាំនៅក្នុងកិច្ចប្រជុំអប់រំនៅថ្នាក់តំបន់? បាទ នៅថ្នាក់ភូមិភាគ សូមកែតម្រូវ។

**ផៈ** ភូមិភាគ ខាងភូមិភាគដូចខ្ញុំមិនទាន់មានចេញឈ្មោះទេណា៎។ ភូមិភាគដូចចេញតែ តាម៉ុក មួយទេ! ក្រៅពីនុ៎ងដូចមិនទាន់ចេញ ដូចមិនទាន់ថា អ្វីក៏ខ្ញុំមានថា?

**សៈ** ប្រហែលថា នៅក្នុងការបកប្រែលម្អៀង តើលោកអាចប្រាប់ខ្ញុំបានទេ អ្នកណាជាអ្នកធ្វើអធិបតីនៃការប្រជុំអប់រំនោះ?

**ផៈ** ការប្រជុំហ្នឹង គឺលោកឈ្មោះ ប៊ិត, អនុ តាម៉ុក ប៉ុន្តែស្លាប់បាត់ហើយ។ ហ្នឹងច្រើនមក--

**សៈ** តើដែលឈ្មោះពេញរបស់គាត់ឈ្មោះ សំ ប៊ិត អ៊ីចឹងដែរឬទេបាទ?

[១១:២៩:៥៨]

**ផៈ** សំ ប៊ិត អ៊ីចឹងហើយ។

**សៈ** សូមអរគុណ។ តើ តាម៉ុក ធ្លាប់ចូលរួមនៅក្នុងការវគ្គអប់រំសិក្សានេះដែរឬទេ?

**ផៈ** ពេលដែលខ្ញុំទៅប្រជុំមិនដែលបានជួបទេ។ បើជួបៗតែផ្ទាល់ និយាយមួយម៉ាត់ពីរម៉ាត់ផ្ទាល់តែម្តង។ ជួបជាវគ្គ ជាសិក្សា អត់ទេ។

**សៈ** តើ តាម៉ុក បានមកភ្នំពេញដែរឬទេនៅក្នុងអំឡុងពេលដែលលោកធ្វើការនៅក្នុងស្នាក់ការឬមន្ទីរមួយនៅក្នុងក្រុងនោះ?

**ផៈ** ពេលណាដែលខាងរដ្ឋត្រូវការ ខាងលើត្រូវការ មកជួបជុំគ្នាគាត់ខាងលើ មកចូលមួយភ្លែត ហើយក៏ទៅបាត់ទៅ។ បើថាប្រជុំមួយថ្ងៃទៅមួយថ្ងៃទៅ បើពីរថ្ងៃៗទៅ។ ឃើញមកវិញ ក៏ហួសទៅទៀតទៅ ចូលមួយភ្លែតៗហ្នឹងមិនបាននៅយូរទេ យ៉ាងយូរមួយម៉ោងអីប៉ុណ្ណឹង។

[១១:៣១:៥៦]

**សៈ** លោកនិយាយថា គាត់ចូលមកនៅពេលដែលមកប្រជុំនៅភ្នំពេញ។ តើលោកដឹងទេ ថាតើអ្នកណាជាអ្នកនៅថ្នាក់លើហ្នឹងបាទ?

**ផៈ** ថ្នាក់ដែលដឹងពីក្រោមទៅ ឮតៗមកថាមានតែលោក ប៉ុល ពត ហ្នឹង។ ហ្នឹងប្រធានខាង

លើហើយហ្នឹង។ ហ្នឹងគឺដឹងទូទៅគ្រប់គ្នាតែអ៊ីចឹង។ ខ្ញុំក៏ដឹងតែប៉ុណ្ណឹងដែរ ដឹងដូចគេដែរ អ៊ីចឹងដែរ។ ប៉ុន្តែក្នុងគណៈកម្មាធិការអី កាលហ្នឹងចាត់តាំងម៉េចៗខ្ញុំមិនដឹងដល់ទេ។

**ស៖** តើ តាម៉ុក បានប្រាប់លោកថាតើគាត់ជួយជាមួយអ្នកណាទេនៅពេលដែលគាត់មកភ្នំពេញហើយទៅជួបលោកនោះ?

**ឆ៖** បើក្នុងដំណើរការគ្រប់គ្រងពេលហ្នឹង គេមិននិយមចេញបុគ្គលទេ មិនចេញឈ្មោះបុគ្គលទេ ចេញឈ្មោះអង្គការ។ បើក្រៅផ្លូវការ អាហ្នឹងបាននិយាយចេញឈ្មោះ បើថាផ្លូវការ គេថាអង្គការខាងលើហៅទៅជួបជុំគ្នា។ ប្រើពាក្យអង្គការ។

**ស៖** ឥឡូវនេះ ខ្ញុំចង់ត្រឡប់ទៅចំណុចមួយក្នុងរយៈពេលខ្លីទេ ចំពោះមនុស្សដែលលោកបានជួបនៅពេលដែលលោកៗទៅកន្លែងផ្សេងៗនៅទីក្រុងភ្នំពេញកាលណោះ? នៅក្នុងពេលនោះ នៅពេលដែលលោកធ្វើការនៅភ្នំពេញ តើលោកធ្លាប់ជួប ឬក៏បានឃើញលោក ខៀវ សំផន ដែរឬទេ?

[១១:៣៤:២៥]

**ឆ៖** បានឃើញ បានជួប។

**ស៖** តើលោកនៅចាំទេ បានឃើញគាត់ប៉ុន្មានដង?

**ឆ៖** បានពីរដង។

**ស៖** តើលោកបានដឹងទេ ថាតើលោក ខៀវ សំផន មានតួនាទីជាអ្វី តំណែងជាអ្វីនៅកាលណោះ?

**ឆ៖** ជាចំហ ផ្សាយពេញពិភពលោក ថាប្រធានគណៈប្រធានរដ្ឋ អាហ្នឹងផ្សាយតាមវ៉ាដ្យូ។ អាហ្នឹងឮគ្រប់តែគ្នា ប្រធានគណៈប្រធានរដ្ឋ។

**ស៖** ក្រៅពីតួនាទីសាធារណៈអ៊ីចឹងតើលោកដឹង ថាតើមាន គាត់មានតួនាទី ឬតំណែងអ្វីផ្សេងទៀតទេ?

**ឆ៖** ដឹង មានតែដឹងដោយស្មានៗ ដឹងជាផ្លូវការអត់ទេ។

**ស៖** តើលោកដឹងដូចថាស្មាន ឬក៏ក្រៅផ្លូវការហ្នឹង លោកដឹងថាគាត់ធ្វើអ្វី?

**ប្រធានអង្គជំនុំ៖**

សាក្សី កុំអាលទាល់ឆ្លើយ។

សូមអញ្ជើញលោកមេធាវី!

[១១:៣៦:១៣]

**លោក អាង ឧត្តមៈ**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សួស្តីសហព្រះរាជអាជ្ញា សួស្តីសហភាតា លោកអ្នកទាំងឡាយ។

សហព្រះរាជអាជ្ញាកំពុងតែនាំសាក្សីឲ្យឆ្លើយស្មាន។ ខ្ញុំសូមជំទាស់សំណួរនេះ សូមអរគុណ។

**ប្រធានអង្គជំនុំៈ**

សេចក្តីជំទាស់របស់មេធាវីការពារក្តីមានប្រសិទ្ធភាព សាក្សីមិនចាំបាច់ឆ្លើយតបនឹងសំណួរចុងក្រោយសួរដោយតំណាងសហព្រះរាជអាជ្ញាទេ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីកៈ**

**សៈ** នៅពេលដែលលោកបានជួបលោក ខៀវ សំផន នៅពីរដងនោះ តើលោកបានជួបគាត់នោះក្នុងគោលបំណងអ្វីដែរ?

**លោក ខៀវ នៅៈ**

**ឆៈ** ជួបមុនដំបូង ជូនគេទៅទេ មិនបានចូលទៅជួបទេ គ្រាន់តែជូនទៅមន្ទីរ ខ្ញុំនៅឯក្រៅ។ ជូនពួកចម្ការកៅស៊ូ ពួកមកពីចម្ការកៅស៊ូឲ្យជូនទៅដល់កន្លែងមន្ទីរហ្នឹង គ្រាន់តែជូនដល់មន្ទីរ ខ្ញុំនៅឯក្រៅ។ ដល់ហើយលោក ខៀវ សំផន គាត់ឮឈ្មោះខ្ញុំថា អត់ដែរឃើញមុខ ចង់ឃើញ ចង់ស្គាល់ ក៏ជួបមួយភ្លែតទៅ។ ប៉ុន្តែជួបអង្កាល់នុ៎ង មាននិយាយកិច្ចការបន្តិចដែរសួរ ថាខាងបាត់ដំបង-- អង្កាល់ហ្នឹងដូចខ្ញុំមានស្នើ បើអាចនិយាយច្រឡំខ្លះ ប៉ុន្តែគ្រាន់តែថា ស្នើសុំនែ៎ក្រណាត់ ពីព្រោះខាងពាយ័ព្យខ្វះក្រណាត់ ចែកប្រជាជន។ ហើយដល់សួរ ហើយគាត់ថា មានតែក្រណាត់ស ខ្ញុំថាក្រណាត់សក៏យកដែរ។ កាលសម័យសង្គ្រាមលោកលើកទីពីរជំនាន់ជប៉ុន គេយកក្រណាត់សហ្នឹងជ្រលក់ជាន់ភក់ ជ្រលក់សំបកឈើប្រើបាន។ រួចទៅ ក៏យកក្រណាត់សឲ្យគេយកទៅជួយខាងបាត់ដំបង ពោធិ៍សាត់ទៅ។ អាហ្នឹងគេនិយាយគ្នារឿងក្រណាត់បន្តិចហ្នឹង។

[១១:៣៩:១៣]

ហើយមើល ប៉ុន្តែនៅចាំបានខ្លះ មិនបានជាគ្រប់លក្ខណៈទេ ពីព្រោះកាលដែលបាននិយាយជាមួយគាត់ហ្នឹង គឺរឿងសម្ភារៈសម្រាប់ប្រជាជន។ រោងចក្រអារឈើ វាមានច្រើនកន្លែងហើយ ប៉ុន្តែខ្ញុំថាបម្រើសេចក្តីត្រូវការប្រជាជន មិនគ្រប់គ្រាន់ទេ។ ត្រូវប្រើតាមប្រពៃណីសិន រណាអារឈើ រណាដៃ

វណាអីហ្នឹងប្រើសិនទៅ ឲ្យតែបានអាហ្នឹងសិនទៅ ពន្លាក ដែកឈូសអី កុំអាលដល់រោងចក្រអី។ ខ្ញុំធ្លាប់មាននិយាយគាត់ពីបញ្ហាហ្នឹង ហើយក៏គាត់លៃលកតាមហ្នឹងទៅ។ អាហ្នឹងគឺជួបហ្នឹង គឺបញ្ហាហ្នឹង។

[១១:៤០:០៦]

ហើយជួបមួយលើកទៀតនោះ ភ្លៀងខ្លាំងបាក់ផ្លូវលេខ១ ជន់លិចបាក់ផ្លូវលេខ១ ផ្លូវទៅស្វាយរៀងហ្នឹង។ ពួកខាងខេត្តកណ្ដាលគេមកកន្លែងខ្ញុំថា សូមឲ្យជួយទាក់ទងទៅខាងលើ ដើម្បីទៅជួយទប់ទល់កន្លែងហ្នឹង ធ្វើម៉េចកុំឲ្យវាបាក់ច្រើនទៅ។ ហើយខ្ញុំក៏ទាក់ទងទៅ។ ទាក់ទងជាមួយគាត់ គាត់មកសួរថា ឥឡូវគិតដោះស្រាយយ៉ាងម៉េច? សួរមកខ្ញុំវិញ។ ខ្ញុំថា កន្លែងទំនប់ទឹកហ្នឹង អាសន្ទះទ្វារហ្នឹងវាដកអត់រួច។ បើបានដកសន្ទះទ្វារហ្នឹងរួច វាទៅតាមទ្វារទឹកផ្លូវហ្នឹងទៅវាធូរ។ បានយកអាឡានស្ទូចទៅស្ទូច ស្ទូចក៏អត់រួច ក៏នៅហ្នឹងទៅ។ អាហ្នឹងបញ្ហាដែលជួបគាត់រឿងអ៊ីចឹង។ ទោះបីបាត់ខ្លះ អីខ្លះ ក៏វានៅចាំចំណុចហ្នឹងបាទ។

**ស៖** សូមអរគុណ ដែលលោកបានរៀបរាប់លម្អិតពីបញ្ហានេះ។ ហើយឥឡូវនេះ ខ្ញុំនឹងសួរតទៅទៀត លោកបាននិយាយថា លោកបានជួបនៅពេលដំបូងនោះគឺថាមនុស្សមកពីចម្ការកៅស៊ូ ដែលមកជួបលោក ខៀវ សំផន នៅក្រសួង ហើយក្រសួងហ្នឹងតើក្រសួងណា? តើលោកអាចជម្រាបបានទេ?

[១១:៤១:៥៤]

**ឆ៖** កន្លែងហ្នឹងដែលចាំបានខ្លះ គឺកន្លែងពាណិជ្ជកម្មក្រៅប្រទេស។ អង្កាល់នោះលោក វន វ៉េត អត់នៅ។ កន្លែងហ្នឹងកន្លែងបើតាមនេះនាទីរបស់លោក វន វ៉េត ប៉ុន្តែដល់លោក វន វ៉េត អត់នៅក៏លោក ខៀវ សំផន ទៅជំនួស ឬក៏ម៉េចទៅ ព្រោះខ្ញុំក្ដាប់មិនបាន វាស្រាប់តែឃើញនៅហ្នឹង។

**ស៖** តើលោកបានដឹងឬទេ ថាតើ ខៀវ សំផន តែងតែធ្វើការនៅក្នុងមន្ទីរនោះ? បើសិនជាលោកមិនដឹងសូមប្រាប់ថាមិនដឹងបាទ។

**ឆ៖** ខ្ញុំមិនដឹងទៅវែងឆ្ងាយទៀតទេ គ្រាន់តែទៅឃើញមួយពេលហ្នឹង។ ពីមុនមកក៏មិនដឹង តទៅទៀតក៏មិនដឹង។ ដឹងតែពេលឃើញហ្នឹង ប៉ុណ្ណឹង។

**ស៖** នៅពេលដែលមនុស្សដែលមកពីខេត្តកណ្ដាលមកជួបលោក ប្រាប់អំពីរឿងទឹកជំនន់ ហើយសូមឲ្យលោកទាក់ទងថ្នាក់លើ តើលោកដឹងដូចម្ដេចថា លោកត្រូវទៅទាក់ទងលោក ខៀវ សំផន នោះ?

**ឆ៖** ខ្ញុំមានក្មួយប្រសាមួយនៅជាប់ហ្នឹង ជាប់ជាមួយលោក ខៀវ សំផន។ ដូច្នេះទាក់ទងតាមរយៈហ្នឹង ឈ្មោះ សេន។ ទាក់ទងតាមរយៈហ្នឹង ហៅថារបៀបមនោសញ្ចេតនាទេ ថាធ្វើម៉េចឲ្យបានឲ្យដំណឹងទៅលើ។

[១១:៤៤:០៧]

**ស៖** តើលោកដឹងថា តើលោក ខៀវ សំផន មានឈ្មោះហៅក្រៅអ្វីទេ នៅក្នុងសម័យកាលនោះ?

**ឆ៖** សម័យកាលនោះខ្ញុំអត់ដឹងទេ។ ប៉ុន្តែដល់មកក្រោយវែងឆ្ងាយ ៨០, ៩០ ហើយទេ បានដឹងថាមាននាមហៅខាងក្រៅ។ បើកាលសម័យនោះអត់ដឹងទេ។

**ស៖** ថាតើលោកនៅចាំទេ ឈ្មោះហៅក្រៅនោះ គេហៅថាអ្វី?

**ឆ៖** ហៅក្រៅមកក្រោយមកឮ តាម៉ុក ហៅ មិត្តហែម១។

**ស៖** ថាតើលោកដឹងទេ នៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ថាតើតាម៉ុក បានជួបលោក ខៀវ សំផន ដែរឬទេ?

**ឆ៖** តាមការសន្និដ្ឋាន ជួប បើទៅខាងលើមិនដឹងយ៉ាងម៉េចទេ តែទៅជួបខាងលើដូចគ្នាហើយ។ អាហ្នឹងក្នុងការសន្និដ្ឋានទេ។ ហើយយើងខាងក្រោម អត់ដឹងទេ អាខាងលើទៅជួបអ្នកណាខ្លះៗ ហ្នឹងមិនដឹងទេ។ ដោយការសន្និដ្ឋាន។ ប៉ុន្តែជួបកម្រិតណាៗ ថ្នាក់ណាយ៉ាងម៉េច មិនដឹងដល់ទេ។

**ស៖** សូមអរគុណ។ លោកបាននិយាយនៅឱកាសមួយ ដែលលោកបានជួបលោក ខៀវ សំផន នោះ លោកបានពិភាក្សាជាមួយគាត់អំពីការប្រើឧបករណ៍សាមញ្ញៗ ហើយមិនត្រូវប្រើឧបករណ៍ឧស្សាហកម្មទេ។ តើលោក ខៀវ សំផន ឆ្លើយតបដូចម្ដេច នៅពេលដែលជួបនិយាយពីរឿងឧបករណ៍សាមញ្ញ ដោយមិនប្រើរបស់ទំនើបនោះ គាត់ថាម៉េច មកលោកវិញ?

[១១:៤៦:៤៣]

**ឆ៖** រីករាយ ស្របគ្នា ចាត់ចែងឲ្យយកទៅតែម្ដង។ ហើយដឹកយកទៅខាងៗ អង្គតាសោម ហ្នឹងមុនគេ បើខ្ញុំត្រូវទៅហ្នឹង ដឹករណា ដឹកស្ទីៗ អារបស់សាមញ្ញ។ ចាត់ចែងការងារហ្នឹង ជាចម្លើយឯកភាព។

**ស៖** មុននឹងបញ្ចប់បញ្ហានេះ ខ្ញុំចង់សួរលោក ថាតើៗឧបករណ៍រោងចក្រអ្វីខ្លះ ដែលមិនត្រូវយកទៅប្រើនោះ បើតាមលោកដឹងនៅកាលនោះ?

**ឆ៖** រោងចក្រភូមិភាគនិរតី គឺមានរោងចក្រនៅឯ (ឮមិនច្បាស់) នៅឯព្រៃណោះ។ ប៉ុនបម្រើសេចក្ដីត្រូវការរបស់ប្រជាជនមិនគ្រប់គ្រាន់។ បានខ្ញុំជាជួបខាងលើ សុំឱ្យ បើខាងឃ្លាំងរដ្ឋមានរបស់ធម្មតា ដែលប្រជាជនប្រើប្រាស់ពីមុនមក គឺសុំយកទៅប្រើជំនួយ កុំឱ្យចាំតែរោងចក្រនោះ ឱ្យទាន់សេចក្ដីត្រូវការ។ ហើយសុំថែមត្រង់ហ្នឹងបន្តិចទៀត វាប្រហែលគ្នា។ សូម្បីតែសំបកដប ក៏ខ្ញុំស្នើទៅដែរ។ ឃើញនៅសល់ យកទៅដាក់ទឹកត្រី ចែកប្រជាជន។ ហ្នឹងថែមត្រង់ហ្នឹងតិច បាទ។ ព្រោះសំបកទាំងកេះៗ ហើយអ្នកធ្វើទឹកត្រី កំពង់ឃ្លាំង កំពង់អំពិល នៅក្បែរបឹងនោះ វាអត់អីដាក់ចែកប្រជាជន។ វាអ៊ីចឹង។

**ស៖** អ្វីដែលលោកបានរៀបរាប់រហូតដល់ពេលនេះ តាមដែលខ្ញុំយល់ តើត្រូវដែរឬទេ ថា ខៀវ សំផន លោក ខៀវ សំផន ជាអ្នកអនុញ្ញាតឱ្យយកប្រើ ឱ្យយកសម្ភារៈមួយចំនួនទៅប្រើ ឬក៏មិនឱ្យយកទៅប្រើ? តើអ៊ីចឹងដែរឬទេ?

[១១:៤៩:១៣]

**ឆ៖** ចម្លើយខ្ញុំអំមិញ ថាលោកឯកភាព។ ហើយចាត់ចែងឱ្យយកទៅ បានយកទៅ ចែកដល់ប្រជាជនហើយ។ លោកយល់ស្រប លោកឯកភាព រីករាយ ព្រោះរបស់ហ្នឹងវានៅសល់ សល់ទំនេរ។ អ៊ីចឹងយកទៅឱ្យប្រជាជនប្រើប្រាស់ចាត់ចែង។ ហ្នឹងខ្ញុំបញ្ជាក់លើកមុនហើយ ឥឡូវសូមបញ្ជាក់ថែមបន្តិចប៉ុណ្ណឹង។

**ស៖** សូមអរគុណ ដែលលោកបានបញ្ជាក់ បាទ បំភ្លឺនូវចំណុចនេះ។ នៅពេលដែលលោកនៅភូមិភាគនិរតី នៅមន្ទីរ-- បាទ មន្ទីរភូមិភាគនិរតី។ ប៉ុន្ដែនៅភ្នំពេញនោះ តើមានមនុស្សផ្សេងៗទៀតមកពីភូមិភាគនិរតី ក្រៅពី តាម៉ុក ពួកគាត់នោះមកភ្នំពេញដែរឬទេ ដែលថា មកប្រជុំ ឬក៏មកធ្វើការងារអីផ្សេង?

**ឆ៖** ខាង-- ជាពិសេសខាងតំបន់ ខាងខេត្ត ថ្នាក់ខេត្ត ថ្នាក់កងពល អាចដល់ថ្នាក់ស្រុកដែរ ប៉ុន្ដែកុំអាលថា ដល់ហ្នឹងទៅក្រែងច្រឡំ។ និយាយត្រឹមខេត្ត ត្រឹមកងពល គឺត្រូវការមកធ្វើការនៅឯលើ មកជួបលោក ប៉ុល ពត ណែនាំផ្ទាល់ ប៉ុន្ដែអាហ្នឹង គ្រាន់តែឮៗមកទេ យើងមិនបានឃើញផ្ទាល់ទេណា គ្រាន់តែដឹងថាទៅជួបអង្គការខាងលើ ទៅរៀនទៅសូត្រ ហើយតែមកគឺថា ភូមិភាគនិរតី ត្រូវចូលផ្ទះខ្ញុំហើយ ហើយបើមាននិរសារ កងការពារជូនឡានមក មកឈប់ឡានហ្នឹង មិនមែនឡានហ្នឹងទៅរហូតដល់ទេ។ មានឡានគេផ្សេងមកយកបន្តពីហ្នឹងទៅ ដល់ចេញពីធ្វើការវិញបានឡានខាងលើនោះជូនមក

ដល់ហ្នឹង បានបន្តដំណើរទៅកន្លែងវិញ។

[១១:៥១:៥៧]

**ស៖** តើលោកអាចនៅចាំបានដែរឬទេ អំពីឈ្មោះនៃអ្នកទាំងអស់នេះ ដែលតែងតែមកប្រជុំនៅភ្នំពេញ ហើយទៅកន្លែងលោកនោះ?

**ឆ៖** ពួកខេត្តនៅក្នុងភូមិភាគនិរតី ប្រធានខេត្តតាកែវ មុនដំបូងឈ្មោះ-- ហ្នឹងហើយឈ្មោះៗសោម។ ខេត្តកណ្ដាល ឈ្មោះ ជា, ឈ្មោះ ប្រាក់ ប៉ុន្តែសុទ្ធតែស្លាប់បាត់អស់ហើយ។ ខាងកំពង់ឆ្នាំង ឈ្មោះ យឹម ហ្នឹងក៏ស្លាប់ដែរ កំពង់ឆ្នាំង។ ខាងកំពង់ស្ពឺ នៅនឹកមិនឃើញ នឹកឃើញតែខាងភូមិភាគខាងក្រោយ គឺនឹកមិនឃើញទេ ខាងតំបន់នៅកំពង់ស្ពឺ។ ប៉ុណ្ណឹងជាដើម។

**ស៖** តើបុគ្គលម្នាក់ឈ្មោះ ជូ ជេត ហៅ ស៊ី ធ្លាប់មកភ្នំពេញ ហើយឆៀងចូលទៅមន្ទីររបស់លោកទេ?

**ឆ៖** ជូ ជេត ហៅ ស៊ី ហ្នឹង កាលនេះនៅរួម ភូមិភាគនិរតី ដល់មកក្រោយមកបែកទៅខាងបស្ចិម ទៅប្រធានបស្ចិម។ ប៉ុន្តែកន្លែងនៅជិតគ្នា កន្លែងមន្ទីរបស្ចិម ហើយនិងខ្ញុំហ្នឹង នៅជិតគ្នា។ ហើយលោក ជូ ជេត ហ្នឹងគឺអ្នកធ្លាប់បួស ធ្លាប់អី ក៏ធ្លាប់ស្គាល់ខ្ញុំតាំងពីនៅបួសមក។ ជួបក្រៅផ្លូវការ។ ជួបគ្នាក្រៅផ្លូវការនិយាយលេងពីនេះពីនោះ តាមដំណើរអ្នកបួស។ ប៉ុន្តែខាងភូមិភាគបស្ចិម។

**ស៖** តើលោកស្គាល់ប្រពន្ធរបស់ ជូ ជេត ដែរទេ? គាត់រៀបការប្រពន្ធ ហើយប្រពន្ធឈ្មោះអ្វី?

[១១:៥៥:០៥]

**ឆ៖** ពីមុនចាំ ឥឡូវនឹកមិនឃើញ។ ពីមុនស្គាល់ឈ្មោះហ្នឹង ប៉ុន្តែឥឡូវនឹកអត់ឃើញ។

**ស៖** បើខ្ញុំប្រាប់ឈ្មោះ តើលោកអាចប្រាប់ខ្ញុំថា តើឈ្មោះដែរឬទេ? ឈ្មោះៗគាត់ អ៊ឹម និន (ស៊ីក) ហៅ លី តើអ៊ីចឹងទេ?

**ឆ៖** ហ្នឹងហើយឈ្មោះ លី អ៊ីចឹងហើយ លី។

**ស៖** តើលោកនៅចាំដែរឬទេថា គាត់មានមុខតំណែង ឬក៏តួនាទីអីទេក្នុងសម័យនោះ?

**ឆ៖** ខ្ញុំដឹងមិនដល់ទេ ព្រោះភូមិភាគផ្សេងគ្នា។ ដឹងអត់ដល់ទេ មិនបានដឹងថាម៉េចៗទេ។

**ស៖** លោកស្គាល់ ជូ ជេត ហើយលោកបានជជែកជាមួយគាត់ម្ដងម្កាល។ តើលោកដឹងទេគាត់មានបញ្ហាអ្វីបន្ទាប់ពីនោះ មកនោះ?

[១១:៥៦:២៩]

**ឆ៖** គ្រាន់តែឮថាមានៗ ប៉ុន្តែមិនដឹងម៉េចទេ ស្រាប់តែបាត់ទៅ។ យើងដឹងយកជាការជាផ្លូវការ តាមតុលាការមិនបាន ដឹងតៗ។

**ស៖** តើលោកបានដឹងអ្វីខ្លះអំពីប្រពន្ធរបស់គាត់? តើប្រពន្ធរបស់គាត់នោះមានបញ្ហាដូចម្ដេចដែរ?

**ឆ៖** មិនបានដឹងទេ ហើយបើលោក ជូ ជេត ហ្នឹងដឹងហួសពីធម្មតាហ្នឹង ដឹងថាគាត់វះ ហើយកាត់ប្រមាត់ ដឹងដល់ក្នុងតិចទៀត។ សុខភាពខ្សោយ កាត់ប្រមាត់។ ហើយប្រពន្ធនោះ មិនបានដឹងថាតមកទៀតយ៉ាងម៉េចអត់ដឹងទេ។

**ស៖** សូមអរគុណលោកសាក្សី។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំជម្រាបថានៅក្នុងឯកសារដែលខ្ញុំបានអានខាងដើម ដើម្បីតំណត់ត្រាតុលាការ។ ជូ ជេត មានចម្លើយសារភាពរបស់គាត់ គឺឯកសារ IS5.15។ ហើយបញ្ហាពាក់ព័ន្ធដែរ គឺឯកសារនេះ E3/1098 ដែលទាក់ទងទៅនឹងការចាប់ខ្លួនប្រពន្ធរបស់គាត់ គឺ E3/108 ហើយនៅចុងបញ្ចប់គឺ ទាំងពីរនាក់គឺថាមកស្ថិតនៅក្នុងបញ្ជីអ្នកទោសស-២១ គឺឯកសារ D288/6.68.1។ ជូ ជេត នៅក្នុងលេខទំព័រ 105, អ៊ឹម ណេន ហៅ លី គឺថានៅក្នុងលេខ 2896 ជាលេខរៀងនៅក្នុងបញ្ជីអ្នកទោសនោះបាទ។

[១១:៥៨:៥៣]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ខៀវ នៅ នៅពេលដែលមនុស្សទាំងអស់នោះ ដែលមកភ្នំពេញមកប្រជុំ លោកនិយាយថាតែងតែមាននីរសារ អង្គរក្សមកជាមួយផង។ តើលោកបានដឹងទេថា ពួកគាត់មកប្រជុំនៅកន្លែងណា?

**លោក ខៀវ នៅ៖**

**ឆ៖** ខ្ញុំសូមជម្រាប ភ្នំពេញសម័យបីឆ្នាំហ្នឹង មិនមែនចេះតែដើរបានសព្វកន្លែងទេ។ ផ្លូវណាជាផ្លូវសាធារណៈ ទៅតែកៀនកោះត្រង់នេះត្រង់នោះ គឺមិនបានដើរទៅទេ។ ដូច្នេះគ្រាន់តែឮថាទៅខាងលើៗហ្នឹងមិនដឹងត្រង់ណាទេ អត់ដឹងទេ។ បើអ្នកដែលធ្លាប់ទៅៗកន្លែងនុ៎ងបានដឹង ហើយអ្នកដែលមិនទាន់ដល់ថ្នាក់ទៅ អត់ដឹងទេ។ អ៊ីចឹងអ្នកធ្វើការនៅកន្លែងហ្នឹងបានដឹង ឯខ្ញុំអ្នកក្រៅ ហើយថ្នាក់ទាបមិនអាចទៅដឹងបានទេ។

**ស៖** សូមអរគុណ។ សំណួរមួយចុងក្រោយទៅលើបញ្ហានេះ។ តើលោកបានដឹង ហើយបើមិនដឹងសូមលោកប្រាប់ខ្ញុំផង។ តើគោលបំណងនៃការមកប្រជុំរបស់អ្នកទាំងអស់នេះ តើគោលបំណងនៃការមកប្រជុំនេះ គឺប្រជុំដើម្បីធ្វើអ្វី?

**ឆ៖** និយាយតាមការសន្និដ្ឋានទៅ ព្រោះយើងក៏មិនមែនប្រធានដែរណា។ ប៉ុន្តែសន្និដ្ឋាន តាមការសន្និដ្ឋាន។ ប្រជុំៗការងារគ្រប់គ្រងរដ្ឋហ្នឹង របៀបរបបបដិវត្តន៍ហ្នឹងត្រូវធ្វើយ៉ាងម៉េចៗ។ អាហ្នឹងយើងបានឃើញឯកសារអីផង បានប៉ាននិយាយអ៊ីចឹង។ ព្រោះឯកសារក៏បញ្ជាក់អ៊ីចឹងដែរ បញ្ជាក់ពីមាគ៌ាអីយ៉ាងនេះយ៉ាងនោះ។ មាគ៌ាប្រជាជន មហាជនស្អីត្រូវយ៉ាងម៉េចៗ គឺយោលទៅតាមឯកសារខ្លះ។ មានអីក្រៅពីមាគ៌ាបដិវត្តន៍ របៀបគ្រប់គ្រងរដ្ឋ កសាងប្រទេស ការពារប្រទេសទេ អាហ្នឹង។

**ស៖** សូមអរគុណលោក ខៀវ នៅ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំត្រូវការប្រហែល ១០ ឬ១៥នាទីទៀត ដើម្បីបញ្ចប់។ សូមការអនុញ្ញាតពីតុលាការ ខ្ញុំសូមបន្តបន្ទាប់ពីអាហារថ្ងៃត្រង់បាទ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោក ខៀវ នៅ។ ឥឡូវនេះសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល និងផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីក្នុងអំឡុងពេលសម្រាកពិសាអាហារថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ នៅវេលាម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី!

[១២:០២:៣៧]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំចង់តាមដានសវនាការនៅបន្ទប់ខាងក្រោមនេះ នៅល្ងាចនេះ ហើយខ្ញុំមានលិខិតបោះបង់សិទ្ធិដើម្បីជូនតុលាការតាមនីតិវិធី បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់សុំនៅ-- ទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់កិច្ចដំណើរការសវនាការនៅរសៀលនេះ។ គាត់លះបង់សិទ្ធិចូលរួមដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។ ក្រុមមេធាវីការពារក្តីបានសន្យាថា ខ្លួននឹងប្រគល់មកអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ។

អង្គជំនុំជម្រះសម្រេចយល់ព្រម តាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលកិច្ចដំណើរការសវនាការពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ។

[១២:០៣:៤២]

អង្គជំនុំជម្រះតម្រូវឲ្យមេធាវីការពារក្តីជនជាប់ចោទ នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការនៅរសៀលនេះ។

អនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយនៅរសៀលនេះ ទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែក លោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៥ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣១:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយព្រឹកមិញមុននឹងចប់--សម្រាកអាហារថ្ងៃត្រង់ ឃើញខាងតំណាងសហព្រះរាជអាជ្ញាបានស្នើសុំនូវពេលវេលាចំនួន១៥នាទីដើម្បីតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះជាបន្ត។

ឥឡូវនេះ អង្គជំនុំជម្រះអនុញ្ញាតសម្រេចឲ្យប្រាំនាទីទៀត ដើម្បីមានឱកាសក្នុងការតាំងសំណួរបញ្ចប់របស់ខ្លួនមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៣:៣៣:០០]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ខៀវ នៅ ខ្ញុំនឹងប្រើពេលប្រាំនាទីនេះ ដើម្បីឲ្យបានអត្ថប្រយោជន៍ល្អបំផុត។ លោកបាននិយាយពីខាងដើមថា ថាលោកបានជួបលោក ខៀវ សំផន ពីរដង។ ហើយទីមួយដែលលោកបានជួបគាត់នោះ គឺនៅពេលដែលលោកពិភាក្សាជាមួយគាត់អំពីសេចក្តីត្រូវការរបស់ប្រជាជននៅខេត្តបាត់ដំបង។ តើលោកនៅចាំដែរឬទេ លោកជួបគាត់នៅឆ្នាំ នៅឆ្នាំ១៩៧៦? ១៩៧៧? ឬក៏១៩៧៨?

**លោក ខៀវ នៅ៖**

**ឆ៖** មិនចាំច្បាស់ទេ។ ប៉ុន្តែប្រហែលជាឆ្នាំ៧៧ ឬចុងឆ្នាំ៧៧។

**ស៖** ពេលដែលលោកជួបគាត់ទីពីរ ជួបលោក ខៀវ សំផន នោះនិយាយអំពីបញ្ហាទឹកជំនន់នៅខេត្តកណ្តាល តើស្ថិតនៅក្នុងឆ្នាំ១៩៧៧ ឬក៏នៅក្នុងឆ្នាំណា?

**ឆ៖** នេះ ក៏មិនចាំដែរ។ ប៉ុន្តែពេលហ្នឹង ភ្លៀងខ្លាំង ទឹកជន់ធំ។ មិនចាំទេ មិនចាំឆ្នាំទេ។

**ស៖** តើលោកនៅចាំឆ្នាំទេនៅឆ្នាំ១៩៧៧, ១៩៧៨ ឬក៏ឆ្នាំណាបាទ?

[១៣:៣៥:០០]

**ឆ៖** នឹកមិនឃើញ ខ្ញុំនឹកមិនឃើញ មិនចាំទេច្របូកច្របល់ ៧៧ ឬ៧៨ ហ្នឹង។ មិនច្បាស់ ប៉ុន្តែ អាចក្នុងពីរឆ្នាំហ្នឹង។

**ស៖** សំណួរចុងក្រោយអំពីបញ្ហានេះ តើលោកនៅចាំទេ នៅពេលណាមួយក្នុងឆ្នាំ មុនរដូវវស្សា ឬក៏រដូវក្នុងពាក់កណ្ដាលរដូវវស្សា ឬក៏ចំណុចណាមួយ?

**ឆ៖** ជួបទឹកជំនន់រដូវវស្សា ទឹកកំពុងតែជន់ខ្លាំង។ ក្នុងរដូវវស្សា។

**ស៖** សូមអរគុណ។ ខ្ញុំចង់ឲ្យលោកបំភ្លឺ អំពីទិដ្ឋភាពមួយនៅក្នុងចម្លើយរបស់លោកទៅសហចៅក្រមស៊ើបអង្កេតនោះ ហើយមុននឹងធ្វើបែបនោះ ខ្ញុំសួរសំណួរសង្ខេបមួយ លោកបាននិយាយថា លោកបានដឹងថា វន វ៉េត ទទួលបន្ទុកខាងសេដ្ឋកិច្ច ខាងផ្នែកខាងពាណិជ្ជកម្ម មុនពេលដែលគាត់បាត់ខ្លួន ហើយលោកក៏បាននិយាយផងដែរ ថាក្រោយដែល វន វ៉េត បាត់ខ្លួនទៅ លោកបានឃើញលោក ខៀវ សំផន នៅក្រសួងពាណិជ្ជកម្មក្រៅប្រទេស។ តាមអ្វីដែលលោកដឹងនោះ តើលោក ខៀវ សំផន បានទទួលតំណែងបន្តអ្វីពីអ្នកដែលបាត់ខ្លួននោះដែរឬទេ?

[១៣:៣៦:៥០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវីការពារក្ដី!

**លោក អាកទូរ វ៉ែកគែន៖**

បាទ លោកប្រធាន។ ខ្ញុំសូមជំទាស់ ពីព្រោះថានៅក្នុងសំណៅជាភាសាបារាំង ហាក់ដូចជាសាក្សីហ្នឹងមិនបាននិយាយថា គាត់បានជួប ឬក៏គាត់បាននិយាយដោយចេញការសន្និដ្ឋានថា គាត់ជួបលោកខៀវ សំផន នៅក្រោយពេលដែល វន វ៉េត បាត់ខ្លួននោះទេ។ ព្រោះថា អានេះ យ៉ាងហោចណាស់ក៏ជាភាសាបារាំងខ្ញុំស្ដាប់អត់មានឮថានិយាយដូច្នេះនោះទេ។ ខ្ញុំគិតថា សហព្រះរាជអាជ្ញាប្រហែលជាកំពុងតែបំប្លែងពាក្យសម្ដីរបស់សាក្សីហើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន នៅកំណត់ហេតុរបស់ខ្ញុំ ខ្ញុំមិនទាន់មានប្រតិចារឹកទេ ប៉ុន្តែកំណត់ហេតុរបស់ខ្ញុំនោះគឺថា សាក្សីនិយាយថា គាត់បានឃើញ ខៀវ សំផន នៅក្រសួងពាណិជ្ជកម្មក្រៅប្រទេសនៅពេលដែល វន វ៉េត អវត្តមាន ខៀវ សំផន មកជំនួស។ ខ្ញុំយល់ថា ខ្ញុំផ្ដល់សេចក្ដីសន្និដ្ឋានដ៏ត្រឹមត្រូវ ដែល

លោកសាក្សីបានឆ្លើយព្រឹកនេះនោះបាទ។

[១៣:៣៨:១០]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីការពារក្តីគ្មានប្រសិទ្ធភាព។ សាក្សីត្រូវឆ្លើយតបនឹងសំណួរដែលសួរចុងក្រោយដោយតំណាងសហព្រះរាជអាជ្ញា!

**លោក ខៀវ នៅ៖**

**ឆ៖** ចម្លើយនេះ ខ្ញុំគ្រាន់តែមិនបានជម្រាបថា សន្និដ្ឋាន ប៉ុន្តែក្នុងន័យសន្និដ្ឋាន មិនមែនក្នុងន័យច្បាស់លាស់ទេ ដែលឆ្លើយថាមកតំណាងលោក វន វេត នោះ។ ប៉ុន្តែខ្ញុំមិនបានជម្រាបថា តាមសន្និដ្ឋានទេ។ តែក្នុងន័យសន្និដ្ឋាន មិនមែនក្នុងន័យច្បាស់លាស់ទេ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** បាទ អរគុណចំពោះដែលលោកសាក្សីបានឆ្លើយ។ ខ្ញុំសល់មួយនាទី ហើយខ្ញុំនឹងសួរលោកសំណួរចុងក្រោយ ពីខាងដើម លោកដែលពេលលោករៀបរាប់អំពីមនុស្សដែលមកពីខាងនិរតី មកចូលរួមការប្រជុំនៅភ្នំពេញ លោកបាននិយាយ លោកនិយាយថាឈ្មោះ ប្រាក់ មកពីខេត្តកណ្តាល។ ខ្ញុំគ្រាន់តែចង់ឲ្យលោកបំភ្លឺថាតើឈ្មោះពេញរបស់បុគ្គលនោះគឺថា សេក សាត ឈ្មោះ ប្រាក់ ហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំមិនបានដឹងឈ្មោះពេញទេ។ ដឹងតែឈ្មោះហ្នឹងហៅ ឈ្មោះផ្ទាល់ហ្នឹងហៅ ប្រាក់ អ៊ីចឹងតែម្តង។ ឯនាមត្រកូលយ៉ាងម៉េចៗ ខ្ញុំមិនដឹងទេ។

**ស៖** លោកថា គាត់មកពីខេត្តកណ្តាល តើលោកដឹងទេថា គាត់កាន់តំណែងអីនៅខេត្តកណ្តាលនោះ?

[១៣:៤០:០៧]

**ឆ៖** ន៎ែ ជាគណៈកម្ម-- ប្រធានគណៈកម្មការខេត្តកណ្តាល។

**លោក អាប់ឌុលឡាក់ ថារីក៖**

ហើយដោយសារពេលវេលា ខ្ញុំសូមអរគុណចំពោះចម្លើយពិស្តាររបស់លោក លោក ខៀវ នៅ ហើយសូមអរគុណអង្គជំនុំជម្រះ លោកប្រធានផងដែរ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៣:៤០:៤៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណលោកប្រធាន។ ដើម្បីកំណត់ប្រតិចារឹកនៅក្នុងសំណៅជាភាសាបារាំងនៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកសាក្សី គឺថាឯកសារ D166/183 ទំព័រ៥ សាក្សីនេះបាននិយាយដូចតទៅនេះ៖ “ខ្ញុំបានជួបលោក ខៀវ សំផន នៅការិយាល័យពាណិជ្ជកម្មក្រៅប្រទេស នៅពេលដែលខ្ញុំទៅរកសម្ភារៈដែលខ្ញុំត្រូវចែកចាយទៅប្រជាជននៅតាមសហករណ៍។ នៅពេលនោះ ខ្ញុំបានដឹកសម្ភារៈទាំងនោះទៅខេត្តតាកែវ។ បន្ទាប់ពី វន វ៉េត បានបាត់ខ្លួន ប្រហែលជានៅឆ្នាំ១៩៧៧ ខៀវ សំផន បានឡើងជំនួស វន វ៉េត ទទួលបន្ទុកពាណិជ្ជកម្មក្រៅប្រទេស។ ខ្ញុំបានឮគេនិយាយថា គេបានចាប់ វន វ៉េត ដោយសារពាក់ព័ន្ធនឹងរឿង សេ.អ៊ី.អា និង កា.ហ្សេ.បេ ប្រហែលជានៅក្នុងឆ្នាំ១៩៧៦ មុនពេលខ្ញុំទៅទីក្រុងភ្នំពេញ ដែលពេលខ្ញុំបានជួប ប៉ុល ពត មួយដង ដែល-- ពេលដែលគាត់មកផ្ទះ តាម៉ុក នៅខេត្តតាកែវ បាទ”។

[១៣:៤២:១៨]

នេះអ្វីដែលច្បាស់លាស់ហ្នឹង គឺថាសាក្សីថា៖ “បន្ទាប់ពីបាត់ខ្លួន វន វ៉េត នៅឆ្នាំ១៩៧៧ គឺ ខៀវ សំផន បានមកជំនួសគាត់នៅ-- ទទួលបន្ទុកខាងពាណិជ្ជកម្មក្រៅប្រទេស”។

**លោក អាកទូរ វែកគែន៖**

បាទ ខ្ញុំគ្រាន់តែចង់និយាយថា ការកត់សម្គាល់របស់ខ្ញុំ មិនមែនយោងទៅនឹងកំណត់ហេតុស្តាប់ចម្លើយទេ។ គឺថា ខ្ញុំចង់យោងទៅអ្វីដែលសហព្រះរាជអាជ្ញានិយាយ ហើយខ្ញុំស្គាល់ពីកំណត់ហេតុស្តាប់ចម្លើយនេះហើយ។ ការជំទាស់ខ្ញុំក្រៅខុសពីនេះទេ ក៏ប៉ុន្តែខ្ញុំចង់និយាយថា ខ្ញុំចង់ឲ្យខាងផ្នែកប្រតិចារឹកហ្នឹងបកប្រែខ្សែអាត់នៃកំណត់ហេតុនេះដែលធ្វើដោយសហចៅក្រមស៊ើបអង្កេត ព្រោះថាមានភាពខុសគ្នា មានចំណុចមួយចំនួនដែលមាននៅក្នុងខ្សែអាត់ ហើយពុំមាននៅក្នុងនៃ កំណត់ហេតុស្តាប់ចម្លើយនេះ។ អ៊ំ ខ្ញុំសូមទោស គឺថាមានអ្វីដែលមាន-- ពុំមាននៅក្នុងខ្សែអាត់ ប៉ុន្តែមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយនេះ។ ឧទាហរណ៍ពាក្យ “ក្រសួង” ឬក៏ពាក្យ “សេ.អ៊ី.អា, កា.ហ្សេ.បេ” ជាដើមនេះ។ នេះគឺថា គឺឯកសារលេខ D166/183.1។

[១៣:៤៣:៥៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ អ្វីដែលខ្ញុំចង់ដឹង ថាតើអ្វីដែលខ្ញុំបានអាននោះ វាខុសពីអ្វីដែល-- ខុសពីខ្សែអាត់នោះ ឬក៏យ៉ាងម៉េច? បើមិនមែនជារឿង-- បើមិនមែនដូច្នេះទេ អ្វីដែលលោកលើកឡើងអំមិញនេះ ចាប់-- គួរឲ្យចាប់អារម្មណ៍ដែរ ប៉ុន្តែមិនមែនជាការសមស្របនោះទេ។

**លោក អាកទួរ វែកកែន៖**

បាទ ពាក្យដែលបកប្រែដោយអ្នកបកប្រែនៅតុលាការយើងនេះ ទាក់ទងទៅនឹងការបន្តតំណែងដោយ-- លោក វន វ៉េត ដោយលោក ខៀវ សំផន ខ្ញុំសូមលើកវគ្គនេះ វគ្គដែលបានបកប្រែនេះមកអានជូន។ "សំណួរ៖ តើលោកបានជួបអ្នកផ្សេងទៀតទេ? ចម្លើយ៖ ខ្ញុំដូចជាមិនដែលបានជួបទេ ប៉ុន្តែខ្ញុំបានជួបលោក ខៀវ សំផន នៅ--"។ ហើយមានបើកវង់ក្រចក ហើយមានចំណុចមួយចំនួនប្រហែលជាស្តាប់អត់ឮ "ខៀវ សំផន ទទួលបន្ទុកខាងសម្ភារៈបន្ទាប់ពី វន វ៉េត ហ្នឹងត្រូវបានចាកចេញទៅ។ នេះគឺជាពាក្យសម្តីដែលខ្ញុំបានស្តាប់ឮនៅក្នុងខ្សែអាត់ ហើយឃើញថាមានខុសគ្នានៅក្នុងកំណត់ហេតុ។ ដូចនៅក្នុងកំណត់ហេតុដែលលោកចៅក្រមបានអានអម្បាញ់មិញនេះ គឺមានសរសេរ សេ.អ៊ី.អា និង កា.ហ្សេ.បេ ក៏ប៉ុន្តែនៅពេលដែលយើងអានប្រតិចារឹកជាខ្សែអាត់នោះ មិនដែលមានឃើញមានលោកសាក្សីនេះ និយាយពី សេ.អ៊ី.អា ឬក៏ កា.ហ្សេ.បេ នោះទេ។

[១៣:៤៥:៥១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ តំណាងសហព្រះរាជអាជ្ញា សហភាគី និងសាធារណជនទាំងអស់។ ខាងតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីពីរនាក់ គឺរូបខ្ញុំ ហើយនិងលោក បាណាបេ នឹងលើកជាសំណួរសម្រាប់លោកសាក្សីមួយរូបនេះ។ ហើយយើងខ្ញុំប្រហែលជាចំណាយរយៈពេល៣៥នាទី ទៅ៤៥នាទី តែប៉ុណ្ណោះបាទ។

[១៣:៤៦:៤៤]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** អ៊ីចឹង ខ្ញុំសូមអនុញ្ញាតចាប់ផ្តើមសំណួរ។ ជម្រាបសួរលោក អ៊ំ យើងខ្ញុំជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះនៅក្នុងសម័យខ្មែរក្រហម។ យើងមានសំណួរមួយចំនួនសម្រាប់សួរលោកអ៊ំ ដើម្បីឲ្យលោកអ៊ំបំភ្លឺ ជាដំបូងគឺនៅ-- សម្រាប់រយៈពេលមុនឆ្នាំ១៩៧៥។ សំណួរទីមួយ ចង់សុំសួរលោកអ៊ំថា តើលោកអ៊ំមានបានដឹងអ្វីខ្លះអំពីចលនាឥស្សរៈនៅសម័យមុនឆ្នាំ១៩៧៥? តើលោកអ៊ំអាចពន្យល់-- អឺ! និយាយបានទេ?

[១៣:៤៧:៣៦]

**លោក ខៀវ នៅ៖**

**ឆ៖** សូមជម្រាបលោក ចលនាដែលហៅថា ឥស្សរៈតាំងពីឆ្នាំសែប្លាយមក តាំងខ្ញុំនៅក្មេង។ ហ្នឹង ដែលហៅថា "ឥស្សរៈ"។ ឥស្សរៈ ហ្នឹង វាមានច្រើនបែប។ ឥស្សរៈ ពុទ្ធឆាយ, ឥស្សរៈ ដាបឈួន, ឥស្សរៈ ចាន់ រង្សី ហើយនៅខាងត្បូងនេះ ឥស្សរៈ សឹង ង៉ុកមិញ។ ហ្នឹងកាលដែលខ្ញុំនៅក្មេង។ ហើយដល់មកក្រោយមកពាក្យថា "ឥស្សរៈ" ហ្នឹង អត់មានប្រើទៀតទេ។ ដល់មក៦៧, ៦៨ មានពាក្យថា "ខ្មែរក្រហម" ប៉ុន្តែខ្មែរក្រហម បើពិនិត្យទៅ គឺមនុស្សដែលធ្លាប់ធ្វើឥស្សរៈហ្នឹងដដែល។ ហ្នឹងសូមជម្រាបដោយខ្លីតែប៉ុណ្ណឹង។

[១៣:៤៨:៤៤]

**ស៖** លោកអ៊ំ តើៗ លោកអ៊ំអាចបំភ្លឺបានទេ តើ តាម៉ុក មានទំនាក់ទំនងអ្វីខ្លះជាមួយនឹងចលនាឥស្សរៈនេះ? តើគាត់មានតួនាទីអ្វីនៅក្នុងនោះដែរឬទេ?

**ឆ៖** សូមជម្រាប ចលនាឥស្សរៈនេះ។ ឥស្សរៈចូលមកមុនដំបូង គាត់មិនបានទាក់ទងអីទេ ប៉ុន្តែគេចូលមកសួរប្រជាជន សួរអ្នកស្រុក រកអ្នកចេះ អ្នកដឹងអីគួរសម ក៏រៀបចំចាត់តាំង។ មាថ្លៃគាត់ហ្នឹង ធ្វើនាយកឃុំ ហើយគាត់ តួតាម៉ុក ហ្នឹង ធ្វើស្មៀនឃុំ។ ហ្នឹងក្នុងឥស្សរៈហ្នឹង។ ធ្វើហ្នឹងរហូតមកទល់នឹងសន្និសីទហ្សឺណែវ៥៤ បានចប់។ ចប់បាន គាត់មកចូលស្រុកវិញ។ ចូលស្រុករស់នៅរកស៊ីធម្មតា ដូចអ្នកស្រុកធម្មតា។ ហ្នឹងការងាររបស់គាត់។

**ស៖** បាទ លោកអ៊ំ ភូមិដែលលោកអ៊ំនៅក្នុងឃុំត្រពាំងធំនោះ ថាតើឈ្មោះភូមិអីដែរលោកអ៊ំ?

**ឆ៖** ភូមិកំណើត ឈ្មោះ ភូមិត្រពាំងគល់ នៅក្នុងឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ។

**សៈ** នៅអម្បាញ់មិញលោកអ៊ំនិយាយពាក់ព័ន្ធទៅនឹងការក្លាយទៅជាខ្មែរក្រហម។ លោកអ៊ំអាចជម្រាបបានទេ ថាតើលោកអ៊ំមានធ្លាប់ឮពាក្យនៅកន្លែងឃុំដែលអ៊ំស្នាក់នៅហ្នឹង ធ្លាប់មានឮពាក្យថាការតស៊ូរួមផ្សំអាវុធដែរឬទេលោកអ៊ំ?

[១៣:៥០:៥៨]

**ឆៈ** មានឮពាក្យ តស៊ូរួមផ្សំអាវុធហ្នឹង។ អាវុធរួមផ្សំនយោបាយ ហ្នឹងមាន។

**សៈ** តើអ្នកណាជាអ្នកប្រើពាក្យនេះ?

**ឆៈ** គ្រាន់តែឮតៗមកទេ តាំងពីណាពីណីវែងឆ្ងាយមក ខ្ញុំភ្លេចអស់ហើយ មិនដឹងរកសួរបុគ្គលមិនឃើញទេ។ បាទ នេះវាចេះថាច្រើនគ្នាទៅ រកអ្នកដើមពាក្យហ្នឹងរកមិនឃើញទេ។

**សៈ** លោកអ៊ំអាចបំភ្លឺបានទេ ថាតើនៅពេលចុងទសវត្សរ៍៦០ ដែលលោកអ៊ំបានមានប្រសាសន៍អម្បាញ់មិញ ថាតើមានមូលដ្ឋានបដិវត្តន៍អ្វីនៅក្នុងឃុំរបស់អ៊ំដែរឬទេ?

**ឆៈ** នៅក្នុងឃុំត្រពាំងធំគ្មានទេ។ ពួកខ្មែរក្រហមនៅព្រៃ នៅឯលិចភ្នំ ជាយខេត្តកំពតឯណោះ។ ឯនៅក្នុងឃុំតែម្តង គ្មានទេ។

**សៈ** បាទ អរគុណលោកអ៊ំចំពោះការបំភ្លឺ។ ខ្ញុំចូលទៅដល់ចំណុចផ្សេងមួយទៀត គឺពាក់ព័ន្ធទៅនឹងរឿងជម្លៀស។ លោកអ៊ំបានធ្លាប់ឆ្លើយជាមួយនឹងតំណាងការិយាល័យសហចៅក្រមស៊ើបអង្កេតថាមានផែនការនៅក្នុងការឲ្យលោកសង្ឃសឹក--

**លោក ពេជ អង្គ៖**

សូមទោសលោកប្រធាន ខ្ញុំនឹងលើកពីនៅក្នុងឯកសារ គឺឯកសារ D116/183។ ERN ជាភាសាខ្មែរ 00355440, ជាភាសាអង់គ្លេស 00358141 និងភាសាបារាំង 00408426។ សូមលោកប្រធានអនុញ្ញាតបញ្ចាំង ហើយសូម--

[១៣:៥៣:៤៨]

**ប្រធានអង្គជំនុំ៖**

លោកអាចដំណើរការប្រព្រឹត្តទៅក្នុងការដេញដោល ដូចសេចក្តីណែនាំអនុវត្តរបស់អង្គជំនុំជម្រះ ដែលបានចេញថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២។ ដូច្នេះការបញ្ចាំងមិនចាំបាច់ទេ។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** នៅក្នុងចម្លើយដែលលោកអ៊ំបានឆ្លើយ ជាមួយតំណាងការិយាល័យសហចៅក្រមស៊ើបអង្កេត លោកអ៊ំបានមានប្រសាសន៍ថា៖ "ផែនការឲ្យព្រះសង្ឃសឹកនេះមានតាំងពីយូរមកហើយ។ ហើយជាទូទៅលោកសង្ឃដឹងថា លទ្ធិកុម្មុយនីស្តមិនអនុញ្ញាតឲ្យមានលោកសង្ឃទេ។ ដូច្នេះលោកសង្ឃទាំងអស់មិនមានការភ្ញាក់ផ្អើលទេ"។ សំណួរចំពោះលោកអ៊ំ ថាតើលោកអ៊ំអាចពន្យល់បានទេថា ធ្វើយ៉ាងដូចម្តេចបានព្រះសង្ឃដឹងថា មានផែនការនៅក្នុងការផ្សឹកព្រះសង្ឃពីយូរមកហើយ?

[១៣:៥៤:៥១]

**លោក ខៀវ នៅ៖**

**ឆ៖** ចលនាកុម្មុយនីស្តវាចូលមកស្រុកខ្មែរតាំងពីឆ្នាំសែបាយមក តាំងខ្ញុំនៅក្មេងមិនទាន់ដឹងអីនោះ ខ្ញុំនៅវត្តចេះអក្សរបន្តិចបន្តួច។ ដឹងហើយ ដឹងថាកុម្មុយនីស្តហើយ។ ហើយមួយទៀត ខ្ញុំបួសនៅក្នុងឆ្នាំ៥៣ មកទល់៥៤ សន្និសីទហ្សឺណែវ ចេះគិត ចេះគូរខ្លះ។ មើលទស្សនាវដ្តីអាមេរិកាំងសរសេរផែនទីផ្សាយផែនទីពិភពលោកទាំងមូល ក្នុងប្រទេសណាដែលកាន់ពុទ្ធសាសនាគូសលឿង កាន់ច្រើនគូសច្រើន កាន់តិច គូសតិច។ ដល់ទៅមើលប្រទេសសូវៀតអត់មាន អត់មានខ្ញុំនិយាយជាមួយអ្នកតស៊ូដែលធ្វើឥស្សរៈ ខ្ញុំថា សូវៀតអត់មានពុទ្ធសាសនាទេ។ គេថា មាន ខ្ញុំថាមើលៗទស្សនាវដ្តីអ្នែ ហ្នឹងឆ្នាំ៥៤មក ដែលខ្ញុំចេះគិត ចេះគូរខ្លះមក តាំងពីអាយុ២០ មក។ បានទុនហ្នឹងហើយ ចេះតែគិតថែមដឹងដំណឹង ហើយមួយទៀត ធ្វើជុំវិញពិភពលោក យើងអ្នករៀន អ្នកសូត្រ យើងតែងតែឮហើយ បើមិនបានទៅរៀនអីមែន ក៏តែងតែឮហើយ កុម្មុយនីស្តចិន កុម្មុយនីស្តសូវៀត កុម្មុយនិស្តកូរ៉េ កុម្មុយនីស្តយូហ្គោស្លាវីអី យើងដឹងហើយ។

[១៣:៥៦:៤២]

**ស៖** បាទៗ។ សូមអរគុណលោកអ៊ំ ដែលដោយសារពេលវេលាខ្លី ខ្ញុំសូមកាត់លោកអ៊ំត្រង់នេះ។ លោកអ៊ំអាចជម្រាបបានទេ ថានៅពេលដែលព្រះសង្ឃលាសិក្ខាបទ ថាតើមានការធ្វើពិធីតាមសាសនានៅក្នុងការលាចាកសិក្ខាបទនេះដែរឬទេ?

**ឆ៖** ធ្វើពិធីត្រឹមត្រូវ តាមប្រពៃណី អត់ទាន់មានប្លែកអីទេ លាចាកមានឧបឈា មានសង្ឃមានអីទទួលខុសត្រូវ ពេលលាចាកសិក្ខាបទ តាមច្បាប់ព្រះពុទ្ធសាសនា តាមគម្ពីរព្រះពុទ្ធសាសនា។ មិនចេះតែសឹកពាសទឹកពាសដី ដូចពាក្យចាស់ថា សឹកដំបូកនោះទេ អត់ទេ។ មានអ្នកស្រុក ឧបសក

ឧបសិកា មកគគ្រឹកគគ្រេង សូត្រមន្តសព្វបែបយ៉ាងទាំងអស់។

**ស៖** បាទ អរគុណលោកអ៊ំ។ តើលោកអ៊ំអាចជម្រាប អង្គសវនាការបានទេថា ព្រះសង្ឃដែលបានលាចាកសិក្ខាបទនោះ តើអ្នកទាំងអស់នោះ ទៅណា? គាត់អញ្ជើញធ្វើអីបន្ទាប់ពីពេលនោះ?

**ឆ៖** មួយចំនួនចាស់ពេកទៅ ក៏ស្លាប់អស់ទៅ លាចាកមកបានបន្តិចក៏ស្លាប់។ ប៉ុន្តែដូចលោកតា អៀម វត្តត្នោតជុំ មកក្រោយមកបានបួសវិញ លោកតា សែម ផ្លឹកជ្រំបានបួសវិញ បានបន្តិចទៅបានសុគត។ លោកតា អ៊ុច គ្រូអនុគណ អត់បានបួសវិញទេ។ ចាស់ៗគឺស្លាប់ សុគតអីអស់ហើយ ហើយនៅក្មេងៗ នៅសល់ស្រុករខ្ញុំ ក្រោយខ្ញុំបន្តិចបន្តួច ខ្លះក៏ស្លាប់ ខ្លះក៏បែកគ្នាមិនដឹងទៅឯណាមកឯណាទេ។

**ស៖** បាទ អរគុណលោកអ៊ំ។ លោកអ៊ំបានមានប្រសាសន៍ អំពីការគោរពប្រតិបត្តិព្រះពុទ្ធសាសនា ដោយស្ងាត់ស្ងៀមនៅបន្ទាប់ពី ១៧ មេសា ចុងឆ្នាំ៧៥ ឬក៏ដើមឆ្នាំ១៩៧៦។ តើពេលនោះ មានការធ្វើពិធីផ្សេងៗ ខាងព្រះពុទ្ធសាសនា ដូចជា ពិធីបុណ្យបច្ច័យបួន បុណ្យកឋិន ឬក៏ពិធីសូត្រមន្តអីផ្សេងៗនៅតាមភូមិ ឬក៏តាមផ្ទះរបស់អ្នកភូមិដែរឬទេអ៊ំ?

[១៣:៥៩:៤២]

**ឆ៖** ត្រង់នេះមិនមានទេ។ ប៉ុន្តែមកខាងលើហ្នឹងមិនដឹងម៉េចទេ។ ប៉ុន្តែនៅតាមភូមិតាមអី ដល់អស់លោកអស់អីទៅក៏ចប់។ អត់មានឃើញធ្វើអីទេ គឺសាសនាកាន់ទុកក្នុងខ្លួនតែរៀងៗខ្លួន ហើយក៏ខ្សឹបខ្សៀវគ្នាទៅ ឯពិធីគគ្រឹកគគ្រេងអត់ឃើញមានធ្វើទេ។ ទាំងខ្ញុំ ទាំងគេហ្នឹង គឺអត់មានប៉ានធ្វើអីយ៉ាងនេះ យ៉ាងនោះអីទេ។

**ស៖** ចុះនៅក្នុងពេលពិធីរៀបអាពាហ៍ពិពាហ៍ តើអ៊ំមានដឹងទេថា តើគេមានប្រើទំនៀមទម្លាប់ខាងសាសនានៅក្នុងរៀបអាពាហ៍ពិពាហ៍ដែរឬទេ?

**ឆ៖** មិនឃើញមានទេ ប៉ុន្តែទំនៀមទម្លាប់ វាគ្រាន់តែថាឲ្យភូមិ ឃុំ ឬមេអនុញ្ញាតយល់ព្រមហើយបានហើយ។ ឯពិធីវែងឆ្ងាយទៅទៀត អត់ទេ។ យើងប្រពៃណីពីបុរមបុរាណ គឺថាច្បាប់រដ្ឋ ច្បាប់ប្រទេស ឲ្យតែបានមក បានធ្វើពិធីផ្សេងៗនេះ មានពិធីត្រង់ច្បាប់អនុញ្ញាតមកហើយ ខាងរដ្ឋអំណាចអនុញ្ញាតមកហើយ ក៏រៀបចំទៅ តាមអង្គភាព តាមកង រៀបចំទៅ។ តែប៉ុណ្ណឹង។

[១៤:០១:២០]

**ស៖** តើលោកអ៊ំអាចជម្រាបបានទេថា តើពិធីរៀបអាពាហ៍ពិពាហ៍ហ្នឹង ថាតើគេធ្វើដោយរបៀបណា ថាតើមានការស្ម័គ្រចិត្តដែរឬទេ? ហើយមានច្រើនគូ ឬក៏តិចគូ? ហើយមានអ្នកណាខ្លះចូល

រួមនៅក្នុងពេលនោះ?

**ឆ៖** ធ្វើដោយឡែកៗ រកកំណត់មនុស្សថា នេះវាតាមកង តាមភូមិ តាមឃុំ តាមអង្គភាព គេធ្វើដោយឡែកៗ។ យើងរកកំណត់អ្នកនេះអ្នកនោះ មិនបានទេ បើដូចតាមប្រពៃណី វាមានអាចារ្យ មានអ្នកផ្លូវថៅមហាទៅធ្វើ អាហ្នឹងបានរកមុខ ថាអ្នកណាធ្វើអាចារ្យ អ្នកណាធ្វើមហាទៅ អ្នកណាធ្វើមេបា។ ឯក្នុងពិធីនេះ ឲ្យតែច្បាប់រដ្ឋមកហើយ ក៏ប្រកាសថាពីរនាក់ហ្នឹងជាប្ដីជាប្រពន្ធ។

**ស៖** តើលោកអ៊ំមានធ្លាប់បានចូលរួម នៅក្នុងកម្មវិធីរៀបអាពាហ៍ពិពាហ៍ណាមួយ ឬក៏បានឃើញខ្លួនឯងទេ នៅបន្ទាប់ពីឆ្នាំ១៩៧៥ ១៧ មេសា នោះអ៊ំ?

**ឆ៖** ឃើញនេះ មិនឃើញអ្នកក្រៅទេ ឃើញខ្លួនឯងតែម្ដង។ តាម៉ុក គាត់ផ្ដុំដាក់តែម្ដង។ ប៉ុន្តែឲ្យខាងមន្ទីរ ប្រធានមន្ទីរអីគេរៀបចំប្រកាសអីស្រួលបួល។

[១៤:០៣:០៤]

**ស៖** បាទ និយាយអំពីករណីជាក់ស្ដែងរបស់លោកអ៊ំ ដែលតាម៉ុក រៀបការជូនហ្នឹង ថាតើអ្នកដែលគេរៀបការជូនលោកអ៊ំ ខាងភាគីស្រី ខាងស្រីហ្នឹង ថាតើគាត់ស្គាល់លោកអ៊ំទេពីមុន?

**ឆ៖** ស្គាល់ដែរ ប៉ុន្តែមិនស្គាល់ច្បាស់ទេ ប៉ុន្តែនៅមន្ទីរភូមិភាគដែរ នៅខាងកាត់ដេរ មិនមែននៅតាមភូមិ តាមនេះទេ។ ដូច្នេះ គាត់ឲ្យដំណឹងតាំងពីថ្ងៃមុនមក។

**ស៖** លោកអ៊ំជម្រាបថា មានប្រសាសន៍ថា ឲ្យដំណឹងពីថ្ងៃមុន តើលោកអាចជម្រាបបានទេថាតើដំណឹងហ្នឹងអ្នកណាឲ្យ ហើយថាតើអ្នកដែលជាអនាគតប្រពន្ធរបស់អ៊ំហ្នឹង គាត់ស្ម័គ្រ គាត់ដឹងខ្លួនថាត្រូវរៀបការដែរឬទេ? ហើយគាត់ស្ម័គ្រចិត្តរៀបការជាមួយអ៊ំដែរឬទេ? ហើយបាទ។

**ឆ៖** ដល់មកក្រោយមក បានឮគ្រួសារខ្ញុំនិយាយថា តាគាត់ទៅថាតាំងពីថ្ងៃមុន ប៉ុន្តែថាអត់ឲ្យចំ ហើយមកដល់កំណត់។ ហើយខ្ញុំអត់ដឹងទេ អត់មានសួរ មានអីទេ។ ហើយពេលគាត់ហៅឲ្យទៅជួបដល់ទៅញ៉ឹមញ៉ែមៗហ្នឹង ហើយដល់ហើយគាត់ថា អើ!ហៅមកហ្នឹងឲ្យ ហៅឲ្យមកការតើ។ បានប្រគល់ឲ្យអ្នកនៅក្នុងមន្ទីរហ្នឹងគេជួបជុំគ្នាទៅ ប្រកាសទៅ។ បើខាងអ្នកផ្ទះនោះ គឺគាត់ទៅនិយាយឲ្យចោទហើយ តាំងពីថ្ងៃមុនណោះ ប៉ុន្តែមិននិយាយចំទេ។

**ស៖** នៅក្នុងពិធីរៀបអាពាហ៍អាពិហ៍នេះ មានការចូលរួមពីឪពុកម្ដាយដែរឬទេ? ឬក៏ពីសាច់ញាតិរបស់គូស្វាមីភរិយាហ្នឹងដែរឬទេ?

[១៤:០៥:២៧]

**ឆ៖** កាលដែលខ្ញុំហ្នឹង ដាច់ដោយឡែក គ្មានបងប្អូន គ្មានអីទេ គឺពួកមន្ទីរជាមួយគ្នាហ្នឹង មករួម។ ញាតិមិត្តនៅឯភូមិ នៅឯផ្ទះណោះ។ តែពួកមន្ទីរ អាហ្នឹងខាងពួកមន្ទីរ ពួកអង្គភាព។

**ស៖** ពេលដែលលោកអ៊ំការហ្នឹង មានប៉ុន្មានគូ? ហើយទីកន្លែងការហ្នឹង នៅកន្លែងណាដែរលោកអ៊ំ?

**ឆ៖** ពេលការហ្នឹង ទោល តែមួយគូ។ ឯនៅខាងទីក្រុងតាកែវហ្នឹង។

[១៤:០៦:០៩]

**ស៖** បាទ សូមអរគុណលោកអ៊ំ។ ខ្ញុំចង់សួរលោកអ៊ំពាក់ព័ន្ធទៅនឹងបញ្ហាដែលលោកអ៊ំបានមានប្រសាសន៍ថា មានអ្នកភ្នំពេញដែលជាសាច់ញាតិរបស់លោកអ៊ំ បានចេញពីភ្នំពេញ ហើយទៅនៅក្នុងភូមិរបស់លោកអ៊ំ នៅរស់នៅជាមួយនឹងអ្នកចាស់នៅក្នុងសហករណ៍។ សំណួរចង់សុំសួរលោកអ៊ំថា តើអ្នកដែលមកពីភ្នំពេញហ្នឹង ថាតើគាត់រស់នៅក្នុងស្ថានភាពបែបណានៅក្នុងសហករណ៍ហ្នឹង? ថាតើគាត់ធ្វើការធ្ងន់ ឬក៏ស្រាល បើប្រៀបធៀបទៅនឹងអ្នកដែលនៅក្នុងភូមិហ្នឹងស្រាប់?

**ឆ៖** ខ្ញុំមកនៅតាកែវ នៅភ្នំពេញនេះ ខ្ញុំមិនបានដឹងច្បាស់ទេ មិនបានដឹងច្បាស់ ប៉ុន្តែកាលនោះវាធ្វើទំនប់ ជីកប្រឡាយអី ធ្វើការងាររួម បាយរួមហ្នឹង វាទាំងអស់គ្នាហ្នឹង។ ប៉ុន្តែមិនបានដឹងល្អិតទេ។ ព្រោះខ្ញុំទៅម្តងៗ ទៅប្រញាប់ដែរ អត់ដែលនៅយូរ។ ការងារទៅក្បែរហ្នឹង ចូលទៅមួយភ្លែតទៅ ហើយក៏មកវិញមក។

**ស៖** បាទ អរគុណលោកអ៊ំ។ ខ្ញុំចង់ជម្រាបសួរលោកអ៊ំពីបញ្ហាមួយទៀត លោកអ៊ំត្រូវបានតាម៉ុក ហៅលោកអ៊ំមកកាន់លុយ ក៏ប៉ុន្តែដល់ជាក់ស្តែង គឺលោកអ៊ំអត់បានកាន់លុយទេ។ នៅក្នុងប្រហែល-- នៅក្នុងប្រហែលជាចុង៧៥ ឬក៏ដើម៧៦។ ខ្ញុំចង់ជម្រាបសួរលោកអ៊ំ ហេតុអ្វីបានជាលោកអ៊ំមិនបានធ្វើកិច្ចការ កាន់លុយនោះ នៅពេលដែល តាម៉ុក បានហៅលោកអ៊ំហើយ ហើយលោកអ៊ំបានទាំងឃើញថាមានលុយថែមទៀតផង នៅទីនោះ?

[១៤:០៨:៣៨]

**ឆ៖** ដល់សម្រេចមក អត់ចាយលុយ វាចប់ត្រឹមអត់ចាយលុយ វាត្រូវអត់បានកាន់ហ្នឹងតែម្តង។

**ស៖** បាទ លោកអ៊ំមានប្រសាសន៍ថា សម្រេចថាមិនចាយលុយ។ តើអ្នកណាដែលជាអ្នកសម្រេចថា មិនចាយលុយនោះ? ធ្វើយ៉ាងម៉េច--

**ឆ៖** ស្ងាត់ៗ ឃើញថា គេអត់យកមកចាត់ចែងចាយ ហើយធ្លាក់លើហ្នឹង ខ្ញុំអត់ដឹងទេ

មិនពីណាមកទេ តាម៉ុក ក៏គាត់គ្មានអំណាចដែរ។ អំណាចមកពីលើមកទៀត មិនមែនអំណាចចប់ត្រឹមហ្នឹងណា។ គាត់មានខាងលើទៀត ឬក៏គណៈកម្មាធិការខាងលើសម្រេច។

**ស៖** តើ តាម៉ុក មានធ្លាប់និយាយជម្រាបជូនអ៊ំទេ អំពីការមិនចាយលុយពីសេចក្ដីសម្រេចចិត្តហ្នឹង? ថាតើគាត់មានជម្រាបថា ថ្នាក់លើមិនឱ្យចាយលុយអ៊ីចឹងដែរឬទេ? ឬក៏អត់ទេ?

**ឆ៖** ស្រពេចស្រពិល ដូចជានឹកមិនឃើញទេ ស្រាប់តែស្ងាត់ៗអត់ចាយពេញផែនដីហ្នឹងទៅ។ អត់បានរៀន អត់បានសូត្រ បានបញ្ជាក់ប្រជុំអីយ៉ាងម៉េច គឺស្ងាត់ៗក៏បាត់ទៅ គឺនៅតាមធម្មតាហ្នឹងទៅ។ របស់របរអីចែកគ្នាទៅ បានមកគឺចែកគ្រប់ទីគ្រប់កន្លែងអ៊ីចឹងទៅ យកទៅចែកគ្នាទៅ។ ត្រង់និយាយថាម៉េចៗ ខ្ញុំមិនបានចាំច្បាស់លាស់ទេ។

**ស៖** តើលោកអ៊ំធ្លាប់សួរដេញដោល តាម៉ុក អំពីការដែលលោកអ៊ំអត់ធ្វើការងារហ្នឹងដោយសារមិន ការមិនឈប់ ការឈប់ចាយលុយហ្នឹងដែរឬទេ? មានធ្លាប់សួរដេញដោល ហេតុអីបានជាមិនចាយលុយ?

[១៤:១១:២២]

**ឆ៖** មិនបានដេញដោលទេ មិនបានដេញដោល។

**ស៖** បាទ អរគុណលោកអ៊ំ។ តើលោកអ៊ំបានមានប្រសាសន៍ថាលោកអ៊ំបានធ្លាប់ជជែកខ្លីៗជាមួយ តាម៉ុក តើលោកអ៊ំមានធ្លាប់ឮ តាម៉ុក និយាយអំពីការផ្ទេរប្រជាជនពីកន្លែងមួយទៅកន្លែងមួយថែមទៀតទេបន្ទាប់ពីឆ្នាំ-- ពីពេលដែលអ៊ំទៅនៅជិត តាម៉ុក នោះ?

**ឆ៖** គាត់មិននិយាយអីច្រើនទេ ប៉ុន្តែឮតាមពួកតំបន់ ពួកខេត្តគេនិយាយខ្លះដែរ។ ហើយជាមួយតាម៉ុក អាហ្នឹងជម្លៀសហើយ អស់ទៅហើយ ទៅគ្រប់ទីគ្រប់កន្លែងអស់ទៅហើយ ខាងស្រុកខាងតំបន់គេនិយាយអស់ៗសព្វគ្រប់ហើយ។

**ស៖** ពេលខាងស្រុក ខាងតំបន់គេនិយាយហ្នឹង គេនិយាយសំដៅទៅលើជម្លៀសពេលណា? តើជម្លៀសនៅបន្ទាប់ពី១៧ មេសា ១៩៧៥ ឬក៏ការជម្លៀសក្រោយពីពេលនេះតទៀត? អាចមួយខែ-- អំពីរខែ បីខែក្រោយពីពេលនេះ?

**ឆ៖** មិនចាំពេលវេលាច្បាស់លាស់ទេ ប៉ុន្តែមិនយូរប៉ុន្មានទេ។ តាមមើលមិនយូរប៉ុន្មានទេ។

[១៤:១៣:១៣]

**ស៖** ខ្ញុំយល់អត់ទាន់ច្បាស់ទេ ដែលលោកអ៊ំនិយាយថាមិនយូរប៉ុន្មាន ថាតើការជម្លៀសណា

ដែលមិនយូរប៉ុន្មាន?

**ឆ៖** *(មិនបើកក្បាលមីក្រូហ្វូន)*

**ប្រធានអង្គជំនុំ៖**

អ៊ំមិនទាន់មានភ្លើងក្រហមកុំអាលទាន់ឆ្លើយ ចាំរង់ចាំភ្លើងក្រហមនៅក្បាលមីក្រូសិនសឹមឆ្លើយអ៊ំ។

**លោក ខៀវ នៅ៖**

**ឆ៖** សូមលោកបញ្ជាក់សំណួរម្តងទៀត។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** តើការជម្លៀសដែលខាងខេត្ត ខាងស្រុកគេនិយាយនុ៎ង ជាការជម្លៀស១៧ មេសា ឬក៏ការជម្លៀសក្នុងពេលផ្សេងពី១៧ មេសា?

**ឆ៖** និយាយក្នុងការជម្លៀស១៧ មេសា ហ្នឹង។ ហើយនិយាយហ្នឹង មិនមែននិយាយជាអង្គប្រជុំ ជាអីវែងឆ្ងាយទេ គេចេះតែថាតៗគ្នាមក។ ដូច្នេះកំណត់ជាផ្លូវការមិនបាន។

**ស៖** បាទ អរគុណលោកអ៊ំ។ ខ្ញុំចង់ជម្រាបសួរលោកអ៊ំមួយទៀត តើលោកអ៊ំធ្លាប់ឮគេនិយាយអំពីក្រាំងតាចាន់ ដែរឬទេ?

[១៤:១៥:០១]

**ឆ៖** បាទឮក៏ភ្លេចហើយ នៅចាំតែឈ្មោះហ្នឹង ប៉ុន្តែថារឿងរ៉ាវអីបែបភ្លេចហើយ មិនបានដឹងរឿងទេ។ ប៉ុន្តែក្រាំងតាចាន់ គឺឈ្មោះហ្នឹងវាធ្លាប់ឮហើយ ប៉ុន្តែរឿងរ៉ាវម៉េចៗ វាមិនបានចាំទេ ដឹងមានរឿងយ៉ាងម៉េចខ្លះ។

**ស៖** ខ្ញុំអត់នៅសល់ចំណុចច្រើនសម្រាប់សួរលោកអ៊ំទេ ខ្ញុំចង់សួរលោកអ៊ំពាក់ព័ន្ធទៅនឹងការដឹកជញ្ជូនសម្ភារៈពីកន្លែងមួយទៅកន្លែងមួយ។ ខ្ញុំចង់សូមជម្រាបសួរថា តើនៅពេលដែលត្រូវការដឹកជញ្ជូនសម្ភារៈពីកន្លែងមួយទៅកន្លែងមួយ តើលោកអ៊ំត្រូវការមានសំបុត្រដើរផ្លូវដែរឬទេ?

**ឆ៖** ឡានដឹកជញ្ជូនទាំងអស់ត្រូវមានសំបុត្រ តាមឡានហ្នឹង តែកុងឡានហ្នឹង គឺដាក់ថាតែកុងឡាន ហើយនិងអ្នកលើកដាក់អីវ៉ាន់ហ្នឹងទៅជាមួយបួនប្រាំនាក់ ដប់នាក់អីអ៊ីចឹងទៅ មានដាក់អ៊ីចឹង។ ឲ្យតែពួកឡានដឹកជញ្ជូនហ្នឹង គឺមានសំបុត្រសម្រាប់ចំហគ្នាច្រើន ព្រោះត្រូវការមនុស្សលើកដាក់។ ហើយបើមិនមានសំបុត្រអ៊ីចឹងទេ ចេញទៅក្រៅក៏មានបញ្ហា ដល់មកពីក្រៅចូលក្រុងវិញ ខាងក្រុងឃាត់ ព្រោះអត់មានលិខិត អត់មានសំបុត្រ។ ដូច្នេះមានសំបុត្រ។

[១៤:១៦:៥៨]

**ស៖** តើលោកអ៊ំជម្រាបបានទេ ថាតើអ្នកណាដែលជាអ្នកចេញសំបុត្រដើរផ្លូវនោះ នៅថ្នាក់ណាដែរ?

**ឆ៖** ខាងភូមិភាគ ជួន តាម៉ុក គាត់ចេញផ្ទាល់ ជូនឲ្យក្នុងគណៈកម្មការហ្នឹងចេញ។ ប៉ុន្តែបន្តិចបន្តួចឡានពីរបីគ្រឿងអី គាត់ខ្ជិលប្រើគេ គាត់ធ្វើខ្លួនគាត់។

**ស៖** តើលោកអ៊ំធ្លាប់-- នៅក្នុងការដឹកជញ្ជូនហ្នឹង លោកអ៊ំធ្លាប់អញ្ជើញទៅដល់ខេត្តណាខ្លះ?

**ឆ៖** ទៅកំពង់ឆ្នាំងៗ ដល់ចុងក្រោយមក តាម៉ុក មកនៅបាត់ដំបងមួយរយៈហ្នឹងក៏មកជួបគាត់នៅហ្នឹង ម្តង។ ឯខេត្តតាកែវ ខេត្តអីហ្នឹង អាហ្នឹងគឺវានៅហ្នឹងទៅហើយ។ ខេត្តកំពតក៏មិនបានទៅដែរ។ កំពង់ស្ពឺៗ ដូចនឹកមិនឃើញថាទៅទេ បើកំពង់ឆ្នាំងនឹកឃើញទៅ។

**ស៖** តើលោកអ៊ំមានឃើញស្ថានភាពរបស់ប្រជាជន ថាតើការរស់នៅរបស់ប្រជាជនដែលអ៊ំបានទៅឃើញហ្នឹង គាត់រស់នៅស្រួល ឬលំបាកយ៉ាងណាដែរលោកអ៊ំ?

[១៤:១៩:០១]

**ឆ៖** ទៅ យើងទៅទាក់ទងតែតំបន់ ទាក់ទងតែសេដ្ឋកិច្ចតំបន់ នៅឯក្រុងនេះ ប្រជាជនអ្នកស្រែអ្នកចម្ការ យើងអត់ដឹង ទៅមិនដល់។ ព្រោះដាក់កន្លែងភូមិភាគ ដាក់កន្លែងខេត្ត កន្លែងតំបន់ បានគេយកចែកខ្លួនគេទៅ។ ដូច្នេះយើងមិនបានដឹងដល់ជ្រៅទៅទៀតទេ។

**ស៖** តើលោកអ៊ំមានៗធ្លាប់ឮអ្នកដែលទទួលសម្ភារៈពីអ៊ំហ្នឹង និយាយអំពីស្ថានភាពរស់នៅរបស់ប្រជាជននៅកន្លែងដែលអ៊ំទៅដល់ដែរឬទេ?

**ឆ៖** ការនិយាយដូចចេះតែមានឮហើយ យ៉ាងនេះ យ៉ាងនោះ។ មានឮ។

**ស៖** តើអ៊ំមានធ្លាប់និយាយអំពីស្ថានភាពរបស់ប្រជាជនហ្នឹងជូនទៅថ្នាក់លើណាមួយទេ ឬក៏ជូនទៅលោក ខៀវ សំផន នៅពេលដែលអ៊ំជួបគាត់?

**ឆ៖** និយាយពីរឿងខ្វះក្រណាត់ហ្នឹង។ ហើយលោក ខៀវ សំផន លោកថា អស់ហើយក្រណាត់ខ្មៅ មានតែក្រណាត់ស។ ខ្ញុំថាក្រណាត់សក៏យកដែរ ឲ្យតែមាន។ យកជ្រលក់សំបកឈើទៅតាមបុរមបុរាណស្លៀកពាក់បានហើយ។ ហើយគាត់ដេញដោលសួរអីចឹង ខ្ញុំថាដឹងមិន-- សួរអីចឹងសួរ-- ខ្ញុំដឹងអត់សព្វទេ ដឹងអត់វែងទេ។ ខ្ញុំដឹកយកទៅដាក់កន្លែងភូមិភាគ កន្លែងនេះទេ កន្លែងស្រុកទេ-- អ្ហូ! កន្លែងខេត្ត។ អត់បានដឹងទូទៅ។ ឯគាត់ចង់ដឹងទៅដល់ភូមិ ដល់ឃុំអី ខ្ញុំថាខ្ញុំអត់ដឹងទេ។

**ស៖** អ៊ីចឹងលោកអ៊ំបានប្រសាសន៍ថា គាត់ចង់ដឹងដល់ភូមិឃុំ ថាតើពេលដែលអ៊ំជួបគាត់ទាំងពីរដងហ្នឹងគាត់សួរអំពីស្ថានភាពនៅភូមិឃុំហ្នឹងទាំងពីរដង ឬក៏សួរតែម្តងទេ?

[១៤:២១:៤៧]

**ឆ៖** ដូចសួរតែម្តងហ្នឹងទេ។ ព្រោះជួបហ្នឹងវាមិនបានយូរហូរហែដែរ ជួបប្រញាប់។ ដូច្នេះមិនបាននិយាយអីវែងឆ្ងាយទេ។

**ស៖** បាទ ខ្ញុំនឹងសួរសូមឲ្យលោកអ៊ំបំភ្លឺនូវចំណុចចុងក្រោយមួយទៀត នៅក្នុងចម្លើយរបស់លោកអ៊ំជាមួយនឹងតំណាងការិយាល័យចៅក្រមស៊ើបអង្កេត នៅក្នុងឯកសារដដែល គឺ D166/183 ERN ជាភាសាខ្មែរ 00355452, ជាភាសាអង់គ្លេស 00358143, ជាភាសាបារាំង 00408428 នៅក្នុងឯកសារនេះលោកអ៊ំបានមានប្រសាសន៍ថា៖ “ប្រហែលជានៅឆ្នាំ១៩៧៨ ដើមឆ្នាំ១៩៧៨ ខ្ញុំបានជួបលោក នួន ជា នៅក្បែរអគារដែលខ្ញុំស្នាក់នៅ ដោយគាត់ជិះឡានមក ហើយប្រាប់ខ្ញុំថា ឲ្យរកឧបករណ៍ភ្លេងខ្មែរបុរាណ ដើម្បីហាត់ភ្លេងប្រចាំប៉ុស្តិ៍វិទ្យុ”។ ខ្ញុំចង់សូមជម្រាបសួរលោកអ៊ំថា តើលោកអ៊ំដឹងទេថាអ្នកណាដែលជាអ្នក គ្រប់គ្រងប៉ុស្តិ៍វិទ្យុ?

[១៤:២៣:៥៣]

**ឆ៖** កាលនោះខ្ញុំមិនដឹងទេ។ ប៉ុន្តែសូមជម្រាបបន្តិច ក្នុងរឿងហ្នឹង។ ព្រោះពួកភ្លេងដែលយកទៅប៉ុស្តិ៍ហ្នឹង ចុងក្រោយបង្អស់មកនៅ-- ឲ្យ តាម៉ុក អ្នកប្រមូល។ ដល់ឲ្យ តាម៉ុក អ្នកប្រមូល វាត្រូវខ្ញុំដឹកពួកភ្លេងហ្នឹងមក។ ដឹកពួកភ្លេងហ្នឹងមក ដល់វាខ្វះឧបករណ៍ ពួកខ្ញុំចេះតែដើរស៊ើបៗទៅយកអីវ៉ាន់តាមឃ្លាំងហ្នឹង ឃើញឧបករណ៍ភ្លេងមាននៅក្នុងឃ្លាំងរដ្ឋ។ ហើយខ្ញុំនិយាយប្រាប់ពួកភ្លេងថាមាន ប៉ុន្តែនៅក្នុងឃ្លាំងរដ្ឋ នាំគ្នាស្ងើទៅ។ ហើយភ្លេងហ្នឹងមិនដឹងជាម៉េចបានៗដឹងទៅដល់លោក នួន ជា។ ខ្ញុំមិនបានដឹងទេ ស្រាប់តែពេលមួយមកឈប់ឡានមុខហ្នឹង សួរខ្ញុំ។ ខ្ញុំចេញមកភ្លេតហ្នឹងថា “អ្អេ! ឮថាដឹងកន្លែងភ្លេង?” ខ្ញុំថា ដឹងនៅឃ្លាំងរដ្ឋដដែល។ “អ្អេ! នាំគេទៅ!” បានជួបតែប៉ុណ្ណឹង។ ទៅរកគ្រឿងភ្លេងនៅឃ្លាំងរដ្ឋដដែលហ្នឹង ហើយក៏ទៅទៀតទៅ អត់បានអីវែងឆ្ងាយទេ។ ហើយលោកសួររកប្រធានប៉ុស្តិ៍ ប្រធានប៉ុស្តិ៍កាលហ្នឹង ខ្ញុំអត់បានដឹងទេ។ ប៉ុន្តែដល់រត់៧៩ទៅ បែកគ្នាទៅវាមានជួបខ្លះ ពួកប៉ុស្តិ៍ ពួកអីហ្នឹងទៅជួបគ្នានៅភ្នំឱរ៉ាល់ ត្រពាំងជោរនោះ។ ហើយពេលនេះ ខ្ញុំមិនដឹងទេ មិនដឹងនរណាប្រធាន នរណាអីទេ។

[១៤:២៥:៤៧]

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ តើលោកអ៊ំអាចជម្រាបបានទេ ផ្នែកពាណិជ្ជកម្មនិរតី ដែលអ៊ំធ្វើការហ្នឹង ថាតើនៅក្នុងរចនាសម្ព័ន្ធ មានទំនាក់ទំនងយ៉ាងម៉េចជាមួយនឹងក្រសួងពាណិជ្ជកម្ម? ថាតើនៅក្រោមឱវាទក្រសួងពាណិជ្ជកម្ម ឬក៏ថានៅក្រោមភូមិភាគនិរតី?

**ឆ៖** ហ្នឹងខាងរដ្ឋ ខាងសេដ្ឋកិច្ចរដ្ឋ ខាងក្រសួងសេដ្ឋកិច្ច បែងភាគក្នុងភូមិភាគមួយៗមានមនុស្សប៉ុន្មានលាន មានប៉ុន្មានម៉ឺន បែងភាគសម្ភារៈតាមហ្នឹង បែងហើយបានចេញសំបុត្រឲ្យទៅដឹកទៅយក។ ហ្នឹងអ៊ីចឹង ខ្ញុំនិយាយៗ ដូចភ្លេចសំណួរបន្តិចទៅវិញហើយ។

[១៤:២៧:០០]

**ស៖** សំណួរសុំចង់ជម្រាបសួរលោកអ៊ំថា តើផ្នែកពាណិជ្ជកម្មនិរតី ដែលលោកអ៊ំធ្វើការនៅក្នុងនោះស្ថិតនៅក្នុងរចនាសម្ព័ន្ធ នៃក្រសួងពាណិជ្ជកម្ម ឬក៏នៅក្នុងរចនាសម្ព័ន្ធរបស់ភូមិភាគនិរតី?

**ឆ៖** រចនាសម្ព័ន្ធ ឬសម្ព័ន្ធភាព វាជាប់គ្នាពីរដ្ឋមកភូមិភាគ ស្អីៗសម្រេចមកពីរដ្ឋ អាចឲ្យបានប៉ុន្មានចេញសំបុត្រឲ្យប៉ុណ្ណឹង បានមកប្រាប់ពួកខ្ញុំឲ្យទៅយក ទៅដឹកចែកតំបន់ ចែកនេះទៅ។ ដូច្នេះ វាឯកភាពគ្នាទាំងសងខាង ទាំងខាងរដ្ឋ និងខាងភូមិភាគ។

**ស៖** លោកអ៊ំមានប្រសាសន៍ថា ខាងរដ្ឋថាតើអ្នកណាគេដែលនៅខាងរដ្ឋនោះ លោកអ៊ំចង់សំដៅលើអ្នកណាខ្លះ?

**ឆ៖** ដែលខាងខ្ញុំទាក់ទងផ្ទាល់ ខាងក្រសួងឃ្លាំងរដ្ឋនោះគឺមានលោក រឿង ប្រធានឃ្លាំងរដ្ឋ។ ឯទៅលើទៅទៀតនោះវា ក្រសួងសេដ្ឋកិច្ចនោះវា អាហ្នឹងមើលទៅប្រហែលជានៅក្នុងលោក វន វ៉េត។ ប៉ុន្តែឥឡូវនិយាយតែពីឃ្លាំងរដ្ឋ គឺលោក រឿង ជាប្រធាន ហើយទៅទាក់ទងត្រឹមប៉ុណ្ណឹង។ គាត់ស្លាប់ហើយលោក រឿង នោះ។

[១៤:២៨:៤៨]

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកអ៊ំ។ សូមអរគុណលោកប្រធាន និងលោក លោកស្រីចៅក្រម។ ជាបន្តសូមលោកប្រធានអនុញ្ញាតឲ្យលោក បាណាបេ ណេគ្វី មេធាវីខាងសមាគមគ្មាន-- មេធាវីគ្មានព្រំដែនបារាំង សូមបន្តលើកសំណួរមួយចំនួនបន្ថែមទៀត។ សូមលោកប្រធានអនុញ្ញាត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក បាណាបេ ណេគ្រី៖**

សូមអរគុណលោកប្រធាន។ លោកប្រធាន ខ្ញុំមានតែសំណួរមួយ ដើម្បីបញ្ជាក់បំភ្លឺពីសាក្សីតែប៉ុណ្ណោះលោកប្រធាន។

[១៤:២៩:២២]

**សួរដោយលោក បាណាបេ ណេគ្រី៖**

**ស៖** លោកសាក្សី លោកបានអះអាងជាច្រើនលើក ច្រើនសាថានៅពេល វន វ៉េត អវត្តមាន លោក ខៀវ សំផន ជំនួសតំណែងគាត់ ហើយលោកចៅក្រម ឡាវ៉ែន៍ ក៏បានបញ្ជាក់ ឬក៏រំឭកលោក អំពីអ្វីដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត ជាពិសេសគឺឃ្លាដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "បន្ទាប់ពីមានការបាត់ខ្លួន វន វ៉េត ប្រហែលជានៅឆ្នាំ១៩៧៧ ខៀវ សំផន បានឡើងជំនួស វន វ៉េត ទទួលបន្ទុកពាណិជ្ជកម្មក្រៅប្រទេស។" សូមបញ្ចប់ការដកស្រង់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្ដី!

[១៤:៣០:២៤]

**លោក អាកទួរ វែកកែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះលោកប្រធាន ពីព្រោះថា ខ្ញុំបានស្នើសុំទៅ ខាងផ្នែកនៃអង្គជំនុំជម្រះរួចមកហើយ ក្នុងការធ្វើប្រតិចារឹក នៃខ្សែអាត់សំឡេងនៃកិច្ចសម្ភាសន៍សាក្សីរូបនេះ ដែលគាត់បានឆ្លើយជាមួយនឹងសហចៅក្រមស៊ើបអង្កេតនោះ។ ហើយយើងក៏បានទទួលនូវខ្សែអាត់ថតសំឡេងនេះ។ ខ្ញុំបានអានអម្បាញ់មិញនេះនៅពេលដែលលោកចៅក្រម ឡាវ៉ែន៍ អនុញ្ញាតឲ្យខ្ញុំធ្វើ។ ខ្ញុំមើលឃើញថា តាមរយៈការកែប្រែរបស់សាក្សីរូបនេះ គឺគាត់បានបញ្ជាក់ជូនអង្គជំនុំជម្រះថាគាត់មិនទទួលស្គាល់នូវអ្វីដែលបានអានឲ្យគាត់ស្ដាប់កំណត់ហេតុស្ដាប់ចម្លើយគាត់ ទាំងស្រុងនៅមុនពេលដែលគាត់មកបង្ហាញខ្លួននោះទេ គឺថាអត្ថបទនៃប្រតិចារឹកខ្សែអាត់ថតសំឡេងនោះ គឺថាមានអត្ថិភាព ហើយដូច្នេះ យើងមិនអាចយកកំណត់ហេតុដែលគ្រាន់ជាការបកប្រែរបស់សហចៅក្រមស៊ើបអង្កេតហើយដែលមានបំប្លែងនូវព័ត៌មាន បន្ថែមនូវព័ត៌មាន ហើយដែលគ្រាន់តែជាការសង្ខេបនៃកិច្ចសម្ភាស ហើយយើង យើងមានខ្សែអាត់រួចមកហើយ។ ខ្សែអាត់នេះហើយ គឺជាចម្លើយដ៏ស្មោះត្រង់របស់គាត់។ ដូច្នេះ គឺថាយើងត្រូវតែយកខ្សែអាត់នេះយកមកធ្វើជាឯកសារភស្តុតាង គឺជាឯកសារខ្សែ

អាត់ថតសំឡេងគាត់ទាំងស្រុង។

[១៤:៣២:១៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ចារីក៖**

លោកប្រធានខ្ញុំចង់ជួយអន្តរាគមន៍បន្តិច ប៉ុន្តែខ្ញុំគិតថាសហការីរបស់ខ្ញុំ គឺមេធាវីហ្នឹង គាត់ហាក់ដូចជាលើស និយាយលើសពីអ្វីដែលសមហេតុផលបន្តិច គឺថាទាក់ទងនឹងការទទួលតួនាទីរបស់ ខៀវ សំផន ជំនួសឲ្យ វន វ៉េត។ ហើយលោកសាក្សីបាននិយាយថា នេះគឺជាសេចក្តីសន្និដ្ឋានរបស់គាត់ ព្រោះថាមិនមាននូវឯកសារជាផ្លូវការណាមួយឡើយ ប៉ុន្តែគាត់បានបញ្ជាក់ច្បាស់ហើយថា នេះគឺជាអ្វីដែល គាត់បានសន្និដ្ឋាន។ ហើយផ្អែកទៅលើប្រតិចារឹកនោះទៀត គឺថាពាក្យហ្នឹងមិនមែននិយាយនៅក្នុងផ្នែកនេះទេ ប៉ុន្តែនៅក្នុងប្រតិចារឹក គឺមានផ្នែកខ្លះដែលបានបញ្ជាក់។

ដូច្នេះ ខ្ញុំគិតថាវាជាសមស្រប ឬក៏ជាការត្រឹមត្រូវដែលៗ មេធាវីខាងដើមបណ្តឹងរដ្ឋប្បវេណីគាត់បានសួរទៅលើសាក្សីអំពីបញ្ហានេះ ទាក់ទងទៅនឹងភស្តុតាង។ សូមអរគុណ។

[១៤:៣៣:២៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ!

**លោក បាណាបេ ណេគ្វី៖**

លោកប្រធាន ខ្ញុំគិតថាសហព្រះរាជអាជ្ញាបានឆ្លើយតប ទៅនឹងការជំទាស់របស់មេធាវីរូបនោះរួចមកហើយ។ ដូចបានបញ្ជាក់អ៊ីចឹង ថាទោះមានខ្លឹមសារនៃខ្សែអាត់នោះយ៉ាងណាក៏ដោយ គឺថាខាង ខៀវ សំផន គាត់អាចប្រើបាននៅពេលដែលគាត់សួរសំណួរនោះ ចំពោះខ្ញុំ ខ្ញុំមានតែពេលបន្តិចទៀត បន្តិចតែប៉ុណ្ណោះ។ ហើយច្បាស់ណាស់ ដោយយោងទៅលើប្រតិចារឹកដែលយើងមាននោះ គឺសាក្សីរូបនោះបានបញ្ជាក់រួចមកហើយ ដូចសហព្រះរាជអាជ្ញាបានបញ្ជាក់អ៊ីចឹង ថានៅពេលដែល វន វ៉េត អវត្តមាន គឺពិតណាស់ គឺលោក ខៀវ សំផន ជាអ្នកឡើងមកជំនួស វន វ៉េត នោះ។ នោះគឺមានបញ្ជាក់នៅក្នុងកំណត់ហេតុរួចមកហើយ។

[១៤:៣៤:២១]

ហើយម្យ៉ាងវិញទៀត លោកចៅក្រម ឡាវែន៍ ក៏បានបញ្ជាក់ជូនសាក្សីរួចមកហើយអំពីខ្លឹមសារនៃចម្លើយរបស់គាត់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ ហើយឥឡូវនេះ គឺខ្ញុំក៏គ្រាន់តែចង់ឲ្យសាក្សីរូបនោះបញ្ជាក់ឲ្យបានច្បាស់ អំពីចម្លើយដែលគាត់បានឆ្លើយ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនោះ គឺថាធ្វើយ៉ាងណាដើម្បីឲ្យខាងមេធាវីការពារក្តីនោះ គឺថាស្តាប់នូវចម្លើយរបស់គាត់។ ខ្ញុំមិនយល់សោះថា ហេតុអ្វីបានជានៅពេលនេះមេធាវីការពារក្តីគាត់ចង់ គឺថាបិទឱកាសរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការបញ្ចេញយោបល់នោះ វាគ្រាន់តែជាសំណួរមួយដើម្បីសួរបញ្ជាក់តែប៉ុណ្ណោះ។ ខ្ញុំសួរតែមួយទេ ហើយគាត់ចង់បិទមិនឲ្យខ្ញុំសួរទៀត។

[១៤:៣៥:០៨]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន គ្មានប្រសិទ្ធភាព។ អង្គជំនុំជម្រះអនុញ្ញាតឲ្យមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ តាំងសំណួរនេះបាន។

**លោក បាណាបេ ណេគ្រី៖**

សូមអគុណលោកប្រធាន។

**សួរដោយលោក បាណាបេ ណេគ្រី៖**

**ស៖** លោកសាក្សី ខ្ញុំគ្រាន់តែចង់ឲ្យលោកឆ្លើយពន្យល់ឲ្យច្បាស់អំពីខ្លឹមសារនៃចម្លើយរបស់លោក។ លោកចៅក្រម ឡាវែន៍ បានបញ្ជាក់រួចមកហើយថា នៅពេលដែលសហចៅក្រមស៊ើបអង្កេតសួរចម្លើយលោកនោះ លោកបានឆ្លើយថា៖ "បន្ទាប់ពី វន វេត បានបាត់ខ្លួន ខៀវ សំផន បានឡើងកាន់តំណែងជំនួស វន វេត ក្នុងឋានៈជាអ្នកទទួលខុសត្រូវខាងពាណិជ្ជកម្មក្រៅប្រទេស"។ តើលោករក្សាចម្លើយនេះដដែលទេ? នេះជាសំណួររបស់ខ្ញុំលោកសាក្សី។

[១៤:៣៦:១៣]

**លោក ខៀវ នៅ៖**

**ឆ៖** បើខ្ញុំនិយាយច្រឡំពីលើកមុន គឺសូមបញ្ជាក់ថែមថា ក្នុងការសន្និដ្ឋាន អត់មានឯកសារអីឲ្យច្បាស់លាស់ថាឡើងជំនួសទេ ប៉ុន្តែសន្និដ្ឋាន ដោយសារឃើញតែនៅកន្លែងហ្នឹង។ អាហ្នឹងអឺចឹង អាហ្នឹងបើពីមុនមក បើខ្ញុំនិយាយច្រឡំ ក៏សុំកែប្រែ។ ព្រោះខ្ញុំស្មារតីភ្លេចៗដែលហើយ វាយ៉ាប់។ ដូច្នេះ បើនឹកឃើញវិញ គឺសូមបញ្ជាក់ថែមថាក្នុងការសន្និដ្ឋាន អត់មានន័យត្រង់ណាច្បាស់លាស់ថាជាតំណាង ជា

ជំនួសតាមផ្លូវតុលាការទេ។ ដូចបញ្ជាក់ថា ក្នុងការសន្និដ្ឋាន។

**ស៖** លោកសាក្សី យើងយល់ហើយថាជាការស្មានរបស់លោក ក៏ប៉ុន្តែវាមានន័យថា បើតាមការយល់ឃើញរបស់លោកនោះ គឺលោក ខៀវ សំផន គាត់ជំនួស វន វ៉េត បន្ទាប់ពី វន វ៉េត បាត់ខ្លួន។ តើអ៊ីចឹងមែនទេ? លោកអាចបញ្ជាក់ឲ្យបានច្បាស់ទេ ថាតាមការយល់ឃើញរបស់លោកនោះ គឺ ខៀវ សំផន ជំនួស វន វ៉េត តើអ៊ីចឹងមែនទេ?

[១៤:៣៧:៣៤]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរហ្នឹងទេ។ សាក្សីមិនអាចផ្ដល់នូវចម្លើយជាការយល់ឃើញទេ។ យើងបានប្រាប់ហើយ កាតព្វកិច្ចសាក្សីត្រឹមតែបទពិសោធន៍ ឬក៏ការសង្កេតរបស់ខ្លួនបន្ថែមពីលើការចងចាំ ការឃើញ ការដឹង ការឮ។

**លោក បាណាបេ ណេគ្វី៖**

លោកប្រធាន អ្វីដែលលោកប្រធាននិយាយអម្បាញ់មិញនេះ ខ្ញុំសូមរៀបចំសំណួរឡើងវិញ។

**សួរដោយលោក បាណាបេ ណេគ្វី៖**

**ស៖** លោកសាក្សី បើតាមបទពិសោធន៍របស់លោក តើជាការពិតដែរឬទេ ចំពោះអ្វីដែលលោកឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះនេះថា បន្ទាប់ពីការបាត់ខ្លួន វន វ៉េត, ខៀវ សំផន បានឡើងជំនួស វន វ៉េត។

[១៤:៣៨:២២]

**លោក អាកទួរ វែកគែន៖**

សូមជំទាស់លោកប្រធាន។ មេធាវីរូបនេះ គាត់ថាមិនបាន-- គាត់មិនបានគិតទៅលើការកត់សម្គាល់របស់ខ្ញុំទេ។ គាត់សួរសំណួរដដែល ដែលខ្ញុំជំទាស់អម្បាញ់មិញនេះហើយ។ ដូច្នេះជាការនិយាយដដែលៗ គឺថាសុំឲ្យសាក្សីធ្វើការសន្និដ្ឋានតែប៉ុណ្ណោះ។

**លោក បាណាបេ ណេគ្វី៖**

លោកប្រធាន ខ្ញុំសូមបដិសេធទៅនឹងការជំទាស់នេះ។

ខ្ញុំរៀបចំសំណួរឡើងវិញ គឺថាខ្ញុំធ្វើយ៉ាងណា ដើម្បីឲ្យសាក្សី គាត់បាននិយាយថាបើតាមបទពិសោធន៍របស់គាត់ និងការកត់សម្គាល់គាត់ ឃើញគាត់នោះ គឺថាតើ ខៀវ សំផន មែនទេ ដែលជាអ្នក

ជំនួស វន វ៉េត ក្រោយពី វន វ៉េត បាត់ខ្លួននោះ? ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា ខ្ញុំបំប្លែងសំណួរនោះ ខ្ញុំសូមឈប់ហើយ ខ្ញុំលែងសួរអីទៀតហើយ។ ក៏ប៉ុន្តែខ្ញុំគិតថា អ្វីដែលខ្ញុំនិយាយនេះ គឺយោងសំដៅទៅលើអ្វីដែលលោកប្រធានបានកត់សម្គាល់អម្បាញ់មិញនេះ។ ខ្ញុំមិនបានឲ្យសាក្សីធ្វើការសន្និដ្ឋានព្រាវៗស្មានៗ ទេ ខ្ញុំសួរថា តាមបទពិសោធន៍របស់គាត់ ហើយនិងតាមការកត់សម្គាល់ឃើញរបស់គាត់។ តើ ខៀវ សំផន ពិតជាមកជំនួស វន វ៉េត មែនទេ នៅពេលដែល វន វ៉េត បាត់ខ្លួននោះ។

[១៤:៣៩:៣៤]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីការពារក្តីគ្មានប្រសិទ្ធភាព។ សាក្សីត្រូវឆ្លើយតបទៅនឹងសំណួរចុងក្រោយអម្បាញ់មិញ ដែលសួរឡើងដោយមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោក ខៀវ នៅ៖**

**ឆ៖** សូមសួរបញ្ជាក់សាដើមវិញ ម្តងទៀត។

**សួរដោយលោក បាណាបេ ណេគ្វី៖**

**ស៖** លោកសាក្សី សំណួររបស់ខ្ញុំគឺចង់លោកប្រាប់ជូនអង្គជំនុំជម្រះថា បើបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោក និងការកត់សម្គាល់របស់លោកនៅពេលនោះ តើ ខៀវ សំផន ជាអ្នកមកជំនួស វន វ៉េត មែនទេ នៅក្រោយពេលដែល វន វ៉េត បាត់ខ្លួននោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបនឹងសំណួរនេះ ហើយមេធាវីជាតិ យើងបានសម្រេចរួចហើយ លើបញ្ហាការតាំងសំណួរនេះ ចាំហេតុការណ៍ថ្មីទើបលោកអាចនិយាយបាន។ បញ្ហានេះយើងបានសម្រេចរួចហើយ។

**លោក ខៀវ នៅ៖**

**ឆ៖** ខ្ញុំដូចជាភាំងហើយ សូមសួរបញ្ជាក់ថែមបន្តិចទៀត។

[១៤:៤១:០៩]

**សួរដោយលោក បាណាបេ ណេគ្វី៖**

**ស៖** លោកសាក្សី ខ្ញុំនឹងសួរម្តងទៀត។ ក្រោយពីការបាត់ខ្លួន វន វ៉េត តើលោក ខៀវ សំផន គឺជាអ្នកមកជំនួស វន វ៉េត មែនទេ បើតាមបទពិសោធន៍របស់លោក និងតាមអ្វីដែលលោកកត់សម្គាល់ឃើញនៅពេលនោះ? តើសំណួរខ្ញុំច្បាស់ដែលឬទេលោកសាក្សី?

**ឆ៖** សំណួរហ្នឹងច្បាស់ហើយ ប៉ុន្តែខ្ញុំនៅតែរក្សាចម្លើយដដែល គឺក្នុងការសន្និដ្ឋាន អត់មានលក្ខណៈអីដែលច្បាស់លាស់ទេ។ ក្នុងការសន្និដ្ឋានប្រហែលជាជំនួស កាលនោះខ្ញុំនឹកអ៊ីចឹង ប៉ុន្តែដល់ហើយទៅរកភស្តុតាងអីដែលពិតប្រាកដវាមិនឃើញ បានខ្ញុំថាក្នុងការសន្និដ្ឋាន។

**ស៖** សូមអរគុណលោកសាក្សីចំពោះការឆ្លើយបំភ្លឺនេះ។

**លោក បាណាបេ ណេគ្វី៖**

ហើយដើមបណ្តឹងរដ្ឋប្បវេណីសូមបញ្ចប់ការសួរសំណួរលោកប្រធាន។ ហើយឥឡូវនេះសូមប្រគល់វេទិកានេះជូនទៅខាងមេធាវីការពារក្តីក្នុងការសួរបន្ត។

[១៤:៤២:៣៨]

**ប្រធានអង្គជំនុំ៖**

ការផ្តល់វេទិកាទៅក្រុមផ្សេងទៀតទំនងជាៗភារកិច្ចរបស់ប្រធានទេតាមមើល៍ មិនមែនរបស់ភាគីទេ។

បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការផ្តល់កន្លែងសម្រាកសមរម្យនៅកន្លែងបន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក ម៉ែខល ផេសមិន៖**

*(មិនឮសំឡេង)*

**ប្រធានអង្គជំនុំ៖**

សូមៗអធ្យាស្រ័យ បាទ អស់លោក លោកចៅក្រម តើមានសំណួរចង់សួរសាក្សីទេ? សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

[១៥:០១:៥៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ លោកប្រធាន ខ្ញុំនិយាយដោយខ្លីៗ ទេ ខ្ញុំមានសំណួរពីរបីតែប៉ុណ្ណោះសួរទៅសាក្សី។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី លោកបាននិយាយអំពី តាម៉ុក។ លោកនិយាយថា គាត់កើតនៅក្នុងស្រុកដូចលោកដែរ បើសិនជាខ្ញុំមិនច្រឡំទេ គាត់ទៅជាព្រះសង្ឃនៅក្នុងវត្ត ដែលលោកនៅដែរ។ តើលោកអាចនិយាយបានទេ ថាតើលោកមានទំនាក់ទំនងប្រភេទណាជាមួយ តាម៉ុក? តើគ្រាន់តែជាអ្នកជិតខាងរបស់លោកទេ ឬក៏ជាមិត្តភក្តិ ឬក៏ជាត្រូវជាបងប្អូនអីនឹងលោកដែរ?

**លោក ខៀវ នៅ៖**

**ឆ៖** តាម៉ុក នៅក្នុងភូមិជាមួយគ្នា ហើយជាប់សាច់ញាតិដែរ។ តែភូមិជាមួយគ្នា ភូមិដែលគាត់កើត ភូមិកំណើត តែដល់តែគាត់មករស់នៅ រស់នៅជាមួយយាយ នៅភូមិផ្សេង នៅជាមួយជីដូនរបស់គាត់។ មកនៅខាងឃុំជាងទងវិញ ភូមិប្រគាប។ ដូច្នេះ ខ្ញុំមិនបានជិតដិតតាំងពីមុនរហូតមក ហើយដល់គាត់បួស ខ្ញុំក៏នៅក្មេង។ ដូច្នេះមិនបានជិតដិតអីទេ។ គាត់លាចាកសិក្ខាមកវិញហើយ បានជិតដិតឃើញគាត់ធ្វើស្រែធ្វើចម្ការហ្នឹង។ សូមអស់ត្រឹមប៉ុណ្ណឹង។

[១៥:០៣:៤៣]

**ស៖** បាទ ដូច្នេះ គឺថាលោកពិភាក្សាជាមួយគាត់ជាញឹកញាប់ ឬក៏យ៉ាងម៉េច? តើគាត់ធ្លាប់អប់រំលោកដែរឬទេ ទាក់ទងទៅនឹងលទ្ធិនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏កុម្មុយនីស្តកម្ពុជានោះ?

**ឆៈ** ពេលសន្និសីទហ្សឺណែវហើយដែលគាត់ឈប់ធ្វើឥស្សរៈ។ គាត់មកនៅស្រុករកស៊ីធម្មតា គាត់ឆ្លៀតពន្យល់អូសទាញ។ ប៉ុន្តែអូសទាញគ្នាទៅវិញទៅមក។ ខ្ញុំអូសទាញគាត់តាមផ្លូវសាសនា ព្រះពុទ្ធសាសនា ឯគាត់អូសទាញខ្ញុំសំដៅទៅរកលទ្ធិ។ អូសទាញមិនបានទៅវិញទៅមក។ មិនបានដូចគ្នា ប៉ុន្តែចុងក្រោយបង្អស់ គាត់មានអំណាច ហាក់ដូចជាចាញ់គាត់វិញ។ ចាញ់ត្រង់គាត់មានអំណាច តែគំនិត គោលជំហរ ជំនឿ ស៊ូសព្វបែបយ៉ាងទាំងអស់មិនចាញ់ទេ នៅដដែល។ សូមជម្រាបដោយខ្លី។

**សៈ** តើគាត់មានបាននិយាយប្រាប់លោថា មានខ្មាំងបដិវត្តន៍ដែរឬទេ? ហើយតើសត្រូវណា-- អ្នកណាទៅជាសត្រូវនោះ?

**ឆៈ** គាត់និយាយតាមលទ្ធិកុម្មុយនីស្ត គាត់ថា អ្នកណាប្រឆាំងនឹងកុម្មុយនីស្តជាសត្រូវ។

**សៈ** តើនេះជាអ្វីដែលគាត់បានបង្កើតឡើងនោះ បើតាមយល់ឃើញ តាមបទពិសោធន៍របស់លោក?

**ឆៈ** សូមបញ្ជាក់សំណួរម្តងទៀត។ សូមលោកសួរម្តងទៀត។

[១៥:០៦:៣១]

**សៈ** បើសិនជាខ្ញុំយល់មិនច្រឡំទេ គឺលោកនិយាយថា បើតាម តាម៉ុកនោះ អ្នកដែលប្រឆាំងនឹងបដិវត្តនោះសុទ្ធតែជាខ្មាំង។ តើគាត់មានបានប្រាប់លោកថា ត្រូវយកខ្មាំងទៅធ្វើអ្វីទេ? ហើយត្រូវអនុវត្តនយោបាយណាមួយទេ ទាក់ទងនឹងខ្មាំងហ្នឹង?

**ឆៈ** គាត់ថា ខ្មាំង វាត្រូវតែប្រឆាំង ត្រូវតែប្រយុទ្ធគ្នា។ អ្នកដែលប្រឆាំង គឺត្រូវតែប្រយុទ្ធគ្នា គ្រាន់តែបញ្ជាក់ប៉ុណ្ណឹង។

**សៈ** ហើយដូចជាក់ស្តែងនោះ តើខ្លឹមសារនៃពាក្យពេចន៍របស់គាត់ហ្នឹង មានឥទ្ធិពលយ៉ាងម៉េចដែរ?

**ឆៈ** ឥទ្ធិពលមកលើខ្លួនខ្ញុំ មិនមានទេ។ ប៉ុន្តែអ្នកក្រៅទៀតមាន បានជាគាត់បបួលគេបានគ្នាច្រើន រហូតទៅដល់ឡើងកាន់រដ្ឋអំណាច បីឆ្នាំនោះ។ តែខ្ញុំក៏ អត់មានអំណាចអី ក៏នៅក្នុងវង់ហ្នឹងដែរ។

**សៈ** ឥឡូវនេះ ខ្ញុំនិយាយឲ្យច្បាស់ជាងហ្នឹង ចំពោះលោកនោះ ពេលដែល តាម៉ុក និយាយថា ត្រូវតែវាយប្រហារខ្មាំងនោះ មានន័យថា កម្ទេចខ្មាំងតែម្តង កុំឲ្យបាត់រូបរាង ឬក៏យ៉ាងម៉េច?

**ឆៈ** តែនិយាយថា ប្រយុទ្ធនោះ វាយ៉ាងម៉េចហៅថា ប្រយុទ្ធ ច្បាំង។ ប្រយុទ្ធគ្នា គឺច្បាំងគ្នាដណ្តើមៗអំណាចគ្នា។ អាហ្នឹង គឺបញ្ជាក់ត្រង់ពាក្យថា ប្រយុទ្ធប្រឆាំង ច្បាំងគ្នាប៉ុណ្ណឹង។

[១៥:០៩:២៣]

**ស៖** បាទសំណួរមួយទៀត ទាក់ទងទៅនឹងលោក នួន ជា លោកបានពន្យល់នៅពេលដែលលោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេត ថាលោកបានជួប នួន ជា នៅពេលដែលលោកនៅទីក្រុងភ្នំពេញ ហើយនៅពេលដែលលោក នួន ជា រកឧបករណ៍ភ្លេងបុរាណ។ លោកក៏បានប្រាប់ផងដែរថាលោកបានជួប នួន ជា តាមរយៈ តាម៉ុក។ សូមលោកប្រាប់យើងថាតើលោកជួប នួន ជា លើកទីមួយនោះនៅពេលណា ហើយ តាម៉ុក នោះនិយាយអំពី នួន ជា យ៉ាងម៉េចខ្លះ?

**ឆ៖** មិនមែនជួបលោក នួន ជា តាមរយៈ តាម៉ុក ទេ។ ជួបពេលនោះ គាត់ទៅ អត់មាន តាម៉ុក នៅហ្នឹងទេ។ ប៉ុន្តែលោក នួន ជា ដឹកកន្លែងខ្ញុំ ហើយទៅឈប់ឡានក្បែរហ្នឹង ក៏ហៅមកជួបប្រាប់ឲ្យរកឧបករណ៍ភ្លេងតែម្តងទៅ។

**ស៖** បើសិនជាខ្ញុំមិនច្រឡំទេ គឺថា នួន ជា មកជួបលោក ព្រោះថា តាម៉ុក ប្រាប់ នួន ជា ថាឲ្យមកជួបលោក អ៊ីចឹងមែនទេ?

**ឆ៖** មិនមែនៗ តាម៉ុក ប្រាប់ទេ ពួកក្រុមភ្លេង។ ក្រុមភ្លេងដែល តាម៉ុក ឲ្យគេនាំប្រមូលមកដើម្បីប្រចាំនៅប៉ុស្តិ៍វិទ្យុ។ ក្រុមភ្លេងដែល តាម៉ុក ប្រមូលមក មិនមែន តាម៉ុក ប្រាប់ទេ។ ក្រុមភ្លេងហ្នឹងរាយ-ការណ៍ជូនលោក នួន ជា។ បានលោក នួន ជា បានដឹង។ រឿងហ្នឹងបាន ព្រោះពួកភ្លេងហ្នឹង គឺតាម៉ុកឲ្យខ្ញុំដឹកមក ដឹកពីតាកែវ ដឹកពីអឺមក។ មិនមែន តាម៉ុក ប្រាប់ទេ គឺក្រុមភ្លេងដែល តាម៉ុក ឲ្យមក។ រាយការណ៍ទៅលោក នួន ជា បានលោក នួន ជា ដឹងរឿងហ្នឹងបានមកសួរខ្ញុំ បញ្ជាក់ខ្ញុំ។

[១៥:១១:៥៤]

**ស៖** បាទ លើកនេះសំណួរចុងក្រោយ។ ទាក់ទងទៅនឹងមុខការរបស់លោកនៅទីក្រុងភ្នំពេញ ហើយយើងយល់ច្បាស់ហើយថា លោកនៅក្នុងផ្នែកសេដ្ឋកិច្ចដែលនៅក្នុងចំណុះភូមិភាគនិរតី ហើយដល់ជាក់ស្តែងនោះ អ្នកណាជាមេរបស់លោក គឺតាម៉ុក ឬក៏ជាក្រសួងពាណិជ្ជកម្ម ឬក៏ទាំងពីរផ្នែកនេះតែម្តង?

**ឆ៖** ពាណិជ្ជកម្មប្រចាំភូមិភាគហ្នឹង ទទួលការគ្រប់គ្រងពី តាម៉ុក។ តាម៉ុក ប្រធានហើយ។

**ស៖** ហើយ តាម៉ុក ទាក់ទងជាមួយក្រសួងពាណិជ្ជកម្មតាមរយៈលោក ឬក៏ធ្វើទំនាក់ទំនងជាមួយក្រសួងពាណិជ្ជកម្មដោយផ្ទាល់ តើការទាក់ទងនោះនោះយ៉ាងម៉េចដែរ?

**ឆ៖** ក្រសួងខាងឃ្លាំងរដ្ឋ ត្រូវចែកទៅភូមិភាគនិរតីហ្នឹងប៉ុន្មានៗ គឺចេញសំបុត្រឲ្យទៅយក

ឲ្យទៅយក ឲ្យទៅដឹកចេញ។ មិនបាច់យើងទៅទាក់ទងអីទេ គឺដល់ពេលថាត្រូវចែក ឲ្យសំបុត្រហ្នឹងមក ឲ្យទៅដឹកចេញ។ វៀរលែងតែរបស់ដែលត្រូវស្នើសុំ អាហ្នឹងបានខាងភូមិភាគទៅសុំ បើថារបស់ជានិច្ចជាអចិន្ត្រៃយ៍ គឺត្រូវតែចែក បែងចែកដល់កំណត់ឲ្យទៅយក។ ដឹកអីប៉ុន្មានៗហ្នឹង គឺមានចំនួននៅក្នុងសំបុត្រសព្វគ្រប់។

[១៥:១៤:០២]

**ស៖** បាទ ឥឡូវខ្ញុំចង់យល់ឲ្យបានលម្អិត។ លោកនិយាយអំពីការិយាល័យ-- មន្ទីរ ក-២២ តើអ្នកណាជាប្រធាន? ហើយប្រធាននោះមានតួនាទីអ្វីដែរ?

**ឆ៖** ក-២២ ដែលខ្ញុំទាក់ទងនឹងគឺឈ្មោះ សេន ត្រូវជាក្មួយប្រសារខ្ញុំ។ ហើយសួរទៅ ថានៅជាមួយលោក ខៀវ សំផន។ ត្រង់អំណាចយ៉ាងម៉េចៗ តទៅទៀតខ្ញុំមិនដឹងទេ។

**ស៖** ដូច្នេះ នេះគឺជាក្មួយរបស់លោក ដែលលោកបាននិយាយអម្បាញ់មិញនេះ ដែលលោកនិយាយថា មិន-- ក្រៅផ្លូវការលោកក៏ទាក់ទង ខៀវ សំផន និយាយអំពីតម្រូវការរបស់ប្រជាជននៅខេត្តកណ្ដាល។ តើលោកចង់យោងទៅលោក សេង ដែលជាក្មួយលោកហ្នឹងមែនទេ ដែលគាត់ជាប្រធានមន្ទីរ ក-២២ នេះ?

**អ្នកបកប្រែ៖**

បាទ អ្នកបកប្រែសូមកែប្រែ ឈ្មោះ សេន។

**លោក ខៀវ នៅ ៖**

**ឆ៖** សេន, សុន សេន។ មិនថាជាប្រធានទេ ខ្ញុំមិនដឹងថាយ៉ាងម៉េចៗទេ ប៉ុន្តែដោយសារជាក្មួយប្រសារ ក៏ទាក់ទងៗផ្ទាល់តែម្ដង ហើយបាន សេន ហ្នឹង រាយការណ៍ទៅលើ។

**ស៖** នៅក្នុងសំណុំរឿងគឺថាមានឯកសារដែលបានដាក់ជូនអង្គជំនុំជម្រះហើយ គឺឯកសារ E3/1236, E3/20032-- អ៊ំ!232 (សូមទោស), E3/1288 គឺជារបាយការណ៍ប្រចាំសប្ដាហ៍នៃក្រសួងពាណិជ្ជកម្ម ដែលរៀបរាប់អំពីបរិមាណចូលនិងចេញនៃឃ្លាំងរដ្ឋ។ គឺបរិមាណស្រូវៗ ហើយនិងដំណើប អង្ករដំណើប និងប្រភេទស្រូវផ្សេងៗទៀត ហើយនិងកន្ទក់ផងដែរ។ ខ្ញុំកត់សម្គាល់ថានៅក្នុងឯកសារនេះ មានកាលបរិច្ឆេទនៃសេចក្ដីសម្រេច។ ខ្ញុំមិនដឹងថា ជាសេចក្ដីសម្រេចឲ្យនាំស្រូវចូល ឬក៏យកស្រូវចេញនោះទេ នៅក្នុងឃ្លាំងនោះ។ លើកាលបរិច្ឆេទហ្នឹង គឺថាមានចំណារ ក-២២។ សំណួរខ្ញុំដូចតទៅនេះ តើរាល់ការនាំផលិតផលចេញ ជាពិសេសផលិតផលស្រូវនោះ ឃ្លាំងរដ្ឋត្រូវតែទទួលការ

អនុញ្ញាតពីមន្ទីរ ក-២២ ដែរឬទេ?

[១៥:១៧:៤១]

**ឆ៖** ការងារក្នុងរដ្ឋ ខ្ញុំមិនដឹងទេ។ កាលណារដ្ឋចេញសំបុត្រមក ក៏ធ្វើតាមសំបុត្រ ឯការងារយ៉ាងម៉េច អំណាចយ៉ាងម៉េច គឺខ្ញុំមិនដឹងទេ។ ប៉ុនខ្ញុំខាងភូមិភាគ។

**ស៖** អម្បាញ់មិញនេះ លោកបានប្រាប់ថា នៅពេលដែលលោកត្រូវដឹកសម្ភារៈពីឃ្លាំងរដ្ឋទៅខេត្តនានា លោកត្រូវតែមានលិខិតអនុញ្ញាត យ៉ាងហោចណាស់ក៏ត្រូវផ្តល់លិខិតអនុញ្ញាតទៅឃ្លាំងរដ្ឋ។ តើ-- ខ្ញុំសូមបញ្ជាក់ម្តងទៀត តើអ្នកណាជាអ្នកសរសេរលិខិតនេះ? ហើយអ្នកណាជាអ្នកផ្តល់ការអនុញ្ញាត?

**ឆ៖** មួយចំនួនចេញពី ក-២២ មក ប៉ុន្តែខ្ញុំមិនចាំបានស៊ីញ៉េទេ គ្រាន់តែដាក់ថា ក-២២ ហើយឈ្មោះ មិនចាំទេ។ អត់ដែលមើលផង ច្រើនតែពួកឡាន ទទួលយកមក យកទៅបើក មិនបានពិនិត្យស៊ីញ៉េ ពិនិត្យអីទេ គ្រាន់តែ ក-២២ ថាឲ្យដឹក ក៏នាំគ្នាទៅដឹកមកតែម្តង។ អត់បាច់ពិនិត្យអីវែងឆ្ងាយទេ។ ដូច្នេះ មិនបានចាំស៊ីញ៉េអីសព្វគ្រប់ទេ។ វាកិច្ចការជាប្រចាំហើយ អត់មានពិនិត្យអីច្រើន ថាឲ្យដឹករបស់គឺប្រញាប់តែដឹកតែម្តង។

[១៥:១៩:៣១]

**ស៖** អ្នកទទួលខុសត្រូវឃ្លាំងរដ្ឋនោះ គឺលោក រឿន មែនទេ?

**ឆ៖** រឿងៗ មិនមែន រឿន ទេ។ រឿង។

**ស៖** បាទ សូមទោស។ តើមានឃ្លាំងច្រើនទេ នៅក្នុងភ្នំពេញ ហើយនៅឃ្លាំងទាំងអស់នោះមានអីខ្លះ? មានតែស្រូវទេ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំមិនដឹងទេ ដឹងតែច្រើន ប៉ុនមិនដឹងស្អីខ្លះទេ។ ព្រោះអ្នកដែលទៅដឹកហ្នឹងគឺ ឲ្យពួកឡានដែលដឹកជញ្ជូន ទៅកាន់តែសំបុត្រហ្នឹងទៅ កាន់សំបុត្រទៅបានដឹកមក។ មិនដឹងថាមាននៅកន្លែងណាៗច្បាស់លាស់ទេ ហើយមានអីខ្លះ មិនច្បាស់លាស់គ្រប់ទីកន្លែងទេ ព្រោះគេខាងរដ្ឋ។

**ស៖** តើលោកធ្លាប់រៀបចំការដឹកជញ្ជូនស្រូវពីឃ្លាំងរដ្ឋទាំងអស់នេះ ទៅកំពង់សោមដែរឬទេ?

**ឆ៖** ការដឹកជញ្ជូនទៅតំបន់ ទៅភូមិភាគ អាហ្នឹងទើបភូមិភាគមានសិទ្ធិទៅ។ ឯបើដឹកទៅកំពង់សោម វាខុសកន្លែងហើយ អាហ្នឹងដល់ខាងរដ្ឋ។ មានក្រសួងដឹកជញ្ជូនជើងគោក គឺខាងរដ្ឋដឹកទៅតែម្តង។ ហើយខាងកំពង់សោមវាមានផ្លូវរទេះភ្លើង អយស្ម័យយាន អត់មានត្រូវការឡានអីច្រើនទេ ឡាន

គ្រាន់តែជញ្ជូនដាក់រទេះភ្លើងប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំខាងភូមិភាគនេះអត់ទេ គឺខាងរដ្ឋហើយត្រូវដឹកជញ្ជូនរបស់ចេញទៅក្រៅ ដឹកពីក្រៅចូលមក អាហ្នឹងខាងរដ្ឋ ខាងប្រទេស។

[១៥:២២:០៥]

**ស៖** បាទ ដូច្នេះ តួនាទីរបស់លោកគឺថាកម្រិតមកត្រឹមការដឹកជញ្ជូនពីភូមិភាគនិរតីមកភ្នំពេញ ហើយពីភ្នំពេញទៅភូមិភាគនិរតីវិញ ហើយពុំមានអ្វីលើសពីហ្នឹងទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងហើយ។

**ស៖** បាទ សូមអរគុណ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទសូមអរគុណ។ ខ្ញុំពុំមានសំណួរអីចោទសួរទៅសាក្សីទៀតទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អស់លោក លោកស្រីចៅក្រមមានសំណួរទៀតទេ?

បាទ មិនមានទេ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

[១៥:២២:៥៩]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ មុនពេលដែលខ្ញុំចាប់ផ្តើមនូវសំណួររបស់ខ្ញុំ ខ្ញុំចង់លើកឡើងនូវបញ្ហាមួយចំនួនដែលសំខាន់ ដែលថាមេធាវីខាង អៀង សារី បាននិយាយនៅពេលរសៀលនេះមកហើយ គឺនិយាយអំពីប្រតិចារឹកដែល១បានដែលសាក្សីបានផ្តល់នៅក្នុងឆ្នាំ២០០៩។ ឥឡូវនេះ ខ្ញុំនិយាយអំពីឯកសារ D166/183.1 ហើយខ្ញុំបានធ្វើការប្រៀបធៀបនូវបួនទំព័រដើមនៃប្រតិចារឹកនៃការសម្ភាសជាមួយនឹងការសរសេរសង្ខេប គឺបានន័យថាកំណត់ហេតុស្តាប់ចម្លើយសាក្សីនេះ ខ្ញុំមិននិយាយ-- ខ្ញុំចង់និយាយថា ខ្ញុំមានការរន្ធត់ ឬក៏ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយធ្វើការប្រៀបធៀបនេះ។ នៅពេលដែលប្រៀបធៀបប្រតិចារឹកជាមួយនឹងការសង្ខេបនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី វាពិបាកនៅក្នុងការពិពណ៌នាអំពីអ្វីដែលបានកើតឡើងនៅក្នុងការសម្ភាសនោះណាស់ ព្រោះថាការសម្ភាសនោះ វាដូចជាការសន្ទនារវាងអ្នកស៊ើបអង្កេត ជាមួយនឹងសាក្សី ហើយវាមានលក្ខណៈថារញ៉េរញ៉ៃច្របូក

ច្របល់ណាស់។

ដូច្នេះ វាហាក់ដូចជាមិនអាចនិយាយបានថា វាអាចនោះទេ ដែលយើងអាចបង្កើតព័ត៌មាន ឬក៏អាចយកព័ត៌មានមកប្រើប្រាស់ ហើយម្យ៉ាងទៀត អ្នកស៊ើបអង្កេតនោះបានផ្តល់នូវព័ត៌មានយ៉ាងច្រើនទៅឱ្យសាក្សីនោះ។ បញ្ហាមួយទៀត ដែលបានកើតឡើង គឺថាការសង្ខេបខ្លួនឯងផ្ទាល់នោះ គឺៗខ្ញុំចង់និយាយអំពីការសង្ខេប គឺវាមានលក្ខណៈមិនត្រឹមត្រូវ មិនសមស្រប ហើយវាមានលក្ខណៈខុសឆ្គង ហើយការពិតទៅវាមិនមែនជាការសង្ខេបនោះទេ ប៉ុន្តែខ្ញុំគិតថា វាជាការបកស្រាយផ្ទាល់ខ្លួនរបស់--ការសន្ទនាដ៏មានលក្ខណៈរញ៉េរញ៉ៃមួយ។

[១៥:២៥:០១]

នៅពេលដែលខ្ញុំធ្វើការប្រៀបធៀបនៅប្អូនទំព័រនៃប្រតិចារឹក គឺខ្ញុំបានទទួលត្រឹមតែមួយផ្នែក តូចមួយនៃសេចក្តីសង្ខេប គឺកំណត់ហេតុស្តាប់ចម្លើយនោះ។ ដូច្នេះហើយខ្ញុំគិតថាកំណត់ហេតុស្តាប់ចម្លើយសាក្សីនេះ គឺមិនមានព័ត៌មានអ្វីដែលសំខាន់ ឬក៏ល្អនោះឡើយ ទោះបីថាយើងទទួលស្គាល់នូវកំណត់ហេតុស្តាប់ចម្លើយសាក្សី ហើយដាក់នៅចំពោះមុខអង្គជំនុំជម្រះក៏ដោយ ក៏យើងមិនអាចពឹងផ្អែកទៅលើកំណត់ហេតុនេះដែរ។ ហើយយើងមិនអាចប្រើ ឬក៏យើងមិនអាចទទួលយកអ្វី ពីកំណត់ ហេតុស្តាប់ចម្លើយសាក្សីនោះឡើយ។

[១៥:២៥:៣៨]

ដូច្នេះខ្ញុំសន្និដ្ឋានថា ឬក៏ខ្ញុំចង់លើកឡើងថា កំណត់ហេតុនេះគឺវាមិនអាចទុកចិត្តបាន។ ហើយចំណុចទីពីរដែលខ្ញុំចង់និយាយ គឺពាក់ព័ន្ធទៅនឹងសំណួរ ថាតើអង្គជំនុំជម្រះបានសម្រេចអំពីសំណើរបស់យើង គឺសំណើតាមវិធាន៨៦ ដែលដាក់កាលពីខែកក្កដា គឺឯកសារលេខៗ E210 គឺថាតើសេចក្តីសម្រេចចំពោះសំណើតាមវិធាន៨៧ ហ្នឹង គឺយ៉ាងម៉េចដែរ?

ដូច្នេះ ខ្ញុំកំពុងតែរង់ចាំនូវការណែនាំពីខាងអង្គជំនុំជម្រះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការឆ្លើយតបយ៉ាងសង្ខេបទៅនឹងសំណើមួយនេះ។ យើងមិនយល់ស្របជាមួយនឹងសហភាគីរបស់យើងទេ។ អ្វីដែលយើងបានទទួលដូចដែលយើងបានបញ្ជាក់ពី

ដើមរួចមកហើយ គឺជាការដកស្រង់សង្ខេបនូវការសម្ភាសដ៏វែង។ ក៏ប៉ុន្តែកំណត់ហេតុហ្នឹង គឺជាសេចក្តីសង្ខេបនៃការសម្ភាស។ ដូច្នេះ វាពិបាកនៅក្នុងការវាយតម្លៃ អំពីភាពជាក់លាក់ ឬក៏ភាពពិតប្រាកដដូចដែលសហភាគាខ្ញុំបានធ្វើឡើង គាត់ធ្វើការប្រៀបធៀបត្រឹមតែបួនទំព័រ។ ប៉ុន្តែអ្វីដែលធ្វើឡើង អ្វីដែលសម្ភាសឡើងគឺវាវែង។

[១៥:២៧:១០]

ហើយឥឡូវនេះយើងមានសាក្សីនៅទីនេះ តាំងពីម្សិលមិញ ហើយនិងថ្ងៃនេះ យើងអាចពិនិត្យមើលទៅលើកំណត់ត្រា។ ហើយម្យ៉ាងទៀត គាត់បានបញ្ជាក់រួចហើយអំពីភាពត្រឹមត្រូវនៃការសម្ភាសនៃកំណត់ហេតុស្តាប់ចម្លើយសាក្សី។ ដូច្នេះហើយ គឺខ្ញុំគិតថា អានេះគឺជាអ្វីដែលបានកើតឡើង គឺយើងបានកោះហៅសាក្សីមកធ្វើការផ្តល់សក្ខីកម្ម យើងធ្វើការត្រួតពិនិត្យ ហើយសាក្សីគាត់បានផ្តើមបញ្ជាក់។

ដូច្នេះអ្វីដែលខ្ញុំចង់និយាយ គឺថាការនិយាយថា សេចក្តីសង្ខេបហ្នឹង គឺវាមិនត្រឹមត្រូវ ឬក៏មិនសមស្របហ្នឹង គឺវាមិនស្របជាមួយនឹងអ្វីដែលសាក្សីបានបញ្ជាក់នោះទេ។

[១៥:២៧:៥១]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣១:០៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីឆ្លើយតបទៅនឹងសំណួរនិងបញ្ហាដែលលើកឡើងដោយក្រុមមេធាវីការពារក្តីលោក នួន ជា អម្បាញ់មិញនេះ។ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ទាក់ទងទៅនឹងឯកសារ E210 អង្គជំនុំជម្រះបានទទួលពីម្សិលមិញនេះ ហើយយើងមិនចាំបាច់ឲ្យមេធាវីការពារក្តីលោក នួន ជា បញ្ជាក់ឡើងវិញនូវការជំទាស់ជាទៀងទាត់របស់ខ្លួនទៅអង្គជំនុំជម្រះ ទៅលើសេចក្តីសម្រេចរបស់ខ្លួនទេ។ យើងយល់ដឹងអំពីការព្រួយបារម្ភរបស់លោក ប៉ុន្តែនៅក្នុងឯកសារនេះ នៅពេលដែលលោកជម្រាបអង្គជំនុំជម្រះថា ឯកសារណាមួយដែលលោកចង់ប្រើ នៅក្នុងការសួរដេញដោលសាក្សីរូបនេះ ថាតើឯកសារណាមួយនោះ បានដាក់ចំពោះមុខអង្គជំនុំជម្រះ ឬក៏នៅក្នុងបញ្ជីរបស់សាក្សីណាមួយ។ ពេលនោះយើងនឹងសម្រេចទៅតាម

ករណីនោះ។

[១៥:៣២:១៤]

នេះជាបញ្ហាដោយឱ្យមេធាវីស្រាវជ្រាវ ហើយរង់ចាំព័ត៌មានទាំងនោះ។ ហើយលោកអាចផ្តល់ឱ្យអង្គជំនុំជម្រះភ្លាមៗក៏បានដែរ។ សូមអរគុណលោកប្រធាន។

**លោក ម៉ៃខល ផេសមិន៖**

លោក លោកស្រីចៅក្រមគឺថា ឯកសារនេះគឺមិនស្ថិតនៅក្នុងបញ្ជីនោះទេ។ ហើយខ្ញុំជឿថា ឯកសារមួយ គឺថាមាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា ប៉ុន្តែមួយទៀតមិនមានទេ។ ដូចដែលលោកចៅក្រមជ្រាបហើយ គឺថាយើងប្រកាន់ជំហរ គឺថាឯកសារនេះ នៅក្នុងបញ្ជីរបស់យើង យើងមិនមានកាតព្វកិច្ចនឹងផ្តល់ព័ត៌មានអីឱ្យអង្គជំនុំជម្រះនោះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

[១៥:៣៣:០៨]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោកបានទទួលការណែនាំឱ្យគោរពទៅតាមសេចក្តីសម្រេច ហើយផ្តល់ព័ត៌មានមកអង្គជំនុំជម្រះថាតើឯកសារដែលលោកនឹងចង់ប្រើ ត្រូវបានដាក់ចំពោះមុខ ឬក៏ស្ថិតនៅក្នុងបញ្ជីរបស់ភាគីណាមួយហើយនៅ? អង្គជំនុំជម្រះបានដឹងច្បាស់ហើយ ថាមេធាវីការពារក្តីលោក នួន ជា មិនបានផ្តល់បញ្ជីលម្អិតរបស់សាក្សី ដើម្បីលើកមកទេ។ ហើយលោកអាចផ្តល់ព័ត៌មាននេះភ្លាមៗ។ យើងមិនអាចនឹងធ្វើការស្រាវជ្រាវជំនួសឱ្យភាគីនោះទេ យើងឱ្យភាគីខ្លួនឯងជាអ្នកស្រាវជ្រាវនោះ។

**លោក ម៉ៃខល ផេសមិន៖**

លោក លោកស្រីចៅក្រម IS19.200 នៅក្នុងបញ្ជីដែលសហព្រះរាជអាជ្ញាបានប្រើ ហើយ IS19.3 គឺមិនស្ថិតនៅក្នុងបញ្ជីរបស់ភាគីណាមួយទេ គឺ IS19.203 បាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

សូមអរគុណ។ ក្នុងករណីនេះលោកអាចយោងទៅរកឯកសារ IS19.200 ប៉ុន្តែមិនត្រូវយោងទៅរក IS19/203 នោះទេ។ ឥឡូវនេះលោកអាចបន្តការតាំងសំណួរ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំបានឮ ប៉ុន្តែមិនតាមរយៈ*ហេតហ្វូន*របស់ខ្ញុំទេ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

តើលោកអាចស្តាប់ខ្ញុំបានទេ លោក ផេសមិន ដោយមិន-- លោក ផេសមិន តើលោកអាចស្តាប់ខ្ញុំបានទេ ដោយមិន-- លោកអាចយោងទៅរក IS19/200 ប៉ុន្តែមិនត្រូវយោងទៅរក IS19/203 ទេ។

[១៥:៣៥:៥០]

**លោក ម៉ៃខល ផេសមិន៖**

អរគុណលោកស្រីចៅក្រម គឺខ្ញុំអាចយល់បានដោយមិនស្តាប់*អៀហ្វូន* នេះ ហើយខ្ញុំៗយល់ថាត្រូវតែបង្ហាញឯកសារនេះជាមួយគ្នា ខ្ញុំចង់យោងទាំងពីរ។ ខ្ញុំចង់សួរដេញដោលសាក្សី ផ្អែកលើឯកសារទាំងពីរនេះ ដែលគាំទ្រគ្នាទៅវិញទៅមក ហើយនៅក្នុងទស្សនៈរបស់យើងគឺថា អាចមានព័ត៌មានដ៏សំខាន់នៅក្នុងនោះ ហើយបើសិនជាសម្រេចបែបនេះ ហាក់ដូចជាហាមមិនឲ្យយើងខ្ញុំប្រើឯកសារពីរនេះដែរ។ ដូច្នេះ ខ្ញុំបង្ខំខ្លួនឲ្យប្រគល់វេទិកាទៅឲ្យមេធាវីរបស់លោក ខៀវ សំផន។ ដូច្នេះ ខ្ញុំត្រូវបង្ខំខ្លួនមិនអាចសួរបានទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បានបង្ហាញជំហរច្បាស់លាស់ដូច្នេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោល ចំពោះសាក្សីរូបនេះ។

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមសាជាថ្មី។ សួស្តីសហព្រះរាជអាជ្ញា សហភាគា លោកអ្នកទាំងឡាយដែលចូលរួមសវនាការនេះផង។ ហើយសួស្តីលោក ខៀវ នៅ ខ្ញុំអាងឧត្តម សហមេធាវីការពារក្តីលោក អៀង សារី។ នៅពេលនេះ ខ្ញុំគ្មានសំណួរនឹងសួរលោកទេ យ៉ាងណាក្តីតាងនាមលោក អៀង សារី ខ្ញុំសូមអរគុណលោក ដែលបានមកផ្តល់សក្ខីកម្មជួយតុលាការ ក្នុងការស្វែងរកការពិត។ សូមជូនពរលោក បានសុខសប្បាយតាមផ្លូវត្រឡប់ទៅវិញ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាកិច្ចបន្តអង្គជំនុំជម្រះ សូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

[១៥:៣៨:០១]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ។

បើតាមការស្តាប់ចម្លើយរបស់សាក្សីកន្លងមកនេះ យើងឃើញថា សាក្សីបានបង្ហាញជំហរយ៉ាងច្បាស់ហើយ ហើយក្រុមមេធាវីការពារលោក ខៀវ សំផន គ្មានសំណួរអ្វីបន្ថែមទៀតទេ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ លោក ខៀវ នៅ ដំណើរការសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សីរបស់លោក បានចប់សព្វគ្រប់ហើយ។ អង្គជំនុំជម្រះ សូមថ្លែងអំណរគុណចំពោះលោក ដែលបានចំណាយពេលវេលាដ៏មានតម្លៃ មកចូលរួមផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ក្នុងរយៈពេលពីរថ្ងៃនេះ ហើយប្រកបដោយភាពអត់ធ្មត់ និងខិតខំអស់ពីលទ្ធភាព សមត្ថភាពដែលមាន ហើយរួម-- អាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ។

ហើយលោក ខៀវ នៅ អាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោក ឬក៏គោលដៅដែលលោកមានបំណងត្រឡប់ទៅវិញបានហើយ ហើយសូមលោកធ្វើដំណើរត្រឡប់ទៅវិញ ប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការបញ្ជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅដែលគាត់ចង់ទៅវិញផងចុះ។

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ល្មមសមពេលសម្រាកហើយ ប៉ុន្តែមុននឹងសម្រាកអង្គជំនុំជម្រះចេញនូវសេចក្តីព្រមានរបស់ខ្លួនមួយ ដែលមានខ្លឹមសារដូចខាងក្រោមនេះ៖

[១៥:៣៩:៤៤]

នៅក្នុងអំឡុងពេលសវនាការលើសំណុំរឿងក្តី០០២/០១ អង្គជំនុំជម្រះបានកត់សម្គាល់អំពីការ

ប្រព្រឹត្តមិនត្រឹមត្រូវដែលមានលក្ខណៈស៊ីសង្វាក់គ្នារបស់មេធាវីការពារក្តី ឱ្យជនជាប់ចោទ នួន ជា ជាពិសេស គឺមេធាវីអន្តរជាតិការពារក្តីក្នុងក្រុមនេះ។ ការប្រព្រឹត្តមិនត្រឹមត្រូវនេះ រួមមាន៖

-ការរំលោភដោយចេតនាលើសេចក្តីបង្គាប់នានារបស់អង្គជំនុំជម្រះ។

-ការបញ្ចេញឯកសារសម្ងាត់ ឬសម្ងាត់បំផុតទៅសារព័ត៌មាន ដោយគ្មានការអនុញ្ញាត។

-និងការធ្វើសេចក្តីថ្លែងការណ៍នានា ក្នុងតុលាការមិនគោរពដល់តុលាការ ឬមិនស្រប តាមនិយាម និងក្រមសីលធម៌វិជ្ជាជីវៈច្បាប់ ដែលមានការទទួលស្គាល់ឡើយ។

អាស្រ័យហេតុនេះ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងថា អំពើ និងគំរូផ្សេងៗ ដែលមិនត្រឹមត្រូវទាំងនេះនឹងត្រូវបញ្ជូនទៅគណៈមេធាវីជាតិនៃមេធាវីដែលមានបញ្ហាពាក់ព័ន្ធ ដើម្បីឱ្យចាត់វិធានការសមស្រប អនុលោមតាមវិធាន៣៨ នៃវិធានផ្ទៃក្នុង។

[១៥:៤១:១០]

អង្គជំនុំជម្រះសាលាដំបូង ចេញសេចក្តីព្រមាននេះជាផ្លូវការ ស្របតាមវិញធាន៣៨ អនុវិធាន១ នៃវិធានផ្ទៃក្នុង និងកត់សម្គាល់ថា អង្គជំនុំជម្រះនឹងចាត់វិធានការតាមនីតិវិធី ដូចមានចែងនៅក្នុងវិធាននេះ ក្រៅពីវិធានការដែលត្រូវបាន ត្រូវចាត់ការដោយគណៈមេធាវីជាតិនៃមេធាវីដែលមានបញ្ហាពាក់ព័ន្ធ។

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើទៅ បន្តធ្វើនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

សវនាការនឹងប្រព្រឹត្តធ្វើទៅ-- បន្តធ្វើនៅថ្ងៃចន្ទ ទី១៦ ខែកក្កដា ឆ្នាំ២០១២ អង្គជំនុំជម្រះនឹងដំណើរការស្តាប់សក្ខីកម្មអ្នកជំនាញ ដេវីដ ឆេនល័រ។ ហេតុដូច្នេះ សូមភាគី និងសាធារណជនជ្រាប។

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញចុះ ហើយនិងឱ្យពួកគាត់ទាំងបីរូប មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃចន្ទ ទី១៦ ខែកក្កដា ឆ្នាំ២០១២ ឱ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៤២ នាទី)*